ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ











# ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ វិស័យជលផល ៖ ២០១៥ - ២០២៤

ជលផលសម្រាប់អនាគត



៤

ទក្ក

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

© ២០១៥ រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កម្ពុជា



# បុព្វកថា





ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុម័តជាផ្លូវការ ហើយបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ស្តីពី កំណើនការងារ សមធម៌ និងប្រសិទ្ធភាព និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨។ លើសពីនេះ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ ២០១០-២០១៩ គឺជាផែនការមេសម្រាប់ដាក់បញ្ចូលជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ដែលកម្មវិធីជលផលត្រូវបានដាក់បញ្ចូលនៅក្នុងផែនការយុទ្ធសាស្ត្រនេះ គឺតំណាងឱ្យផែនការគ្រប់គ្រងវិស័យជលផលជាតិ។

បន្ទាប់ពីមានការអនុម័តលើក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ រួចមករាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវកំណែទម្រង់វិស័យជលផលបានយ៉ាងល្អប្រសើរ។ កំណែទម្រង់វិស័យជលផលស៊ីជម្រៅក្នុងឆ្នាំ២០១២ គឺជាព្រឹត្តិការណ៍ដ៏សំខាន់បំផុតក្នុងកំណែទម្រង់វិស័យជលផលដែលបានអនុវត្តជាបន្តបន្ទាប់កន្លងមក ក្នុងនោះរាជរដ្ឋាភិបាលបានសម្រេចលុបចេញទាំងស្រុងនូវឡូតិ៍នេសាទបឹងព្រែកដែលនៅសល់ទាំង៨០។ កំណែទម្រង់នេះរួមមាន ការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវដល់សហគមន៍នេសាទ ក្នុងការសហការគ្រប់គ្រងធនធានជលផល។ ដើម្បីគាំទ្រដល់កំណែទម្រង់វិស័យជលផល រដ្ឋបាលជលផលបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងសហគមន៍នេសាទ ដោយបានគាំទ្រនិងជួយសម្របសម្រួលរៀបចំសហគមន៍នេសាទបានជាង៥១៦សហគមន៍។

ចាប់តាំងពីក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ ត្រូវបានអនុម័តរួចមកមានកត្តាខាងក្រៅដែលជះឥទ្ធិពលមកលើវិស័យជលផលកាន់តែមានការកើនឡើង។ កត្តាដែលជះឥទ្ធិពលទាំងនេះរួមមាន ការប្រែប្រួលអាកាសធាតុ ការសាងសង់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានា ការគ្រប់គ្រងដីនិងការអភិវឌ្ឍសេដ្ឋកិច្ច រួមទាំងការបង្កើតឡើងនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ក្រៅពីនេះ ក៏មានការប្រែប្រួលនូវគោលនយោបាយពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ បញ្ហាកុមារ និងយុវជនផងដែរ។ កំណែទម្រង់គោលនយោបាយដ៏មានសារៈ







សំខាន់នេះ គឺជាការបង្កើននូវការយកចិត្តទុកដាក់ទៅលើការធ្វើពាណិជ្ជនីយកម្ម និងការអភិវឌ្ឍកសិឧស្សាហកម្ម នៅក្នុងវិស័យកសិកម្ម។ ទោះបីជា ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ នៅមានសុពលភាពក៏ដោយ ប៉ុន្តែដោយមានការប្រែប្រួលនូវបរិយាកាសគោលនយោបាយនិងសេដ្ឋកិច្ចនោះ ការកែសម្រួលនិងការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ ២០១០-២០១៩ ឱ្យបានសមស្រប គឺជាការចាំបាច់។

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ រួមមាន៣វគ្គដែលក្នុងនោះវគ្គទី១ មានចំណងជើងថា "ជលផលសម្រាប់អនាគត" គឺជាឯកសារសំខាន់និងជាឯកសារគោលសម្រាប់ការធ្វើបច្ចុប្បន្នភាពនេះ។ ចំណែកវគ្គទី២ គឺផ្តល់នូវ "ព័ត៌មានជាសារវតា" និងវគ្គទី៣ គឺរៀបរាប់អំពី " ក្រមប្រតិបត្តិជលផលកម្ពុជា (កាំកូដ)" ។

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលវគ្គទី៤ ឆ្នាំ២០១៥-២០២៤ ដែលត្រូវធ្វើបច្ចុប្បន្នភាពនេះ រួមមានខ្លឹមសារបញ្ជាក់អំពី សមិទ្ធផលសម្រេចបាននៃវិស័យជលផលក៏ដូចជាសក្តានុពលនាពេលបច្ចុប្បន្ន បញ្ហាប្រឈម និងការធ្វើបច្ចុប្បន្នភាពអភិក្រមជាយុទ្ធសាស្ត្រ សំដៅសម្រេចបាននូវទស្សនវិស័យរបស់វិស័យជលផល។ លើសពីនេះ សូចនាករកម្រិតលទ្ធផលសម្រេចនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ត្រូវបានកែសម្រួលនិងធ្វើបច្ចុប្បន្នភាពឱ្យបានស្របជាមួយនឹងសកម្មភាពជាអាទិភាពនាពេលបច្ចុប្បន្ននៃវិស័យជលផល ដោយរួមទាំងក្របខ័ណ្ឌដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨។

រាជធានីភ្នំពេញថ្ងៃទី..........ខែ................ឆ្នាំ២០១៥

**ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ







# មាតិកា


**បុព្វកថា** ... ក

**ពាក្យចំព្រួញ** ... ង

**១. សេចក្តីផ្តើម** ... ១

**២. សមិទ្ធផលសម្រេចបាននៃវិស័យជលផលឆ្នាំ២០០៩-២០១៤** ... ៣

**៣. សក្តានុពលនិងបញ្ហាប្រឈមនៃវិស័យជលផលកម្ពុជា** ... ៧

- ការនេសាទនិងការគ្រប់គ្រង ... ៨
- វារីវប្បកម្ម៖ ទឹកសាបនិងសមុទ្រ ... ៩
- ខ្សែសង្វាក់ផលិតកម្មជលផល ... ១០
- ការធ្វើនិយតកម្មនិងសេវាកម្ម ... ១០

**៤. អភិក្រមជាយុទ្ធសាស្ត្រនៃវិស័យជលផល** ... ១៣

- ទស្សនវិស័យសម្រាប់វិស័យជលផល ... ១៣
- ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនិងក្របខ័ណ្ឌគោលនយោបាយទូលំទូលាយ ... ១៤
- យុទ្ធសាស្ត្រវិស័យជលផលផ្តោតការយកចិត្តទុកដាក់ ... ១៨
- ការនេសាទនិងការគ្រប់គ្រង ... ២១
- វារីវប្បកម្មទឹកសាបនិងសមុទ្រ ... ២៨
- ខ្សែសង្វាក់ផលិតកម្មជលផល ... ៣២
- ការធ្វើនិយតកម្មនិងសេវាកម្ម ... ៣៦

**៥. ការអនុវត្តអភិក្រមជាយុទ្ធសាស្ត្រ** ... ៤១

- អភិក្រមផ្អែកតាមកម្មវិធី ... ៤១
- ការសម្របទៅនឹងការប្រែប្រួល ... ៤២









ការចាត់អាទិភាពតាមគោលការណ៍អភិវឌ្ឍន៍....................................................................................................................៤២

១. កសាងភាពធន់ទ្រាំតាមរយៈការរៀបចំផែនការដែលអាចបត់បែននិងសម្របតាមកាលៈទេសៈ.................៤៣

២. ផ្អែកលើភស្តុតាងដែលមានមូលដ្ឋានជាក់លាក់ ការទទួលខុសត្រូវនិងតម្លាភាព..................................៤៣

៣. ប្រតិបត្តិការនៅគ្រប់កម្រិត.............................................................................................................៤៤

៤. ដោះស្រាយនូវភាពប្រទាំងប្រទើសរវាងគោលដៅនានានិងធានាបាននូវភាពប្រទាក់ក្រឡាគ្នា...................៤៥

៥. ធានាបាននូវនិរន្តរភាពនៃមុខងាររបស់ប្រព័ន្ធអេកូឡូស៊ី.............................................................៤៦

៦.លើកកម្ពស់សិទ្ធិស្របច្បាប់និងការទទួលខុសត្រូវរបស់សហគមន៍និងបុគ្គលនីមួយៗ.............................៤៦

៧. ដោះស្រាយនូវតម្រូវការនិងឆ្លើយតបទៅតាមបំណងប្រាថ្នារបស់សហគមន៍.........................................៤៧

៨. ស្វែងយល់អំពីភាពពឹងអាស្រ័យនៅក្នុងវិស័យនិងធ្វើឱ្យមានតុល្យភាពជាមួយនឹងជម្រើសមុខរបរ.............៤៧

៩. គិតគូរអំពីការចំណាយនិងផលចំណេញ ដោយរក្សាបាននូវនិរន្តរភាពនិងសមធម៌..............................៤៨

១០. ការកសាងសមត្ថភាព...........................................................................................................៤៩

**ឧបសម្ព័ន្ធ១៖** បរិយាកាសគោលនយោបាយដែលមានឥទ្ធិពលដល់ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិស័យ
ជលផលឆ្នាំ២០១៥-២០២៤.........................................................................................................៥៤

គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព.......................................................................................៥៤

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ សម្រាប់កំណើនការងារ សមធម៌ និងប្រសិទ្ធភាព......................៥៧

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ .............................................................................៥៩

ទស្សនវិស័យសម្រាប់ឆ្នាំ២០៣០ និងការអភិវឌ្ឍន៍បៃតង ..........................................................................៦១

គោលនយោបាយស្តីពី ការប្រែប្រួលអាកាសធាតុ ...........................................................................៦២

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ..............................................................................៦៣

**ឧបសម្ព័ន្ធ២៖** ការណែនាំអំពីសូចនាករនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនិងចំណុចដៅ...៦៤








# ពាក្យបំព្រួញ

| | |
|---|---|
| ASDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន |
| CamCode | ក្រមប្រតិបត្តិជលផលកម្ពុជា (កាំកូដ) |
| CCCSP | ផែនការយុទ្ធសាស្ត្រស្តីពី ការប្រែប្រួលអាកាសធាតុកម្ពុជា |
| CCRF | ក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវនៃវិស័យជលផល |
| CFi | សហគមន៍នេសាទ |
| CFR | ស្រះជម្រកត្រីសហគមន៍ |
| CITES | អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ |
| EU | សហគមន៍អឺរ៉ុប |
| FAO | អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ |
| FiA | រដ្ឋបាលជលផល |
| GDP | ផលិតផលសរុបក្នុងស្រុក |
| GGMP | ផែនការមេនៃការអភិវឌ្ឍបៃតង |
| GMP | ការអនុវត្តអនាម័យល្អក្នុងផលិតកម្ម |
| HACCP | ការវិភាគអំពីសារជាតិគ្រោះថ្នាក់ និងចំណុចចាំបាច់ត្រូវត្រួតពិនិត្យ |
| ILO | ការិយាល័យពលកម្មអន្តរជាតិ |
| IPOA | ផែនការសកម្មភាពអន្តរជាតិ |
| IUU | ការធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត |







| | |
|---|---|
| JMI | សូចនាករតាមដានរួមគ្នា |
| M&E | ការតាមដាននិងការវាយតម្លៃ |
| MARPOL | អនុសញ្ញាអន្តរជាតិឆ្នាំ១៩៧៣ សម្រាប់ការការពារជាតិពុលដែលបណ្តាលមកពីនាវា ដោយត្រូវបានកែសម្រួលដោយពិធីសារឆ្នាំ១៩៧៨ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MRC | គណៈកម្មការទន្លេមេគង្គ |
| NADS | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីវប្បកម្មជាតិ |
| NGGR | ផែនទីបង្ហាញផ្លូវនៃការអភិវឌ្ឍន៍បៃតង |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PBA | អភិក្រមផ្អែកតាមកម្មវិធី |
| REDD | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងការរេចរឹលព្រៃឈើ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS III | យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព |
| SEAFDEC | មជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលតំបន់អាស៊ីអាគ្នេយ៍ |
| SPF | ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល |
| SPS | អនាម័យនិងភូតគាមអនាម័យ |
| TWGFi | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់វិស័យជលផល |
| UNCLOS | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ |

















# ១

# សេចក្តីផ្តើម

វិស័យជលផល គឺជាវិស័យមួយដ៏មានសារៈសំខាន់យ៉ាងខ្លាំងចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ ត្រូវបានរៀបចំឡើង ដើម្បីគ្រប់គ្រងវិស័យជលផលដោយផ្តល់នូវប្រយោជន៍ដ៏ច្រើនបំផុត និងធានាបាននូវនិរន្តរភាពនៃការរួមចំណែក ចំពោះការអភិវឌ្ឍជាតិ។ នេះគឺជាផ្នែកមួយនៃអភិក្រមផ្អែកលើកម្មវិធីដ៏ទូលំទូលាយមួយសម្រាប់ការគ្រប់គ្រងវិស័យ ដែលត្រូវបានរៀបចំឡើងដើម្បីជាមគ្គុទេសក៍ដល់ការជួយគាំទ្ររបស់ម្ចាស់ជំនួយឱ្យបានស្របជាមួយនឹងផែនការអាទិភាព និងគោលដៅអភិវឌ្ឍន៍ជាតិ ហើយដើម្បីធ្វើសមាហរណកម្មសមាសភាពផ្សេងៗនៅក្នុងវិស័យជលផលទៅក្នុងយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដែលស្របនឹងដំណើរការនៃការអភិវឌ្ឍដ៏ទូលំទូលាយ។ អភិក្រមផ្អែកលើកម្មវិធីរបស់វិស័យជលផលនៅកម្ពុជា គឺជាកម្មវិធីមួយដែលត្រូវបានអនុវត្តនិងមានដំណើរការទទួលបានជោគជ័យ ជាក់ស្តែងដូចជាការកើនឡើងនូវប្រសិទ្ធភាពនៃជំនួយចំពោះវិស័យនិងការគាំទ្រ ក៏ដូចជាការពង្រឹងនូវភាពជាម្ចាស់នៅក្នុងដំណើរការអភិវឌ្ឍ។

ឯកសារនេះ ត្រូវបានរៀបចំឡើង ដើម្បីកែសម្រួលឱ្យកាន់ប្រសើរឡើងនូវខ្លឹមសាររបស់ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យជលផលនៅកម្ពុជានិងធ្វើបច្ចុប្បន្នភាពដើម្បីឆ្លើយតបទៅនឹងគោលនយោបាយនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថាននៅក្នុងប្រទេសនិងនៅក្នុងតំបន់។

ការជះឥទ្ធិពលពីកត្តាខាងក្រៅមកលើវិស័យជលផល គឺប្រែប្រួលពីមួយពេលទៅមួយពេល ដូចនេះក្របខ័ណ្ឌគោលនយោបាយជាតិត្រូវមានការវិវដ្ត ដើម្បីឆ្លើយតបបានទៅនឹងការជះឥទ្ធិពលដែលកើតមានឡើងមកលើប្រទេសជាតិ សេដ្ឋកិច្ច និងប្រជាពលរដ្ឋ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ បានកំណត់នូវរចនាសម្ព័ន្ធយ៉ាងសំខាន់ថ្មីមួយសម្រាប់ការអភិវឌ្ឍ ក្នុងនោះក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលចាំបាច់ត្រូវរៀបចំឡើងឱ្យបានសមស្រប និងផ្តល់នូវបរិបទជលផលយូរអង្វែងសម្រាប់ជាមគ្គុទេសក៍ដល់ការអភិវឌ្ឍវិស័យជលផល។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រដែលបានធ្វើបច្ចុប្បន្នភាពនេះ (វគ្គទី៤) គឺមានរួមបញ្ចូលនូវគោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់វិស័យជលផល ដែលក្នុងនោះរដ្ឋាភិបាលបានសម្រេចលុបឡូតិ៍នេសាទចំនួន៨០បន្ថែមទៀត ដោយមួយចំនួនប្រគល់ទៅឱ្យសហគមន៍នេសាទធ្វើការគ្រប់គ្រង និងមួយចំនួនរក្សាទុកជាកន្លែងអភិរក្ស។ ការប្រែប្រួលទាំងនេះ រួមជាមួយនឹងការប្រែប្រួលផ្សេងទៀតដូចជាការ













ប្រែប្រួលអាកាសធាតុ ការពង្រីកសកម្មភាពផលិតថាមពលវារីអគ្គិសនី ការផ្លាស់ប្តូរតួនាទីរបស់អន្តរជាតិ និងការបង្កើនការយកចិត្តទុកដាក់ចំពោះសិទ្ធិស្ត្រី ការគិតគូរដល់កុមារនិងអ្នកក្រីក្រនៅក្នុងដំណើរការអភិវឌ្ឍ គឺចាំបាច់ត្រូវធ្វើការកែសម្រួលក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឱ្យបានសមស្របតាមគោលដៅ នៅក្នុងឆ្នាំខាងមុខ។ ការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ គឺដើម្បីដោះស្រាយនូវការប្រែប្រួលទាំងនេះនៅក្នុងបរិបទសមស្របនិងផ្តល់នូវក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍវិស័យជលផលក្នុងរយៈពេល១០ឆ្នាំខាងមុខ។

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវគ្គទី៤នេះ គឺចាប់ផ្តើមពីការលើកឡើងនូវចំណុចសំខាន់ៗនៃវិស័យជលផលនៅកម្ពុជានិងការរីកចម្រើនដែលសម្រេចបានជាង៥ឆ្នាំកន្លងទៅនេះ គឺចាប់តាំងពីពេលក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ ត្រូវបានរៀបចំឡើងតាំងពីដំបូង។ បន្ទាប់មក គឺពិនិត្យមើលឡើងវិញនូវសក្តានុពលនៃវិស័យជលផលនិងបញ្ហាប្រឈមដែលជួបប្រទះ។ នៅក្នុងជំពូកទី៣ គឺរៀបរាប់អំពីអភិក្រមជាយុទ្ធសាស្ត្រសម្រាប់វិស័យជលផលក្នុងរយៈពេល១០ឆ្នាំខាងមុខ។ នេះគឺ ផ្អែកលើទស្សនវិស័យសម្រាប់វិស័យជលផល ក្របខ័ណ្ឌគោលនយោបាយដ៏ទូលំទូលាយដែលគ្របដណ្តប់លើវិស័យជលផល (មានការពិភាក្សាលម្អិតបន្ថែមនៅក្នុងឯកសារឧបសម្ព័ន្ធ១) និងផ្នែកសំខាន់ៗដែលត្រូវគិតគូរជាយុទ្ធសាស្ត្រសម្រាប់វិស័យ។ ធាតុសំខាន់ៗដែលត្រូវគូសបញ្ជាក់អំពីអភិក្រមជាយុទ្ធសាស្ត្រគឺផ្អែកលើសសរស្តម្ភនៃការអភិវឌ្ឍចំនួន៤គឺ: ១).ការនេសាទ[១]និងការគ្រប់គ្រង ២). វារីវប្បកម្ម (ទឹកសាបនិងសមុទ្រ) ៣) .តម្លៃសង្វាក់ផលិតកម្មជលផល ៤). និយតកម្មនិងសេវាកម្ម។ ជំពូកទី៤ គឺលើកឡើងអំពីវិធីសាស្ត្រនិងគោលការណ៍សម្រាប់អនុវត្តនូវក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ។

---

*[១] ជលផលរួមទាំងត្រី វារិសត្វ និងវារីរុក្ខជាតិដទៃទៀត ដែលប្រើប្រាស់សម្រាប់ម្ហូបអាហារ ជួញដូរ និងជាធាតុចូលសម្រាប់សកម្មភាពផ្សេងទៀត។ វារីសត្វផ្សេងទៀតរួមចំណែកជាច្រើននៅក្នុងផលនេសាទ ហើយមានសក្តានុពលសម្រាប់ការអភិវឌ្ឍន៍វារីវប្បកម្ម។ លើសពីនេះ ច្បាប់ស្តីពីជលផលកម្ពុជានៅជំពូក១មាត្រា២បានចែងថាច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិទាំងជលផលកែច្នៃនិងទាំងវារីវប្បកម្ម។*







# ២

# សមិទ្ធផលសម្រេចរបស់វិស័យ ជលផលឆ្នាំ ២០០៩-២០១៤

ធនធានជលផលកម្ពុជា គឺជាធនធានមួយដ៏ធំទូលាយនិងមានលក្ខណៈជីវសាស្ត្រសម្បូរបែបបំផុតនៅក្នុងពិភពលោក ដោយប្រមាណជាង៣០%នៃផ្ទៃប្រទេស គឺជាតំបន់ដីសើមជាអចិន្ត្រៃយ៍ ឬតាមរដូវកាល។ វិស័យជលផលបានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់នូវមុខរបរនិងជីវភាពរស់នៅដល់អ្នកក្រីក្រ ផ្តល់នូវសន្តិសុខស្បៀង រួមចំណែកដល់ផលិតផលសរុបក្នុងស្រុក និងរក្សានូវតុល្យភាពនៃការដោះដូររូបិយវត្ថុអន្តរជាតិ។

អភិបាលកិច្ចល្អ គឺជាស្នូលនៃការសម្រេចបាននូវយុត្តិធម៌សង្គម និរន្តរភាព និងការអភិវឌ្ឍប្រកបដោយសមធម៌នៅកម្ពុជា។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយកំណែទម្រង់វិស័យជលផលក្នុងគោលបំណងលើកកម្ពស់នេសាទទ្រង់ទ្រាយតូច។ គោលដៅចុងក្រោយនៃកម្មវិធីកំណែទម្រង់វិស័យជលផល គឺដើម្បីពង្រឹងសមត្ថភាព ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ ដើម្បីកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋមូលដ្ឋានចំពោះរដ្ឋាភិបាល និងដើម្បីឆ្លើយតបចំពោះតម្រូវការនិងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋនិងសហគមន៍មូលដ្ឋាន។

ក្នុងកំណែទម្រង់នេះ រាជរដ្ឋាភិបាលបានសម្រេចលុបឡូតិ៍នេសាទបឹងព្រែកទាំងអស់ ហើយប្រគល់ទៅឱ្យសហគមន៍នេសាទគ្រប់គ្រងនិងធ្វើនេសាទទ្រង់ទ្រាយតូច។ រដ្ឋបាលជលផលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធដោយរៀបចំសហគមន៍នេសាទបានចំនួន៥១៦ ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តរភាព។ ក្នុងចំណោមសហគមន៍នេសាទដែលបានរៀបចំ មានសហគមន៍នេសាទចំនួន៤៧៧ ស្ថិតនៅក្នុងតំបន់ទឹកសាប និង៣៩ស្ថិតនៅក្នុងតំបន់ឆ្នេរ ហើយមានសមាជិកចូលរួមសរុបចំនួន១៥៦.៦២៨ គ្រួសារ ស្មើនឹង៣៣២.១៦៨នាក់ ក្នុងនោះស្ត្រីមានចំនួនប្រមាណ៣៣%។ បច្ចុប្បន្នមានសហគមន៍នេសាទចំនួន៣២៨ ត្រូវបានចុះបញ្ជីជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បន្ទាប់ពីបានលប់ឡូតិ៍នេសាទនៅក្នុងដំណាក់កាលទី២នៃកំណែទម្រង់វិស័យជលផលរួចមក តំបន់អភិរក្សចំនួន៥០ត្រូវបានបង្កើតឡើងថែមទៀត ការបង្កើតតំបន់អភិរក្សទាំងនេះគឺដើម្បីធានាបាននូវនិរន្តរភាពនៃធនធានជលផល និងរក្សាបាននូវជីវសាស្ត្រនិងប្រព័ន្ធអេកូឡូស៊ីឱ្យល្អប្រសើរ។ តំបន់អភិរក្សជលផលចំនួន៨ ដែលមានទំហំ២២.៥០០







ហិកតា គឺបានបង្កើតឡើងតាំងពីមុនពេលការកែទម្រង់វិស័យជលផល ហើយបន្ទាប់មកតំបន់អភិរក្សជាច្រើនដែលមានទំហំសរុប៩៧.៥០៣ហិកតា ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។ រដ្ឋបាលជលផលបានសហការយ៉ាងជិតស្និទ្ធជាមួយសហគមន៍មូលដ្ឋានដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមដាំព្រៃលិចទឹកឡើងវិញ ហើយគិតមកដល់បច្ចុប្បន្នព្រៃលិចទឹកចំនួន២.២០០ ហិកតា ត្រូវបានដាំដុះឡើងវិញ។ ទន្ទឹមនឹងនេះ សហគមន៍ដែលស្ថិតនៅតាមបណ្ដោយតំបន់ឆ្នេរក៏បានចូលរួមក្នុងកម្មវិធីលែងកូនក្ដាមដើម្បីធានានូវនិរន្តរភាពផលស្ដុកក្ដាមធម្មជាតិ។ ធនាគារក្ដាមចំនួន៣៤កន្លែងត្រូវបានបង្កើតឡើង ក្នុងនោះមានបែដាក់ក្ដាមសរុបចំនួន៩៥បែ។ តាមរយៈកម្មវិធីលែងក្ដាមនេះ គឺបានធ្វើឱ្យផលស្ដុកក្ដាមកើនឡើងគួរឱ្យកត់សម្គាល់។ លើសពីនេះ ប្រភេទត្រីជិតផុតពូជជាច្រើននិងទីជម្រកជាច្រើនត្រូវបានថែរក្សាយ៉ាងល្អ ក្នុងនោះរួមមានសត្វផ្សោត ផ្កាថ្ម ស្មៅសមុទ្រ សេះសមុទ្រ និងអណ្ដើកសមុទ្រ។

ភាពជោគជ័យនៃកំណែទម្រង់វិស័យជលផលតាមរយៈការបង្កើតសហគមន៍នេសាទនៅកម្ពុជា ត្រូវបានទទួលនូវការយកចិត្តទុកដាក់ពីថ្នាក់តំបន់និងអន្តរជាតិ ជាក់ស្ដែងសិក្ខាសាលាថ្នាក់អាស៊ានបានចាប់អារម្មណ៍និងលើកឡើងពីបទពិសោធន៍និងភាពជោគជ័យនេះ។

ស្របជាមួយនឹងដំណើរការនៃការគ្រប់គ្រងសហគមន៍នេសាទ ក៏ដូចជាការអភិរក្សធនធានជលផល រដ្ឋបាលជលផលក៏បានផ្ដល់នូវសេវាកម្មបង្ក្រាបបទល្មើសនេសាទនិងការពារព្រៃលិចទឹក ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិផងដែរ ហើយក៏បានសហការជាមួយនឹងសមត្ថកិច្ចផ្សេងទៀត ដូចជាភ្នាក់ងារនគរបាល យោធា អាជ្ញាធរស្រុក និងខេត្តក្នុងការបំពេញការងារនេះបានយ៉ាងល្អ។

វិស័យជលផលនៅតែបន្តនូវតួនាទីដ៏មានសារៈសំខាន់ចំពោះសន្តិសុខស្បៀងជាតិ និងផ្ដល់នូវការងារនិងប្រាក់ចំណូលសម្រាប់ប្រជាពលរដ្ឋនៅជនបទជាច្រើន។ ក្នុងឆ្នាំ២០១៣ ការប៉ាន់ស្មានផលនេសាទទឹកសាបសរុបមានចំនួន៥៥០.០០០តោន (រួមទាំងនេសាទវាលស្រែផងដែរ) និងនេសាទសមុទ្រមានចំនួន១០០.០០០តោន។ លើសពីនេះ ផលិតផលវារីវប្បកម្មសម្រេចបានចំនួន៨០.០០០តោន គឺមានការកើនឡើងចំនួន៧.៥% ប្រៀបធៀបនឹងឆ្នាំ២០១២(តារាងទី១)។ ជារួម ផលិតផលជលផលសរុបទាំងផលនេសាទពីធម្មជាតិនិងផលចិញ្ចឹម គឺមានការកើនឡើងច្រើនជាង៤០% គិតចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ ក្នុងនោះកំណើនគិតជាមធ្យម គឺមានប្រមាណ១០% ក្នុង១ឆ្នាំ។














ការកើនឡើងនូវផលនេសាទទឹកសាប គឺកើតឡើងដោយសារការអនុវត្តយុទ្ធសាស្ត្រនានា រួមមានការបង្កើនធនធានជលផលតាមវាលស្រែនិងការបង្កើតស្រះជម្រកត្រីសហគមន៍[២]។ រដ្ឋបាលជលផលបានខិតខំជំរុញការបង្កើតស្រះជម្រកត្រីសហគមន៍ ជាលទ្ធផល គឺសម្រេចបានចំនួន៨២០ នៅទូទាំងប្រទេស ដែលធ្វើឱ្យផលនេសាទតាមវាលស្រែមានការកើនឡើង។

តារាងទី១. ផលិតផលជលផលទឹកសាប និងសមុទ្រ គិតជាតោនសម្រាប់ឆ្នាំ២០០៩-២០១៤

| ប្រភេទ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|
| នេសាទទឹកសាប | ៣៩០.០០០ | ៤០៥.០០០ | ៤៤៥.០០០ | ៥០៩.០០០ | ៥៥០.០០០ | ៥០៥.០០០ |
| នេសាទសមុទ្រ | ៧៥.០០០ | ៨៥.០០០ | ៩១.០០០ | ៩៩.០០០ | ១០០.០០០ | ១២០.០០០ |
| វារីវប្បកម្ម | ៥០.០០០ | ៦០.០០០ | ៧២.០០០ | ៧៤.០០០ | ៨០.០០០ | ១២០.០០០ |
| សរុប | ៥១៥.០០០ | ៥៥០.០០០ | ៦០៨.០០០ | ៦៨២.០០០ | ៧៣០.០០០ | ៧៤៥.២៥៥ |

ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការអភិវឌ្ឍវារីវប្បកម្មរួមមានត្រី ក្រពើ និងបង្កង។ វិស័យនេះបានបង្ហាញពីការលូតលាស់ គួរឱ្យកត់សម្គាល់នៅក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ពោលគឺផលិតផលវារីវប្បកម្មបានកើនឡើងពី ៥០.០០០តោន នៅក្នុងឆ្នាំ២០០៩ ដល់ ១២០.០០០តោន ក្នុងឆ្នាំ២០១៤។ កាលពីពេលកន្លងទៅ ទោះបីជាការយកចិត្តទុកដាក់គឺផ្តោតលើប្រព័ន្ធផលិតកម្មខ្នាតតូចក៏ដោយ ប៉ុន្តែបច្ចុប្បន្នគឺមានការគិតគូរអំពីសក្តានុពលនៃប្រព័ន្ធផលិតកម្មជាលក្ខណៈពាណិជ្ជកម្ម ដើម្បីរក្សាបាននូវបរិមាណផលត្រីសម្រាប់ផ្គត់ផ្គង់គ្រប់គ្រាន់។ ជាក់ស្តែងការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍវារីវប្បកម្មទ្រង់ទ្រាយធំទាំងនៅតំបន់ឆ្នេរនិងតំបន់ទឹកសាប គឺបានផ្តល់នូវលទ្ធផលបានយ៉ាងល្អប្រសើរ។

---

[២] *ការនេសាទតាមវាលស្រែ គឺយោងទៅលើការនេសាទត្រី និងវារីសត្វដទៃទៀតពីវាលស្រែលិចទឹក និងប្រព័ន្ធប្រឡាយ និងព្រែកនានា*













ទោះបីជាការកែច្នៃផលនេសាទ ធ្លាប់ត្រូវបានអនុវត្តជាទំនៀមទំលាប់នៅក្នុងវិស័យឯកជនតាំងពីយូរយារមកហើយក៏ដោយ ប៉ុន្តែការគាំទ្រចំពោះផ្នែកនេះ គឺជាកិច្ចការថ្មីមួយដែលរដ្ឋបាលជលផលកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ននេះ។ កិច្ចការនេះ គឺពាក់ព័ន្ធជាមួយនឹងការគិតគូរអំពីគុណភាពនៃផលិតផលត្រី ការផលិត ការទុកដាក់ និងការប្រើប្រាស់តាមស្តង់ដារនិងការជំរុញការផ្គត់ផ្គង់ទីផ្សារក្នុងស្រុកនិងនាំចេញទៅទីផ្សារក្រៅស្រុក។ រដ្ឋបាលជលផលបានគាំទ្រដល់ការបង្កើតសមាគមកែច្នៃផលនេសាទបានចំនួន១៦សមាគម និងបានបង្កើតនូវផលិតផលស្តង់ដារចំពោះផលិតផលសំខាន់ៗមួយចំនួន ដូចជាប្រហុក ត្រីងៀត ត្រីរ៉ស់/ត្រីឆ្តោ និងបង្គាបង្កង។ លើសពីនេះរដ្ឋបាលជលផលបានជំរុញឱ្យមានការវិភាគទៅលើផលិតផលដែលបង្កគ្រោះថ្នាក់ចំពោះសុខភាព និងចំណុចដែលត្រូវត្រួតពិនិត្យជាចាំបាច់ ដែលសរសេរកាត់ជាអក្សរឡាតាំងថា (HACCP) និងស្តង់ដារគុណភាព និងសុវត្ថិភាពផ្សេងទៀតចំពោះរាល់គ្រប់ផលផលិតផលជលផលទាំងអស់។ រដ្ឋបាលជលផលសហការជាមួយស្ថាប័នផ្សេងទៀត ដើម្បីស្នើសុំឱ្យផ្តល់នូវឧបករណ៍និងសេវាកម្មពិសោធន៍ដ៏មានប្រសិទ្ធភាព សម្រាប់វិភាគរកបាក់តេរីនៅក្នុងត្រី ដើម្បីធានាបាននូវគុណភាពជាស្តង់ដារសម្រាប់ការនាំចេញ។

កិច្ចខិតខំប្រឹងប្រែងសម្រាប់ការអភិវឌ្ឍនេះ គឺត្រូវបានគាំទ្រដោយការស្រាវជ្រាវរបស់វិទ្យាស្ថានសំខាន់ៗចំនួន ៣ គឺ ១). វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍជលផលទឹកសាប ២). វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍជលផលសមុទ្រ និង ៣). វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្ម។ សកម្មភាពស្រាវជ្រាវនេះ បានផ្តល់នូវភ័ស្តុតាងដើម្បីគាំទ្រដល់ការរៀបចំនិងអនុវត្តនូវគោលនយោបាយ។

វិស័យជលផលនៅកម្ពុជាក៏ជាផ្នែកមួយនៃជលផលនៅក្នុងតំបន់អាងទន្លេមេគង្គផងដែរ ហើយកម្ពុជាធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងគណៈកម្មការទន្លេមេគង្គតាមរយៈកម្មវិធីជលផល និងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដើម្បីសម្រេចបាននូវសុខដុមនីយកម្មជាមួយនឹងបណ្តាប្រទេសជិតខាង។







៣

# សក្ដានុពលនិងបញ្ហាប្រឈមនៃវិស័យជលផលនៅកម្ពុជា

វិស័យជលផលរបស់កម្ពុជាមានចំណុចខ្លាំងជាច្រើន ដូចដែលបានចែងនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០០៩។ ចំណុចខ្លាំងទាំងនោះរួមមាន ធនធានជលផលមានវិសាលភាពយ៉ាងធំធេងនៅក្នុងបឹងទន្លេសាប ដងទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរសមុទ្រ។ លើសពីនេះ កម្ពុជាមានផ្ទៃដីធំទូលាយដែលមានលក្ខណៈសមស្របជាមួយនឹងវារីវប្បកម្មទាំងទ្រង់ទ្រាយតូចនិងទ្រង់ទ្រាយធំសម្រាប់ពាណិជ្ជកម្ម។ កម្ពុជាមានប្រជានេសាទ អ្នកកែច្នៃផលនេសាទ និងអ្នកជួញដូរផលនេសាទប្រកបដោយជំនាញនិងសកម្ម។ អ្នកទាំងនេះបានបង្ហាញពីឆន្ទៈនិងលទ្ធភាពក្នុងការចូលរួមចំណែកដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងសហគមន៍នេសាទ។ លើសពីនេះ រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងសមស្រប និងមានសមត្ថភាពល្អ ហើយបានបំពេញការងារក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យជលផលទទួលបានលទ្ធផលល្អប្រសើរ។ សមិទ្ធផលសម្រេចបានទាំងនេះ គឺកើតឡើងពីការបំពេញការងារក្នុងភាពជាដៃគូរួមគ្នាយ៉ាងទូលំទូលាយជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានា។

របាយការណ៍ស្តីពីផលនេសាទបានបង្ហាញពីការកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងទៅថ្មីៗនេះ។ បច្ចុប្បន្ននេះមានការទទួលស្គាល់ថា ទោះបីជានៅមានលទ្ធភាពអាចធ្វើឱ្យផលនេសាទកើនឡើងតាមរយៈការពង្រឹងការគ្រប់គ្រងឱ្យបានល្អប្រសើរក៏ដោយ ប៉ុន្តែមានកត្តាអភិវឌ្ឍន៍ដទៃទៀតដែលធ្វើឱ្យវិស័យជលផលមានការលំបាកក្នុងការរក្សាផលនេសាទប្រចាំឆ្នាំឱ្យមាននិរន្តរភាពក្នុងកម្រិត៦០០.០០០តោន ពីគ្រប់ប្រភពទាំងនេសាទទឹកសាបនិងនេសាទសមុទ្រ។

ទោះបីជានៅកម្ពុជាមានលទ្ធភាពអាចធ្វើឱ្យផលនេសាទទឹកសាបកើនឡើងនៅថ្ងៃអនាគតក៏ដោយ ប៉ុន្តែការបង្កើននេះត្រូវមានការសិក្សាស្រាវជ្រាវបន្ថែមទៀត។ ចំពោះបញ្ហានេះ មានការរំពឹងថាវារីវប្បកម្មនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាបាននូវការផ្គត់ផ្គង់ផលត្រីនៅក្នុងឆ្នាំខាងមុខ។ ការរៀបចំស្រះជម្រកត្រីសហគមន៍ គឺជាផ្នែកមួយនៃកម្ម-













វិធីដ៏ទូលំទូលាយក្នុងការធ្វើឱ្យមានការកើនឡើង និងរក្សានូវនិរន្តរភាពផលនេសាទតាមវាលស្រែ ហើយវាមានតួនាទីយ៉ាងសំខាន់ក្នុងការបំពេញបន្ថែមនូវផលត្រីក្នុងរដូវខ្សត់ត្រី។

លើសពីនេះ វិស័យជលផលក៏មានសក្តានុពលក្នុងការបង្កើននូវតួនាទីរបស់ខ្លួនក្នុងការរួមចំណែកដល់សេដ្ឋកិច្ចជាតិតាមរយៈការធ្វើឱ្យបានប្រសើរនូវខ្សែសង្វាក់ផលិតផលជលផល។ ការពង្រីកទីផ្សារថ្នាក់តំបន់និងការកើនឡើងតម្រូវការទាំងក្នុងស្រុកនិងការនាំចេញ គឺជាសក្តានុពលសម្រាប់ការលូតលាស់នៃវិស័យជលផល។ ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការបង្កើននូវការត្រួតពិនិត្យគុណភាពកែច្នៃនៅក្នុងវិស័យជលផល គឺអាចបង្កើនបាននូវភាពទុកចិត្តពីទីផ្សារចំពោះផលិតផលកម្ពុជាប៉ុន្តែការពង្រឹងវិធានការអនាម័យល្អគឺជាកត្តាចាំបាច់។ ក្រៅពីនេះ ខ្សែសង្វាក់ផលិតកម្មអាចធ្វើឱ្យប្រសើរឡើងបានតាមរយៈការស្វែងរកទីផ្សារល្អ ការធ្វើឱ្យប្រសើរឡើងនូវធាតុចូល ការលើកកម្ពស់ការប្រើប្រាស់សាច់ត្រី និងប្រសិទ្ធភាពនៃការដឹកជញ្ជូននិងប្រព័ន្ធរក្សាទុក។

ទោះបីជាយ៉ាងនេះក្តី វិស័យជលផលក៏ជួបប្រទះនូវបញ្ហានិងការគំរាមកំហែងផងដែរ។ ការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជននិងជាមួយនឹងមន្ត្រីនៅថ្នាក់ខណ្ឌរដ្ឋបាលជលផល និងយោងទៅលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺបានកំណត់នូវបញ្ហាប្រឈមមួយចំនួនចំពោះវិស័យជលផល។ បញ្ហាប្រឈមទាំងនោះអាចគូសបញ្ជាក់នៅក្នុងសសរស្តម្ភទាំង៤នៃវិស័យជលផល។

## ការនេសាទនិងការគ្រប់គ្រង

- សហគមន៍នេសាទពុំមានថវិកា ឬសមត្ថភាពក្នុងការអនុវត្តនូវផែនការសកម្មភាពរបស់ខ្លួនបានឡើយ ហើយសមាជិកសហគមន៍នេសាទភាគច្រើន គឺជាអ្នកក្រីក្រ។ សហគមន៍នេសាទមួយចំនួនពុំមានការអភិវឌ្ឍសហគមន៍របស់ខ្លួនគ្រប់គ្រាន់ ហើយការគ្រប់គ្រងនៅមានភាពទន់ខ្សោយ។
- ការពង្រីកសកម្មភាពពាណិជ្ជនីយកម្មកសិកម្ម គឺបានបង្កើនទាំងការប្រើប្រាស់ជីគីមីទៅលើវាលស្រែនិងធ្វើឱ្យមានការផ្លាស់ប្តូរលក្ខណៈរូបរបស់វាលស្រែ ជាហេតុបណ្តាលឱ្យប៉ះពាល់ដល់សក្តានុពលនៃធនធានជលផលតាមវាលស្រែ។













- ការនេសាទខុសច្បាប់នៅតែកើតមានច្រើននៅឡើយ។
- ការកាប់បំផ្លាញព្រៃលិចទឹកនិងព្រៃកោងកាងបណ្ដាលឱ្យប៉ះពាល់ដល់ទីជម្រកនៅតំបន់ទឹកសាប និងតំបន់ឆ្នេរសមុទ្រ ។
- ការរំលោភយកទីជម្រកនៅតំបន់ឆ្នេរសមុទ្រធ្វើជាកន្លែងអភិវឌ្ឍន៍ ជាពិសេសគឺធ្វើជាទីក្រុង។
- ការធ្វើអាជីវកម្មបូមខ្សាច់ និងក្រួសដែលធ្វើឱ្យប៉ះពាល់ដល់ទន្លេ និងតំបន់ឆ្នេរសមុទ្រ។
- ការសាងសង់ទំនប់វារីអគ្គិសនីនៅទន្លេមេគង្គនិងដៃរបស់វា ដែលបង្កនូវផលអវិជ្ជមានដល់ធនធានជលផល។
- ការជះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុមកលើធនធានជលផលបានកើតមានយ៉ាងពិតប្រាកដ ប៉ុន្តែភាគច្រើនមិនទាន់យល់ដឹងឱ្យបានច្បាស់នៅឡើយ។

## វារីវប្បកម្ម៖ ទឹកសាបនិងសមុទ្រ

- ការលើកទឹកចិត្តចំពោះការវិនិយោគលើការអភិវឌ្ឍវារីវប្បកម្ម គឺមិនទាន់មានភាពទូលំទូលាយ ហើយលិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងប្រព័ន្ធផលិតកម្មនិងការផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់វារីវប្បកម្ម នៅមានភាពទន់ខ្សោយ។
- សកម្មភាពវារីវប្បកម្មខុសច្បាប់ ជាពិសេសសកម្មភាពពាក់ព័ន្ធនឹងការចិញ្ចឹមត្រីឆ្តោ នៅតែបន្តកើតមាន។
- ចំណេះដឹងជំនាញនិងបច្ចេកទេសពាក់ព័ន្ធនឹងផលិតកម្មវារីវប្បកម្មប្រភេទវារីសត្វសម្រាប់ពាណិជ្ជកម្ម ក៏ដូចជាការដោះស្រាយនូវបញ្ហាជំងឺ គឺនៅមានកម្រិតនៅឡើយ។
- ការគ្រប់គ្រងដីធ្លីនិងទឹកសម្រាប់ពង្រីកសកម្មភាពវារីវប្បកម្ម គឺនៅមានភាពទន់ខ្សោយ។
- ការផ្គត់ផ្គង់ចំណីនិងកូនត្រីពូជសម្រាប់វារីវប្បកម្ម នៅមានកម្រិតនិងគ្រប់គ្រងមិនបានល្អ។
- ការគ្រប់គ្រងការនាំចូលវត្ថុធាតុដើមសម្រាប់វិស័យនេះ មិនទាន់បានល្អ។







## ខ្សែសង្វាក់ផលិតកម្មជលផល

- តម្លៃអគ្គិសនីសម្រាប់បម្រើការងារវារីវប្បកម្មតាមបែបប្រពលវប្បកម្មនិងសម្រាប់ការកែច្នៃផលនេសាទ គឺមានតម្លៃខ្ពស់។
- កង្វះកិច្ចសហប្រតិបត្តិការឆ្លងដែនរវាងអ្នកពាក់ព័ន្ធសំខាន់ៗ និងកង្វះលិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មឆ្លងដែន។
- វិធានការអនាម័យនិងភូតគាមអនាម័យមិនត្រូវបានបញ្ចូលនៅក្នុងខ្សែចង្វាក់ផលិតកម្មឱ្យបានល្អ។ ហើយប្រព័ន្ធមន្ទីរពិសោធន៍សម្រាប់ធ្វើការពិសោធន៍សាកល្បង និងការចេញវិញ្ញាបនបត្របញ្ជាក់មិនបានរៀបចំល្អ។
- មានការលើកទឹកចិត្តតិចតួច ចំពោះវិស័យឯកជនក្នុងការចូលរួមសកម្មភាពកែច្នៃជាលក្ខណៈពាណិជ្ជកម្ម។
- ជំនាញបច្ចេកទេសកែច្នៃទំនើប គឺមានកម្រិតកំណត់ក្នុងចំណោមវិស័យឯកជននៅកម្ពុជា។ បណ្ដាប្រទេសជិតខាងបានបង្កើតប្រព័ន្ធផលិតកម្មនិងទីផ្សារ ដែលកម្ពុជាមានលទ្ធភាពតិចតួច ក្នុងការចូលដល់ទីផ្សារនោះ។

## ការធ្វើនិយតកម្មនិងសេវាកម្ម

- សកម្មភាពខុសច្បាប់នៅតែបន្តកើតមាន ជាពិសេសការប្រើឧបករណ៍ឆក់ត្រី ស្នៀមុង ការដាក់សម្រាស់[៣] ការកាប់ព្រៃលិចទឹកនៅក្នុងសហគមន៍នេសាទ និងនៅដែននេសាទសាធារណៈ និងការប្រើអួនអូសនៅតំបន់ឆ្នេរសមុទ្រ។
- ការយល់ដឹងអំពីច្បាប់និងផលប្រយោជន៍នៃការអនុវត្តច្បាប់នៅមានកម្រិត។
- ការអនុវត្តនិងការគោរពច្បាប់នៅមានកម្រិត និងខ្វះការយល់ដឹងអំពី សារៈសំខាន់នៃវិស័យជលផលក្នុងចំណោមអ្នកនេសាទ និងអ្នកពាក់ព័ន្ធនានា។
- ចំនួនមន្ត្រីដែលមានជំនាញនិងមានបទពិសោធន៍ច្បាស់លាស់ពុំគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាដែលកើតមានក្នុងវិស័យជលផលនាពេលបច្ចុប្បន្ន។
- ឧបករណ៍និងថវិកាសម្រាប់គាំទ្រដល់ការគ្រប់គ្រង ការស្រាវជ្រាវ ការផ្សព្វផ្សាយ ការអភិរក្ស និងការការពារធនធានជលផលនៅមានកម្រិត។

[៣] *សម្រាស់ គឺជាមធ្យោបាយដាក់ឱ្យត្រីកុំ ដើម្បីចាប់ត្រីដែលត្រូវបានធ្វើឡើងពីមែកឈើ*







ប្រព័ន្ធធារាសាស្ត្រ និងវារីអគ្គិសនីដែលមានស្រាប់ និងផែនការសាងសង់បន្ថែមនៅក្នុងប្រទេសកម្ពុជា នឹងជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅលើធនធានជលផល។ តម្រូវការនៃការផលិតថាមពលអគ្គិសនីនឹងកាន់តែកើនឡើង ដើម្បីបំពេញតម្រូវការប្រើប្រាស់នៅសហគ្រាសធុនតូច និងធុនមធ្យមដែលមានការលូតលាស់ដូចការរំពឹងទុកនៅក្នុងយុទ្ធសាស្ត្រចតុកោណ។

ការធ្វើទំនប់កាត់ទន្លេ និងស្ទឹងអាចបង្កឱ្យបាត់បង់ជីវចម្រុះ ប្រភេទត្រី និងទីជម្រក។ បញ្ហានេះមិនអាចទូទាត់បានដោយការធ្វើសន្និធិត្រីប្រភេទក្រៅស្រុកបានឡើយ ពីព្រោះវាធ្វើឱ្យប៉ះពាល់ដល់ប្រភេទត្រីក្នុងស្រុក និងបង្កឱ្យមានជំងឺកើតឡើង។ ការធ្វើសន្និធិប្រភេទត្រីក្នុងស្រុកដែលអាចធន់ទ្រាំនឹងការរស់នៅក្នុងបឹង គឺជាជម្រើសដ៏ល្អ ប៉ុន្តែជាលទ្ធផលគឺនាំឲ្យពពួកត្រីទាំងនោះនឹងមានភាពចម្រុះតិចទៅៗ ហើយការធ្វើសន្និធិត្រីនៅក្នុងអាងទឹកធំៗ គឺត្រូវការចំណាយច្រើន។ លើសពីនេះ ការធ្វើសន្និធិត្រីនៅក្នុងដែនទឹកមិនអាចជៀសផុតពីហានិភ័យ ពីព្រោះថាវាអាចធ្វើឱ្យប៉ះពាល់ដល់មុខងារនៃប្រព័ន្ធអេកូឡូស៊ី ជាហេតុបណ្តាលឱ្យមានការប្រែប្រួលលក្ខណៈរបស់ហ្វូងត្រី និងបាត់បង់សេនេទិករបស់វា។ ដូចគ្នានេះដែរ ការធ្វើវារីវប្បកម្មនៅក្នុងអាងទឹកនឹងជួបប្រទះនូវបញ្ហាបច្ចេកទេស ឧបករណ៍ប្រើប្រាស់និងការចំណាយច្រើន។ បញ្ហាទាំងនេះ គឺទាមទារការយល់ដឹងឱ្យច្បាស់និងការទូទាត់ឱ្យបានជាក់លាក់។

ផែនការអភិវឌ្ឍន៍ជាតិទទួលស្គាល់ថា លទ្ធផលដែលកើតចេញពីការប្រែប្រួលនៅកម្រិតថ្នាក់ជាតិ ដែលអាចមានឥទ្ធិពលដល់ប្រទេសជាតិទាំងមូលនៅក្នុងពេលអនាគត វាក៏មានឥទ្ធិពលមកលើវិស័យជលផលផងដែរ។ បញ្ហាទាំងនេះ រួមមានដំណើរការវិវឌ្ឍនៃប្រទេសកម្ពុជាឆ្ពោះទៅជាប្រទេសមួយដែលមានប្រាក់ចំណូលមធ្យម គឺធ្វើឱ្យកម្ពុជានឹងបាត់បង់ជំនួយថវិកាសម្រាប់ការអភិវឌ្ឍមួយចំនួន ជាមួយគ្នានេះដែរ កម្ពុជានឹងទទួលរងនូវឥទ្ធិពលនៃបញ្ហាអស្ថិរភាពនៃសេដ្ឋកិច្ចពិភពលោក ក៏ដូចជាការធ្វើសមាហរណកម្មនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលរួមមានការកាត់បន្ថយនូវរបាំងនៃការនាំចេញ នាំចូលរវាងជាតិនឹងជាតិ ការផ្ទេរជំនាញបច្ចេកទេសតាមរយៈប្រព័ន្ធអេឡិកត្រូនិច តម្រូវការនៃការវិនិយោគទៅលើធនធានមនុស្សសម្រាប់ការប្រកួតប្រជែងជាលក្ខណៈតំបន់ ភាពចាំបាច់ក្នុងការពង្រឹងរូបិយប័ណ្ណ និងតម្រូវការសម្រាប់បញ្ហាបរិយាកាសគោលនយោបាយប្រមូលផ្តុំ។ ការលើកទឹកចិត្តចំពោះការវិនិយោគខាងក្រៅតាមរយៈសហគមន៍សេដ្ឋកិច្ចអាស៊ាននឹងកើតមាននូវផលប៉ះពាល់ទាំងវិជ្ជមានផងនិងអវិជ្ជមានផង។ ការវិនិយោគធំៗពីបរទេសអាចជួយដល់វិស័យជលផលក្នុងការអភិវឌ្ឍ ប៉ុន្តែវាក៏អាចបង្កើតឡើងនូវការប្រកួតប្រជែងសម្រាប់កិច្ចការជំនួញនៅមូលដ្ឋានផងដែរ។ ដូចគ្នានេះដែរ ការកើនឡើងនូវការវិនិយោគ ចំពោះពលកម្មនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ អាចនឹងមានការជះឥទ្ធិពលដោយផ្ទាល់ពីការប្រកួតប្រជែងទៅលើតម្លៃ













សង្វាក់ផលិតផលជលផល។ ដើម្បីដោះស្រាយនូវបញ្ហានេះ គឺទាមទារឱ្យមានការចូលរួមពីវិស័យឯកជនដែលរឹងមាំច្រើនថែមទៀតនៅកម្ពុជា ជាពិសេស ការចូលរួមរបស់វិស័យឯកជននៅក្នុងវិស័យវារីវប្បកម្ម និងការកែច្នៃផលនេសាទ។ ជាទូទៅ ការវិនិយោគទុនរបស់វិស័យឯកជននៅកម្ពុជាតែងតែជួបប្រទះនូវការខ្វះខាតថាមពលអគ្គិសនី (ដំណោះស្រាយគឺការសាងសង់វារីអគ្គិសនី) ការយឺតយ៉ាវនូវដំណើរការនីតិវិធី និងការិយាល័យធិបតេយ្យនៅក្នុងប្រព័ន្ធរដ្ឋបាលរបស់រដ្ឋ ភាពទន់ខ្សោយនៃការទទួលបាននូវសេវាកម្មជំនួញ ពុំមានការលើកទឹកចិត្តឱ្យបានទូលំទូលាយចំពោះការវិនិយោគ និងមានភាពទន់ខ្សោយក្នុងការទទួលបាននូវសេវាឥណទានសមស្រប។

ការប្រែប្រួលអាកាសធាតុក៏ជាកត្តាគំរាមកំហែងដែលកើតមានឡើងមិនបានដឹងជាមុន ដែលធ្វើឱ្យមានការប្រែ - ប្រួលរបបទឹកជំនន់ ការប៉ះពាល់លក្ខណៈជីវសាស្ត្ររបស់ប្រភេទត្រី ការកើតឡើងនូវខ្យល់ព្យុះដែលធ្វើឱ្យប៉ះពាល់ដល់សហគមន៍តំបន់ឆ្នេរ និងទម្រង់នៃការប៉ះពាល់ផ្សេងៗទៀតចំពោះផលិតកម្មកសិកម្ម។

ដូចនេះបញ្ហាគន្លឹះសម្រាប់ការអភិវឌ្ឍវិស័យជលផលនៅថ្ងៃអនាគត គឺការទទួលស្គាល់ថា ផលនេសាទពីធម្មជាតិមិនអាចរក្សាបានឋិតថេរឡើយ ហើយការផ្តល់អាទិភាពចំពោះវិស័យនេះ ត្រូវផ្អែកលើសកម្មភាពណាដែលមានផលប៉ះពាល់អវិជ្ជមានជាអប្បបរមាទៅលើបរិស្ថាន។

ដោយទទួលស្គាល់នូវបញ្ហាទាំងអស់ខាងលើនិងផ្អែកលើកាលានុវត្តភាព ដែលមានរាជរដ្ឋាភិបាលកម្ពុជាបានធ្វើការកែសម្រួល និងធ្វើបច្ចុប្បន្នភាពអភិក្រមជាយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ករណីទាំងអស់ដូចរៀបរាប់ខាងលើនេះ គឺត្រូវបានគិតគូរ និងរួមបញ្ចូលនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ ២០១០-២០១៩ ដែលជាក្របខ័ណ្ឌសម្រាប់រៀបចំផែនការដ៏សំខាន់នៃវិស័យជលផល។







៤

# អភិក្រមជាយុទ្ធសាស្ត្ររបស់វិស័យជលផល

ការធ្វើបច្ចុប្បន្នភាពនៃអភិក្រមជាយុទ្ធសាស្ត្រសម្រាប់វិស័យជលផល គឺគ្របដណ្តប់សម្រាប់រយៈពេលពីឆ្នាំ២០១៥ដល់ឆ្នាំ២០២៤។ ការធ្វើបច្ចុប្បន្នភាពនេះ គឺផ្អែកលើក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ ដោយធ្វើការឆ្លុះបញ្ចាំងពីការប្រែប្រួលលក្ខខណ្ឌគោលនយោបាយ សេដ្ឋកិច្ច សង្គម និងបរិស្ថានដែលវិស័យជលផលចាំបាច់ត្រូវដំណើរការ។ អភិក្រមជាយុទ្ធសាស្ត្រនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ឆ្លុះបញ្ចាំងពីទស្សនវិស័យរបស់វិស័យជលផលក្របខ័ណ្ឌគោលនយោបាយទូលំទូលាយ និងចំណុចដៅជាយុទ្ធសាស្ត្រនៃវិស័យជលផល។

## ទស្សនវិស័យសម្រាប់វិស័យជលផល

ក្របខ័ណ្ឌគោលនយោបាយសំខាន់ៗដែលណែនាំដល់ការអភិវឌ្ឍនៅកម្ពុជា ជាពិសេសចំពោះវិស័យជលផល គឺត្រូវបានកំណត់ឡើងដោយក្របខ័ណ្ឌគោលនយោបាយសមាហរណកម្ម និងអន្តរទំនាក់ទំនង។ ក្របខ័ណ្ឌទាំងនេះគឺណែនាំនិងផ្តល់នូវព័ត៌មានអំពីដំណើរការអភិវឌ្ឍដោយរួមបញ្ចូលនៅក្នុងកម្រិតក្របខ័ណ្ឌជាតិនិងអន្តរជាតិ។ កម្រិតក្របខ័ណ្ឌអន្តរជាតិ ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព អនុសញ្ញានៃក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវចំពោះ វិស័យជលផលនិងគោលការណ៍ណែនាំដោយស្ម័គ្រចិត្តសម្រាប់និរន្តរភាពនេសាទទ្រង់ទ្រាយតូចក្នុងបរិបទនៃសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ។ កម្រិតក្របខ័ណ្ឌជាតិ ដូចជាទស្សនវិស័យសម្រាប់ឆ្នាំ២០៣០ យុទ្ធសាស្ត្រចតុកោណក្នុងដំណាក់កាលទី៣ (កំណើន ការងារ សមធ៌ម និងប្រសិទ្ធភាព) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជាឆ្នាំ២០១៤-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។ អន្តរកម្មនេះ រួមជាមួយនឹងក្របខ័ណ្ឌគោលនយោយដ៏ទូលំទូលាយនឹងមានចែងលម្អិតថែមទៀត នៅក្នុងឧបសម្ព័ន្ធ១។ តាមរយៈដំណើរការពិនិត្យមើលឡើងវិញ ការវាយតម្លៃនិងការផ្តល់មតិត្រឡប់នៃដំណើរការរៀបចំគោលនយោបាយលទ្ធផលនៃដំណើរការអភិវឌ្ឍនៅក្នុងវិស័យជលផល គឺជាព័ត៌មានដ៏សំខាន់សម្រាប់ក្របខ័ណ្ឌគោលនយោបាយទាំង







នៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលមានទស្សនៈរយៈពេលវែង ដែលទស្សនៈនេះ គឺស្របគ្នានឹងទស្សនវិស័យសម្រាប់ឆ្នាំ២០៣០ បង្កើតនូវបរិបទនិងអាទិភាពដែលជាគោលការណ៍ បង្ហាញទិសដៅសម្រាប់រៀបចំគោលនយោបាយថ្នាក់ជាតិសម្រាប់វិស័យជលផល។

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលដែលត្រូវធ្វើបច្ចុប្បន្នភាពនេះ គឺត្រូវបានធ្វើឡើងផ្អែកតាម ទស្សនវិស័យសម្រាប់វិស័យជលផល ដែលត្រូវបានកំណត់នៅក្នុងឯកសារគោលនយោបាយវិស័យជលផល និងនៅ ក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩។ ទស្សនវិស័យសម្រាប់វិស័យជលផលគឺ៖

*គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គមនិងការអភិវឌ្ឍប្រទេសជាតិ។*

ទោះបីជា ទស្សនវិស័យរបស់វិស័យជលផលស្ថិតនៅមិនប្រែប្រួលក្តី ប៉ុន្តែក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ វិស័យជលផលឆ្នាំ២០១០-២០១៩ រំពឹងទុកថា ក្នុងកាលៈទេសៈដែលវិស័យជលផលមានការអភិវឌ្ឍទាំងនៅថ្នាក់ ជាតិ និងថ្នាក់អន្តរជាតិនោះ វិស័យជលផលនឹងមានការប្រែប្រួល។ នៅក្នុងដំណើរការប្រែប្រួលក៏មានការកើនឡើង នូវភាពមិនទៀងទាត់ដែលឆ្លុះបញ្ចាំងអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុនិងឥទ្ធិពលសេដ្ឋកិច្ច។ ចំណុចគន្លឹះទៅ ថ្ងៃអនាគតសម្រាប់វិស័យជលផលនៅក្នុងប្រទេសកម្ពុជា គឺត្រូវធ្វើការឆ្លើយតបនិងសម្របទៅនឹងការប្រែប្រួលទាំង នោះ ដើម្បីកសាងភាពធន់ទ្រាំសម្រាប់វិស័យក៏ដូចជាសម្រាប់សហគមន៍។

ទំនាក់ទំនងរវាងក្របខ័ណ្ឌគោលនយោបាយ រួមជាមួយនឹងគោលនយោបាយរបស់វិស័យជលផល ដែលមាន ឥទ្ធិពលទៅវិញទៅមកអាចរៀបរាប់បានដូចខាងក្រោម៖

## ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនិងក្របខ័ណ្ឌគោលនយោបាយទូលំទូលាយ

ការប្រែប្រួលដែលមិនអាចព្យាករណ៍បាន គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងដំណើរការអភិវឌ្ឍនៅបណ្តាឆ្នាំខាង មុខ។ នៅកម្ពុជាមានកត្តាជាច្រើនដែលជះឥទ្ធិពលទៅលើវិស័យជលផល ហើយឥទ្ធិពលនោះគឺពិបាកក្នុងការព្យាករ ទុកជាមុន។ ភាពមិនទៀងទាត់នេះមិនត្រឹមតែជះឥទ្ធិពលមកលើកម្ពុជាប៉ុណ្ណោះទេ។ ការប្រែប្រួលអាកាសធាតុ និង







ការប្រែប្រួលសេដ្ឋកិច្ចនិងសង្គម (ទាំងថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ) នឹងជះឥទ្ធិពលមកលើបណ្តាប្រទេសនានា ដែលមិនអាចដឹងជាមុនបាន។ បញ្ហានេះ គឺទាមទារនូវអភិក្រមថ្មីមួយក្នុងការរៀបចំផែនការសម្រាប់វិស័យជលផល ដែលអាចឆ្លើយតបទៅនឹងការប្រែប្រួលនិងភាពមិនទៀងទាត់ដែលនឹងកើតឡើង។

អភិក្រមជាយុទ្ធសាស្ត្រនិងគោលនយោបាយវិស័យជលផល ក៏បានឆ្លុះបញ្ចាំងពីគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពជាសកលផងដែរ។ វិស័យជលផលបានរួមចំណែកយ៉ាងសំខាន់ដល់គោលដៅទាំងនេះ ហើយក៏ទទួលរងនូវឥទ្ធិពលពីគោលដៅទាំងនេះផងដែរ (សូមអានឧបសម្ព័ន្ធ១)។

វិធីដែលវិស័យជលផលអាចសម្រេចបាននូវគោលដៅទាំងនេះ គឺមានការពាក់ព័ន្ធនឹងក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវចំពោះវិស័យជលផល និងគោលការណ៍ណែនាំដោយស្ម័គ្រចិត្តសម្រាប់សុវត្ថិភាពនេសាទទ្រង់ទ្រាយតូចក្នុងបរិបទសន្តិសុខស្បៀងនិងការកាត់បន្ថយភាពក្រីក្រ (ក្រមប្រតិបត្តិជលផលកម្ពុជាវគ្គ៣ នៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល) ដែលបង្ហាញពីវិធីសម្រាប់ការអភិវឌ្ឍវិស័យជលផល។

ក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវ ចំពោះវិស័យជលផលក៏បានទទួលស្គាល់នូវការធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ហើយបានរៀបចំផែនការសកម្មភាពអន្តរជាតិសម្រាប់ទប់ស្កាត់។ ផែនការសកម្មភាពនេះគឺជាឯកសារស្ម័គ្រចិត្តដែលអនុវត្តនៅគ្រប់រដ្ឋនិងអង្គភាពពាក់ព័ន្ធ និងគ្រប់អ្នកនេសាទទាំងអស់។

ប្រទេសកម្ពុជា គឺជាប្រទេសដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិជាច្រើន។ កិច្ចព្រមព្រៀងទាំងនោះមានឥទ្ធិពលចំពោះវិស័យជលផល រួមមាន៖

- អនុសញ្ញាស្តីពីជីវចម្រុះ។
- អនុសញ្ញាស្តីពីការនេសាទនិងការអភិរក្សធនធានមានជីវិតនៅក្នុងសមុទ្រដែលមានជម្រៅទឹកជ្រៅ។
- អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មលើប្រភេទសត្វនិងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់។
- ពិធីសារក្យូតូអំពីការប្រែប្រួលអាកាសធាតុ និងក្របខ័ណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ។
- អនុសញ្ញាទីក្រុងបាសែលស្តីពី ការត្រួតពិនិត្យការដឹកជញ្ជូនឆ្លងដែននូវកាកសំណល់ប្រកបដោយគ្រោះថ្នាក់។
- ពិធីសារម៉ុងទ្រាលស្តីពីសារធាតុដែលបំផ្លាញប្រទាប់អូហ្សូន។
- ពិធីសារឆ្នាំ១៩៧៨ ពាក់ព័ន្ធនឹងអនុសញ្ញាអន្តរជាតិសម្រាប់ការពារការបំពុលពីការដឹកជញ្ជូនតាមនាវា។
- កិច្ចព្រមព្រៀងអន្តរជាតិស្តីពីផលិតផលព្រៃឈើតំបន់ត្រូពិចឆ្នាំ១៩៨៤។







- អនុសញ្ញាស្តីពីតំបន់ដីសើមអន្តរជាតិសំខាន់ៗ ជាពិសេសតំបន់ពាំសារ។
- អនុសញ្ញាអន្តរជាតិសម្រាប់ការធ្វើនិយតកម្មចំពោះត្រីបាឡែន។
- អនុសញ្ញាអង្គការសហប្រជាតិស្តីពីច្បាប់សមុទ្រ។ អនុសញ្ញានេះត្រូវបានចុះហត្ថលេខាហើយ ប៉ុន្តែមិនទាន់មានការអនុម័តដោយរដ្ឋសភានៅឡើយ។

កិច្ចព្រមព្រៀងអន្តរជាតិទាំងនេះ គឺជាបន្ទុកបន្ថែមទៅលើកាតព្វកិច្ចរបស់កម្ពុជា ប៉ុន្តែវាក៏ជាកាលានុវត្តភាពសម្រាប់កិច្ចសហប្រតិបត្តិការ និងសម្រាប់និរន្តរភាពនៃវិស័យជលផលយូរអង្វែងផងដែរ។ បន្ថែមទៅលើកិច្ចព្រមព្រៀងអន្តរជាតិ កម្ពុជាមានទំនាក់ទំនងយូរអង្វែងយ៉ាងល្អជាមួយនឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលអាស៊ីអាគ្នេយ៍ (SEAFDEC) និងគណៈកម្មការទន្លេមេគង្គ (MRC) ដែលផ្តល់ព័ត៌មាននិងមានឥទ្ធិពលដល់គោលនយោបាយ។

យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គរបស់គណៈកម្មការទន្លេមេគង្គ ផ្តល់នូវក្របខ័ណ្ឌជាអន្តរវិស័យសម្រាប់កិច្ចសហប្រត្តិបត្តិការនៅក្នុងតំបន់តាមរយៈដំណើរការសមាហរណកម្មធនធានទឹក។ យុទ្ធសាស្ត្រនេះ គឺផ្អែកលើគោលបំណងនៃកិច្ចព្រមព្រៀងឆ្នាំ១៩៩៥ របស់គណៈកម្មការទន្លេមេគង្គ ដែលរួមមាន៖

- កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនូវគ្រប់វិស័យនៃការអភិវឌ្ឍ ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធរបស់អាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព ដើម្បីទទួលបាននូវផលប្រយោជន៍ដ៏ប្រសើរបំផុតពីការប្រើប្រាស់ច្រើនយ៉ាងនិងផ្តល់នូវផលប្រយោជន៍ទៅវិញទៅមករវាងបណ្តាប្រទេសជាសមាជិក។
- លើកទឹកចិត្ត និងគាំទ្រការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍដ៏ប្រសើរបំផុត ដើម្បីទទួលបានផលប្រយោជន៍ប្រកបដោយនិរន្តរភាព និងដើម្បីកាត់បន្ថយការខ្វះខាតនៃការប្រើប្រាស់ធនធាន ដោយផ្តោតលើគម្រោងអភិវឌ្ឍអាងទន្លេមេគង្គរួមគ្នា តាមរយៈការរៀបចំផែនការអភិវឌ្ឍអាងទាំងមូល។
- ការពារបរិស្ថាន ធនធានធម្មជាតិ ធនធានវារិជាត និងរក្សាបាននូវតុល្យភាពអេកូឡូស៊ីនៃអាងទន្លេមេគង្គពីការបំពុល ឬពីផលប៉ះពាល់អវិជ្ជមាននានា។
- ប្រើប្រាស់ទឹកនៅក្នុងប្រព័ន្ធទន្លេមេគង្គប្រកបដោយសមធម៌និងសមស្រប។

យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គផ្តល់នូវរចនាសម្ព័ន្ធមួយសម្រាប់កិច្ចសហប្រតិបត្តិការនៅថ្នាក់តំបន់ ហើយនឹងធ្វើការសម្របសម្រួលនៅថ្នាក់ជាតិ តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលបានលើកឡើង។

យុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលនៅ ក្នុងតំបន់អាងទន្លេមេគង្គរបស់គណៈកម្មការទន្លេមេគង្គ







ត្រូវបានរៀបចំឡើងដោយរួមបញ្ចូលជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គ។ យុទ្ធសាស្ត្រនេះមានគោលបំណង ដើម្បីប្រើប្រាស់ធនធានវារិជាតប្រកបដោយនិរន្តរភាពនិងមានការទទួលខុសត្រូវ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ គណៈកម្មការទន្លេមេគង្គបានគាំទ្រដល់កម្មវិធីមួយចំនួន តាមរយៈការកសាងចំណេះដឹងអំពីធនធានជលផល ការតាមដាននិន្នាការធនធានជលផល ការលើកកម្ពស់ការចរចារដើម្បីសម្រេចបាននូវសុខដុមនីយកម្មថ្នាក់តំបន់និងអន្តរវិស័យ នៅក្នុងក្របខ័ណ្ឌសមាហរណកម្មការគ្រប់គ្រងធនធានទឹក និងគាំទ្រដល់ការគ្រប់គ្រងដែលមានប្រសិទ្ធភាព។ កម្មវិធីជលផលនៃគណៈកម្មការទន្លេមេគង្គបានគាំទ្រ និងជួយពង្រឹងការងាររបស់រដ្ឋបាលជលផល។

ទស្សនវិស័យរបស់កម្ពុជាឆ្នាំ២០៣០ គឺជាទស្សនវិស័យមួយអំពីការអភិវឌ្ឍដែលមានរយៈពេលវែង និងផ្តោតលើកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌និងនិរន្តរភាព។ ករណីនេះ គឺបានចែងនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ដោយយកចិត្តទុកដាក់ជាចម្បងដល់កំណើនសេដ្ឋកិច្ច និងកំណើនផលិតកម្ម តាមរយៈការលើកកម្ពស់អភិបាលកិច្ចល្អនិងបង្កើនជីវភាពរស់នៅ។ យុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានទទួលស្គាល់នូវសារៈសំខាន់របស់វិស័យជលផល ដោយសង្កត់ធ្ងន់ចំពោះតម្រូវការក្នុងការធានាបាននូវនិរន្ត-ភាពនៃផលនេសាទ និងគាំទ្រដល់ផលិតកម្មវារីវប្បកម្ម និងតម្លៃសង្វាក់ផលផលិតផលជលផល ដើម្បីរួមចំណែកដល់កំណើន។ កិច្ចការនេះ គឺធ្វើឱ្យមានការបង្វែរការយកចិត្តទុកដាក់នៃវិស័យ ពីការបង្កើននូវផលិតកម្ម មកជាការបង្កើតតម្លៃបន្ថែម។ ជាមួយគ្នានេះ ក៏បានទទួលស្គាល់ផងដែរអំពីផលប៉ះពាល់ដែលកើតមានចំពោះធនធានជលផលនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើពិពិធកម្មលើការដាំដុះ និងលើកកម្ពស់វារីវប្បកម្មនិងតម្លៃបន្ថែមនៃសង្វាក់ផលិតកម្ម។ កត្តាសំខាន់ដែលធ្វើឱ្យមានការកើនឡើងនូវផលិតភាព គឺអាចធ្វើបានតាមរយៈការធ្វើប្រពលវប្បកម្មវារីវប្បកម្មប្រកបដោយនិរន្តរភាព [៤]។

ដើម្បីសម្រេចបាននូវគោលដៅនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានទទួលស្គាល់នូវតម្រូវការចាំបាច់ក្នុងការពង្រឹងនូវការអនុវត្តច្បាប់ និងការកសាងសមត្ថភាពរបស់រដ្ឋបាលជលផលវិស័យឯកជននិងសហគមន៍ ជាពិសេសពាក់ព័ន្ធនឹងបញ្ហាការប្រែប្រួលអាកាសធាតុនិងស្ថានភាពនៃការប្រែប្រួលសេដ្ឋកិច្ចនិងការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ។

---

*[៤] និរន្តរភាពនៃប្រពលវប្បកម្មវារីវប្បកម្មគឺសំដៅទៅលើ ការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ម្ហូបអាហារ និងអាហារូបត្ថម្ភ បង្កើននូវកាលានុវត្តភាពនៃមុខរបរចិញ្ចឹមជីវិត និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចតាមបែបនៃការអភិវឌ្ឍន៍បៃតង តាមរយៈការប្រើប្រាស់ធនធានវារីវប្បកម្មប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។*













ក្របខ័ណ្ឌបទដ្ឋានគតិយុត្តសំខាន់ក្នុងការគ្រប់គ្រងវិស័យជលផលគឺច្បាប់ស្ដីពីជលផលឆ្នាំ២០០៦។

សារៈសំខាន់របស់វិស័យជលផលក៏ត្រូវបានទទួលស្គាល់ផងដែរពីដៃគូអភិវឌ្ឍន៍ តាមរយៈសូចនាករតាមដាន និងត្រួតពិនិត្យរួមគ្នា។ កិច្ចការទាំងនេះ គឺត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសូចនាករនៃលទ្ធផលរបស់វិស័យ ហើយចាំបាច់ត្រូវកែសម្រួលពីមួយពេលទៅមួយពេល។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម បានកំណត់នូវគោលដៅយ៉ាងជាក់លាក់ក្នុងបង្កើនផលិតភាពក្នុងអត្រា៥%ក្នុង១ឆ្នាំ ក្នុងនោះវិស័យជលផលជាវិស័យមួយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបាននូវគោលដៅនេះ។ ដើម្បីបង្កើននូវការរួមចំណែករបស់វិស័យជលផលឱ្យបានច្រើនថែមទៀតចំពោះកំណើនលទ្ធភាពដែលអាចធ្វើបាន គឺតាមរយៈការបង្កើននូវផលិតភាពនៃប្រពលវប្បកម្មវារីវប្បកម្មប្រកបដោយនិរន្តរភាពការបង្កើននូវផលិតផលជលផលតាមវាលស្រែ និងការបង្កើននូវតម្លៃសង្វាក់ផលិតផលជលផល។ ដូចនេះ ដើម្បីធានាបាននូវនិរន្តរភាពនៃធនធានធម្មជាតិ វិធានការចាំបាច់ គឺពង្រឹងការគ្រប់គ្រងការនេសាទទាំងទឹកសាបនិងសមុទ្រ និងទីជម្រកឱ្យបានល្អ។ កិច្ចការនេះនឹងអាចរក្សាបាននូវលក្ខណៈជីវសាស្ត្រ និងធានាបាននូវសុវត្ថិភាពកេរ្តិ៍មរតកធម្មជាតិរបស់កម្ពុជា។

## យុទ្ធសាស្ត្រវិស័យជលផលផ្ដោតការយកចិត្តទុកដាក់

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១១-២០១៩ មានគោលដៅចំនួន៧។ គោលដៅទាំងនេះ ត្រូវបានដាក់រួមបញ្ចូលជាមួយសសរស្តម្ភនៃការអភិវឌ្ឍចំនួន៣ នៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ដើម្បីផ្សារភ្ជាប់វិស័យជលផលជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។ សសរស្តម្ភអភិវឌ្ឍន៍របស់ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនីមួយៗរួមមានសូចនាករពាក់ព័ន្ធរបស់វា និងចំណុចដៅដែលឆ្លុះបញ្ចាំងអំពីគោលបំណងជាយុទ្ធសាស្ត្ររបស់វិស័យ។ ឯកសារក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលដែលត្រូវធ្វើបច្ចុប្បន្នភាពនេះ គឺជាឯកសារយុទ្ធសាស្ត្រយូរអង្វែង ដែលគ្របដណ្តប់រយៈពេល១០ឆ្នាំ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មគ្របដណ្តប់រយៈពេលខ្លី ហើយត្រូវបានយកធ្វើជាគោលការណ៍ណែនាំដល់លទ្ធផលរបស់







អនុកម្មវិធីទាំង១១ របស់វិស័យជលផល។ កម្មវិធីជលផលដែលបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មគឺតំណាងឱ្យផែនការគ្រប់គ្រងជលផលជាតិ។

សសរស្តម្ភអភិវឌ្ឍន៍ទាំង៣នេះ គឺនៅតែជាចំណុចអាទិភាពក្នុងការអភិវឌ្ឍវិស័យជលផល ដែលកំពុងដំណើរការទៅមុខជាប្រក្រតី។ ប៉ុន្តែដើម្បីធានាបានថា វិស័យជលផលត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ទោះបីក្នុងករណីមានការប្រែប្រួលដែលកើតឡើងមិនបានគ្រោងទុក និងដើម្បីធានាបាននូវការឆ្លើយតបទាន់ពេលវេលានិងមានប្រសិទ្ធភាព តាមរយៈការបង្កើននូវគុណភាពនៃការផ្តល់នូវសេវាកម្មសសរស្តម្ភអភិវឌ្ឍន៍ទី៤ ត្រូវបានរួមបញ្ចូលបន្ថែមក្នុងនោះ គឺទទួលស្គាល់អំពីតម្រូវការនៃការកសាងសមត្ថភាពទាំងធនធានមនុស្សនិងស្ថាប័ននៅក្នុងរដ្ឋបាលជលផល និងភ្នាក់ងារដៃគូអភិវឌ្ឍន៍នានា ដើម្បីសម្រេចបានជោគជ័យនូវការអនុវត្តនូវកម្មវិធីដែលបានរៀបចំ។ សសរស្តម្ភនៃការអភិវឌ្ឍទាំង៤សម្រាប់វិស័យជលផល រួមមានដូចខាងក្រោម៖

- ការនេសាទនិងការគ្រប់គ្រង
- វារីវប្បកម្ម រួមទាំងទឹកសាបនិងសមុទ្រ
- ខ្សែសង្វាក់ផលិតកម្មជលផល
- និយតកម្មនិងសេវាកម្ម។

សសរស្តម្ភទាំង៤នេះ គឺផ្តោតលើសក្តានុពលនៃលទ្ធផលសម្រេច ដែលជាគោលបំណងរបស់ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលដែលធ្វើបច្ចុប្បន្នភាពនេះ។ សសរស្តម្ភនីមួយៗក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលដែលត្រូវធ្វើបច្ចុប្បន្នភាពនេះ គឺមានសូចនាករកម្រិតលទ្ធផលសម្រេចចំនួន៣ រួមជាមួយនឹងចំណុចដៅពាក់ព័ន្ធនានា សម្រាប់ឆ្នាំ២០១៧-២០២០ និងឆ្នាំ២០២៤។ សូចនាកររបស់ក្របខ័ណ្ឌផែនការយុទ្ធ-សាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១១-២០១៩ មួយចំនួនដែលនៅតែពាក់ព័ន្ធ គឺនឹងត្រូវរក្សាទុកជាសូចនាករកម្រិតលទ្ធផលសម្រេចរបស់ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ដែលត្រូវធ្វើបច្ចុប្បន្នភាពនេះឬដាក់បញ្ចូលជាមួយនឹងសូចនាកររបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។

ផ្អែកលើក្របខ័ណ្ឌគោលនយោបាយដ៏ទូលំទូលាយនិងគោលដៅកម្រិតថ្នាក់ជាតិនិងកម្រិតវិស័យកសិកម្ម រដ្ឋបាលជលផលនឹងបំពេញការងារស្របតាមសសរស្តម្ភនៃការអភិវឌ្ឍទាំងនេះ ដើម្បីទទួលបាននូវលទ្ធផលដូចខាងក្រោម៖







| សសរស្តម្ភនិងលទ្ធផល [៥] | សូចនាករ | ចំណុចដៅ |
|---|---|---|
| **សសរស្តម្ភទី១.**<br>**ការនេសាទនិង ការគ្រប់គ្រង៖**<br>ផលនេសាទទឹកសាបនិងសមុទ្រត្រូវបានរក្សាឱ្យមានស្ថិរភាព តាមរយៈ ការគ្រប់គ្រង ការអភិរក្សប្រកបដោយនិរន្តរភាព និងអនុវត្តតាមគោលការណ៍បរិស្ថានល្អ។ | ១.១ ផលនេសាទពីគ្រប់ប្រភព<br>ឆ្នាំគោលៈ ៦០០.០០០តោន<br><br>១.២ ចំនួនសហគមន៍ដែលបានដំណើរការល្អ<br>ឆ្នាំគោល៖ ៥០ សហគមន៍ (២០១៤)<br><br>១.៣ តំបន់អភិរក្សដែលគ្រប់គ្រងបានល្អ<br>ឆ្នាំគោល៖ ២៦.៦៧៤ហិកតា (២០១៤) | ២០១៧៖ ៦០០.០០០តោន<br>២០២០៖ ៦០០.០០០តោន<br>២០២៤៖ ៦០០.០០០តោន<br><br>២០១៧៖ ១០០សហគមន៍<br>២០២០៖ ២០០សហគមន៍<br>២០២៤៖ ៣០០សហគមន៍<br><br>២០១៧៖ ១១៦.២៦២ហិកតា<br>២០២០៖ ១៤២.១៣៥ហិកតា<br>២០២៤៖ ១៧២.៧៤៦ហិកតា |
| **សសរស្តម្ភទី២.**<br>**វារីវប្បកម្ម៖ ទឹកសាបនិងសមុទ្រ**<br>វារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្មនិងប្រកបដោយនិរន្តរភាពដែលអាចរួមចំណែកដល់សន្តិសុខស្បៀង ការអភិវឌ្ឍសេដ្ឋកិច្ច ផលិតផលសរុបក្នុងស្រុកនិងការនាំចេញ។ | ២.១ ផលិតផលវារីវប្បកម្ម (កើនឡើង ២០%ក្នុង១ឆ្នាំៗ)<br>ឆ្នាំគោល៖ ១២០.០០០តោន (២០១៤)<br>២.១ ចំនួនក្រុមហ៊ុនវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្មទ្រង់ទ្រាយមធ្យមនិងធំ ដែលបានចុះបញ្ជី ហើយបានសម្រប តាមគោលការណ៍អនុវត្តន៍ល្អ<br>ឆ្នាំគោល៖ ៨ (២០១៤)<br>២.២ តម្លៃផលិតផលវារីវប្បកម្មសរុបនៅកសិដ្ឋានគិតជាដុល្លារអាមេរិក<br>ឆ្នាំគោល៖ $២៤០ លាន (២០១៤) | ២០១៧៖ ២០៧.០០០តោន<br>២០២០៖ ៣៦០.០០០តោន<br>២០២៤៖ ៧៤០.០០០តោន<br>២០១៧៖ ២០<br>២០២០៖ ៣៥<br>២០២៤៖ ៦៦<br><br>២០១៧៖ $៤១៤ លាន<br>២០២០៖ $៧១៦លាន<br>២០២៤៖ $១៤៨៦លាន |

[៥] *សូមអានឧបសម្ព័ន្ធ២ដែលពន្យល់បកស្រាយតារាងនេះ*







| សសរស្តម្ភ និងលទ្ធផល | សូចនាករ | ចំណុចដៅ |
|---|---|---|
| **សសរស្តម្ភទី៣. ខ្សែសង្វាក់ផលិតកម្មជលផល**<br>ស្តង់ដារនៃខ្សែសង្វាក់ផលិតកម្មជលផលដំណើរការនិងនីតិវិធីត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់សន្តិសុខស្បៀង និរន្តរភាពនៃជីវភាពរស់នៅ និងការធ្វើពាណិជ្ជកម្មប្រកបដោយសមធម៌ និងមានផលចំណេញ។ | ៣.១ ការរួមចំណែករបស់វិស័យជលផលចំពោះផលិតផលសរុបក្នុងស្រុក<br>ឆ្នាំគោល: ៨% នៃ GDP (២០១៤)<br>៣.២ ការកើនឡើងនូវផលនេសាទ ស្របច្បាប់ និងផលិតផលវារីវប្បកម្ម<br>ឆ្នាំគោល: ១៧.៥០០ តោន (២០១៤)<br>៣.៣ ការកើនឡើងនូវចំនួនក្រុមហ៊ុនកែច្នៃត្រីជាទ្រង់ទ្រាយមធ្យម និងធំដែលបានអនុវត្តតាមលក្ខខណ្ឌអនាម័យល្អ<br>ឆ្នាំគោល៖ ក្រុមហ៊ុនចំនួន ១ (២០១៤) | ២០១៧៖ ៨% នៃGDP<br>២០២០៖ ៨%<br>២០២៤៖៨%<br>២០១៧៖ ៣០.០០០តោន<br>២០២០៖៥០.០០០តោន<br>២០២៤៖ ១០០.០០០តោន<br>២០១៧៖ ១០<br>២០២០៖ ២០<br>២០២៤៖ ៣០ |
| **សសរស្តម្ភទី៤. ការធ្វើនិយតកម្ម និងសេវាកម្ម**<br>គោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ និងសេវាកម្មសម្រាប់អនុវិស័យនៃវិស័យជលផល គឺមានភាពគ្រប់គ្រាន់មានលក្ខណៈសមស្របនិងបង្កភាពងាយស្រួល។ | ៤.១ បច្ចេកទេសជំនាញសមស្របសម្រាប់ជលផល និងវារីវប្បកម្ម គឺមានការកើនឡើង<br>ឆ្នាំគោល៖ និស្សិតចំនួន៤០ បានចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យសំខាន់ពាក់ព័ន្ធនឹងជលផល<br>៤.២ ចំនួនលិខិតផ្លូវការរបស់ក្រសួងពាក់ព័ន្ធដែលបានផ្ញើមករដ្ឋបាលជលផល ដើម្បីជូនដំណឹង ឬស្នើសុំការចូលរួមចំណែករបស់រដ្ឋបាលជលផលពាក់ព័ន្ធនឹងការសម្រេចចិត្តនិងច្បាប់នានាដែលអាចមានឥទ្ធិពលទៅលើវិស័យជលផល។<br>ឆ្នាំគោល៖ ៤៣៦ (២០១៤)<br>៤.៣ ទស្សនៈយល់ដឹងរបស់វិស័យឯកជននិងអ្នកពាក់ព័ន្ធចំពោះឥទ្ធិពល និងការអនុវត្តគោលនយោបាយនិងច្បាប់។<br>ឆ្នាំគោល៖ ២០១៥ (ការអង្កេតអំពីទស្សនៈនៃការយល់ដឹងដែលធ្វើឡើងដោយក្រុមការងារតាមដាននិងវាយតម្លៃ)។ | ២០១៧៖ ១០%កើនឡើងធៀបនឹងឆ្នាំគោល<br>២០២០៖ ៣០%<br>២០២៤៖ ៥០%<br>២០១៧៖ ២០%កើនឡើងធៀបនឹងឆ្នាំគោល<br>២០២០៖ ៥០%<br>២០២៤៖ ៧០%<br>២០១៧៖ ២០%កើនឡើងធៀបនឹងឆ្នាំគោល<br>២០២០៖ ៥០%<br>២០២៤៖ ៧០% |







សសរស្តម្ភនៃការអភិវឌ្ឍទាំង៤ នៃវិស័យជលផលនឹងរួមចំណែកដល់ទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់អនាគតនៃវិស័យជលផល។ សូចនាកររបស់សសរស្តម្ភនៃការអភិវឌ្ឍទាំងនេះ គឺរៀបរាប់អំពីស្ថានភាពដែលជាបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលកម្ពុជាចង់ឃើញនៅក្នុងទសវត្សរ៍ខាងមុខ។ លទ្ធផលសម្រេចជាក់លាក់ពាក់ព័ន្ធនឹងអនុកម្មវិធីនានានៃវិស័យជលផល ត្រូវបានកំណត់នៅក្នុងផែនការគ្រប់គ្រងជលផលជាតិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ហើយដែលនឹងមានការប្រែប្រួលនៅក្នុងឆ្នាំខាងមុខ ក្នុងការទទួលស្គាល់នូវភាពមិនទៀងទាត់ដែលនឹងកើតឡើង ដែលវិស័យជលផលថ្នាក់ជាតិនិងថ្នាក់តំបន់ត្រូវជួបប្រឈម។

ភាពចាំបាច់និងអភិក្រមជាយុទ្ធសាស្ត្រដ៏ទូលាយសម្រាប់សសរស្តម្ភនៃការអភិវឌ្ឍទាំង៤ របស់វិស័យជលផលរួមមានដូចខាងក្រោម៖

## ការនេសាទនិងការគ្រប់គ្រង

កាលពីអតីតកាល ការនេសាទត្រូវបានចាត់ទុកថាជាស្នូលនៃការអភិវឌ្ឍវិស័យជលផលនៅកម្ពុជា។ នៅថ្ងៃអនាគត នេសាទទឹកសាបនៅតែអាចពង្រីកបាន តាមរយៈការគ្រប់គ្រងឱ្យបានប្រសើរឡើង ប៉ុន្តែវាអាចរងនូវការផលប៉ះពាល់ដោយសារកំណើននូវសម្ពាធពីការធ្វើពិពិធកម្មកសិកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការនេសាទខុសច្បាប់។ ដូចគ្នានេះដែរ ការបើកចំហសេដ្ឋកិច្ច ក្រោមក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាននឹងបង្កើតបាននូវសក្តានុពល ប៉ុន្តែក៏មានបញ្ហាប្រឈមផងដែរ។ ការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យមានការប្រែប្រួលរបបទឹកជំនន់និងចរាចររបស់ត្រី ហើយជះឥទ្ធិពលដល់លក្ខខណ្ឌការងាររបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ដើម្បីឆ្លើយតបនូវការប្រែប្រួលទាំងនេះ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលបានផ្តោតលើការពង្រឹងការគ្រប់គ្រងឱ្យប្រសើរឡើង ជំរុញអភិបាលកិច្ចល្អ អភិរក្សទីជម្រក បង្កើតមុខរបរចិញ្ចឹមជីវិតដែលអាចធន់ទ្រាំបានពង្រឹងសិទ្ធិអំណាចនិងរៀបចំផែនការដែលអាចសម្របបានទៅតាមការប្រែប្រួល។

ផលនេសាទពីធម្មជាតិនឹងត្រូវរក្សាឱ្យស្ថិតនៅក្នុងកម្រិតដែលអាចធានានូវនិរន្តរភាព ហើយកម្មវិធីបង្កើតស្រះជម្រកត្រីសហគមន៍ ដូចមានចែងលម្អិតនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនឹងត្រូវបន្តអនុវត្ត ហើយជំរុញបង្កើននូវធនធានជលផលតាមវាលស្រែនៅទីកន្លែងណាដែលអាចធ្វើបាន (អានបន្ថែមនូវផ្នែកវារីវប្បកម្មខាងក្រោយ)។ ការស្រាវជ្រាវនឹងបន្តធ្វើឡើងដើម្បីបង្កើនការយល់ដឹងបន្ថែមទៀតអំពីទំនាក់ទំនងរវាងធនធានជលផលតាមវាលស្រែនិងនេសាទធម្មជាតិ ហើយកំណត់ឡើងវិញនូវការប៉ាន់ស្មានអំពីផលិតភាពធនធាន













ជលផលតាមវាលស្រែ។ ការបង្កើនផលស្តុកត្រីធម្មជាតិ គឺសកម្មភាពជាប្រពៃណីយ៉ាងសំខាន់នៅក្នុងវិស័យជលផល ហើយនឹងត្រូវអនុវត្តបន្តទៅមុខទៀត។ ដើម្បីធានាថា ការអនុវត្តនេះមានសុវត្ថិភាព គឺត្រូវធ្វើឡើងស្របតាមការណែនាំជាអន្តរជាតិ។ ការបង្កើនផលស្តុកត្រីធម្មជាតិនេះ គឺត្រូវធ្វើឡើងដោយផ្អែកលើលក្ខខណ្ឌ៖១). ស្របជាមួយនឹងគោលនយោបាយ ២). ធានាបាននូវសុវត្ថិភាពនៃទីជម្រក ៣). បង្កើនបាននូវផលិតភាពតាមគោលដៅចង់បាន ៤). ទទួលបាននូវផលចំណេញផ្នែកសេដ្ឋកិច្ចនិងសង្គម និង៥). បង្កើននូវកម្រិតជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានដែលពឹងផ្អែកលើធនធានជលផល។

តាមរយៈក្រុមការងារបច្ចេកទេសចម្រុះស្តីពី កំណែទម្រង់ជលផល រដ្ឋបាលជលផលនឹងធ្វើការជាមួយនាយកដ្ឋានពាក់ព័ន្ធនានានៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្រេចបាននូវតុល្យភាពរវាងការថែរក្សាឱ្យមាននិរន្តរភាពនូវធនធានជលផលតាមវាលស្រែនិងការធ្វើពិពិធកម្មផលិតកម្មស្រូវ។ ការអនុវត្តតាមរបៀបនេះ គឺអាចទទួលបាននូវតម្លៃបន្ថែមដែលកើតចេញពីការធ្វើសមាហរណកម្មរវាងដំណាំស្រូវជាមួយនឹងជលផល។

ការគ្រប់គ្រងធនធានជលផលនិងទីជម្រក នៅក្នុងក្របខ័ណ្ឌច្បាប់មួយជាក់លាក់ គឺជាកិច្ចការយ៉ាងសំខាន់ក្នុងការធានាបាននូវនិរន្តរភាពនៃវិស័យជលផល ជាពិសេសនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុនិងឥទ្ធិពលពីថ្នាក់តំបន់។ សហគមន៍នេសាទ គឺជាចំណុចស្នូលនៃការកែទម្រង់វិស័យជលផលស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះ រាជរដ្ឋាភិបាលបានកាត់ឡូតិ៍នេសាទហើយប្រគល់ទៅឱ្យសហគមន៍គ្រប់គ្រង។ កិច្ចការនេះមិនត្រឹមតែបង្កើតបាននូវអភិបាលកិច្ចល្អប៉ុណ្ណោះទេ ប៉ុន្តែក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់នូវការងារ និងសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅជនបទទៀតផង។ ដោយមានការគាំទ្រពីអង្គការដៃគូ រដ្ឋបាលជលផលនឹងផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសហគមន៍នេសាទឱ្យមានដំណើរការល្អ តាមរយៈការរៀបចំឱ្យមានលក្ខន្តិកៈយន្តការដឹកនាំនិងបណ្តុះបណ្តាលធនធានមនុស្ស។ កិច្ចការនេះនឹងត្រូវបំពេញបន្ថែមដោយការអនុវត្តតាមគោល ការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ ក្នុងការធានានូវនិរន្តរភាពនេសាទទ្រង់ទ្រាយតូច។













សកម្មភាពសំខាន់ៗក្នុងការពង្រឹងសហគមន៍នេសាទរួមមាន ការរៀបចំផែនទីនិងកំណត់ព្រំប្រទល់តំបន់សហ-គមន៍នេសាទឱ្យបានច្បាស់លាស់។ ផែនការគ្រប់គ្រងសហគមន៍នេសាទនឹងត្រូវរៀបចំឡើងស្របតាមច្បាប់និងត្រូវអនុវត្តដោយគណៈកម្មការសហគមន៍នេសាទ។ សមាជិកគណៈកម្មការសហគមន៍នេសាទនឹងត្រូវទទួលបាននូវការបណ្តុះបណ្តាលកសាងសមត្ថភាព ដើម្បីបំពេញការងារគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍ និងធនធានជលផល។ ការកំណត់និងបង្កើតតំបន់អភិរក្សសហគមន៍នេសាទ គឺជាកិច្ចការចាំបាច់។ ការអនុវត្តនូវលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានជលផល នៅក្នុងកន្លែងនេសាទសហគមន៍នឹងត្រូវពង្រឹង។ ការផ្សព្វផ្សាយព័ត៌មាននិងច្បាប់នឹងត្រូវធ្វើឡើង ដើម្បីធានាការយល់ដឹងរបស់សហគមន៍អំពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

តួនាទីរបស់ស្ត្រីក្នុងការចូលរួមនិងការសម្រេចចិត្តនៅក្នុងការគ្រប់គ្រងវិស័យជលផល ក៏ត្រូវបានពង្រឹងផងដែរ។ ប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងនេះ នឹងត្រូវធ្វើការវាយតម្លៃ ហើយទុកជាមេរៀនបទពិសោធន៍និងធ្វើការចែករំលែក។

លើសពីនេះ ការគាំទ្រនឹងត្រូវធ្វើឡើង ដើម្បីរៀបចំអង្គការសម្រាប់សហប្រតិបត្តិការ ដែលផ្តល់លទ្ធភាពដល់សហគមន៍មានតំណាងរបស់ខ្លួន និងចូលរួមផ្តល់នូវមតិយោបល់ផ្ទាល់ នៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងផលប្រយោជន៍របស់ខ្លួន។

ដើម្បីគាំទ្រដល់តួនាទីគ្រប់គ្រងរបស់សហគមន៍នេសាទ រដ្ឋបាលជលផលនិងអង្គការដៃគូនឹងជួយដល់សហគមន៍ក្នុងការបង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រង ការអភិវឌ្ឍដែននេសាទ និងការធ្វើអាជីវកម្មនេសាទប្រកបដោយនិរន្តរភាពនិងរួមចំណែកដល់សេដ្ឋកិច្ចជាតិ។ ដំណើរការនេះអាចធានាបានថាទីជម្រកដ៏សំខាន់ដូចជា ព្រៃលិចទឹកនិងព្រៃកោងកាងត្រូវបានកំណត់និងរៀបចំផែនទីឱ្យបានច្បាស់លាស់។ បញ្ហាប្រឈមដូចជាទំនាស់ជាអន្តរវិស័យរវាងការបង្កើនសកម្មភាពកសិកម្មដើម្បីបង្កបង្កើនផលស្រូវនិងការថែរក្សាគុណភាពទឹកសម្រាប់ធនធានជលផល និងការ







ថែរក្សាទីជម្រក នឹងត្រូវដោះស្រាយបានតាមរយៈក្រុមការងារបច្ចេកទេសចម្រុះស្តីពី កំណែទម្រង់វិស័យជលផល ដែលមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធនានា។ សូចនាករសំខាន់ៗសម្រាប់ការថែរក្សាដែននេសាទឱ្យបានល្អ នឹងត្រូវកំណត់ឡើងនិងធ្វើការតាមដាននិងវាយតម្លៃក្នុងពេលកំណត់មួយ។ ការយល់ដឹងនេះ នឹងធ្វើការឆ្លុះបញ្ចាំង នៅក្នុងការរៀបចំផែនការវិស័យស្របតាមសភាពការណ៍ជាក់ស្តែង។

ការដាំព្រៃលិចទឹកនិងព្រៃកោងកាងឡើងវិញនឹងត្រូវបានទទួលនូវការគាំទ្រ ដើម្បីផ្តល់នូវមូលដ្ឋាននៃការលូតលាស់ប្រកបដោយនិរន្តរភាពនៃធនធានជលផល។ ភ្នាក់ងារអភិវឌ្ឍន៍នឹងបំពេញការងារយ៉ាងជិតស្និទ្ធជាមួយសហ-គមន៍ដើម្បីបង្កើតនិងការពារតំបន់អភិរក្សទាំងទឹកសាបនិងសមុទ្រ ជាពិសេស តំបន់អភិរក្សថ្មីនឹងត្រូវបង្កើតឡើងបន្ថែម ហើយត្រូវគ្រប់គ្រងនិងការពារស្របតាមការកែទម្រង់ស៊ីជម្រៅនៃវិស័យជលផល។

ការផ្សព្វផ្សាយនូវការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃជីវសាស្ត្រវារិជាត និងការអភិរក្សសម្រាប់ជាផលប្រយោជន៍សេដ្ឋកិច្ចសន្តិសុខស្បៀង និងជីវភាពរស់នៅនឹងត្រូវធ្វើឡើងនៅក្នុងសហគមន៍ ថ្នាក់ជាតិ និងតាមសាលារៀន។ ការផ្សព្វផ្សាយនឹងគូសបញ្ជាក់អំពីប្រភេទវារិជាតដែលងាយរងគ្រោះ ហើយជួយដល់សហគមន៍ និងវិស័យឯកជនដើម្បីរៀបចំយុទ្ធសាស្ត្រកាត់បន្ថយសម្ពាធទៅលើធនធានទាំងនោះ។ការយល់ដឹងអំពីសារៈសំខាន់នៃទីជម្រកដ៏សំខាន់ទាំងនេះ នឹងត្រូវផ្សព្វផ្សាយឱ្យទូលំទូលាយ ដើម្បីធានាបាននូវការយល់ដឹង ការអនុវត្តតាមបទប្បញ្ញត្តិពាក់-ព័ន្ធនឹងការគ្រប់គ្រងធនធានទាំងនេះ។ រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងភ្នាក់ងារនានាដើម្បីធានាថា ច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងដែននេសាទ គឺមានភាពសមស្របតាមការចាំបាច់របស់វិស័យជលផល និងស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល។ ច្បាប់ថ្មីនឹងត្រូវរៀបចំឡើងនិងអនុវត្តតាមការចាំបាច់។ រដ្ឋបាលជលផលក៏នឹងបំពេញការងារជាមួយភ្នាក់ងារផ្សេងទៀត ដើម្បីគាំទ្រដល់សហគមន៍ក្នុងការយល់ដឹងអំពី សារៈសំខាន់នៃការធ្វើនេសាទប្រកបដោយនិរន្តរភាព និងជួយដល់សហគមន៍ក្នុងការអនុវត្តឱ្យបានល្អ ព្រមទាំងលើកកម្ពស់សមភាពយេនឌ័រនិងប្រឈមមុខលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផលផងដែរ។

តាមរយៈការស្រាវជ្រាវ រដ្ឋបាលជលផលនឹងប្រមូលបាននូវព័ត៌មានចាំបាច់សម្រាប់រៀបចំនិងអនុវត្តនូវគោលនយោបាយពាក់ព័ន្ធនឹងនេសាទទឹកសាបនិងនេសាទសមុទ្រ។ កិច្ចការនេះ មិនត្រឹមតែធ្វើឱ្យប្រសើរឡើងនូវផលិតផល និងបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែវាក៏ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌសេដ្ឋកិច្ចសង្គមរបស់អ្នកនេសាទ និងបង្ហាញពីរបៀបនៃការធ្វើឱ្យប្រសើរឡើងស្របតាមគោលដៅនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ តួនាទីស្ត្រីនិងកុមារនៅក្នុង







វិស័យជលផលនឹងត្រូវធ្វើការស្រាវជ្រាវ ហើយច្បាប់និងគោលនយោបាយសមស្របនឹងត្រូវរៀបចំឡើង ដើម្បីធានាថាពួកគេទទួលបាននូវយុត្តិធម៌ ស្របតាមស្តង់ដារអន្តរជាតិ ដូចជាអនុវត្តគោលការណ៍ណែនាំរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ ស្តីពីពលកម្មកុមារក្នុងវិស័យជលផល និងវារីវប្បកម្ម។

ការយល់ដឹងអំពីធនធានជលផលតាមវាលស្រែបានច្បាស់លាស់និងនេសាទទឹកសាប នៅតំបន់ដែននេសាទផ្សេងទៀតនឹងពង្រឹងបាននូវយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍន៍។ ការកែលម្អនូវវិធីសាស្ត្រប៉ាន់ប្រមាណនូវសក្តានុពលនៃផលនេសាទ និងផលនេសាទដែលអាចចាប់បានជាក់ស្តែង ពីគ្រប់ប្រភពនៃការនេសាទនឹងត្រូវរៀបចំឡើងនៅក្នុងរយៈពេលខ្លីនិងមធ្យម ដើម្បីធ្វើឱ្យបានប្រសើរឡើងនូវដំណើរការនៃការគ្រប់គ្រង។ រដ្ឋបាលជលផលនឹងធ្វើបច្ចុប្បន្នភាពជាប្រចាំ និងកែលម្អស្ថិតិផលចាប់ទាំងទឹកសាបនិងសមុទ្រ ដើម្បីផ្តល់ជូនដល់អ្នកតាក់តែងគោលនយោបាយជាមួយនឹងការណែនាំអំពីយុទ្ធសាស្ត្រនៃការគ្រប់គ្រងជលផល។ កិច្ចការនេះក៏នឹងធ្វើការតាមដាននូវប្រភេទនិងទីជម្រកសំខាន់ៗ ដើម្បីធានាថា ប្រព័ន្ធអេកូឡូស៊ីនៅតែមានស្ថានភាពល្អ។ លើសពីនេះ ត្រូវធ្វើការជាមួយនឹងសហគមន៍ ដើម្បីបណ្តុះបណ្តាលពួកគាត់អំពីរបៀបតាមដាន និងការវាយតម្លៃធនធានជលផល ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានធម្មជាតិ។ រដ្ឋបាលជលផលក៏នឹងធ្វើការជាមួយនឹងភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀតនិងសហគមន៍ ដើម្បីកំណត់នូវតំបន់ដែលអាចរៀបចំជាស្រះជម្រកត្រីសហគមន៍បាន ជាពិសេស ចំពោះប្រភេទត្រីកម្រ និងរក្សាបាននូវទីជម្រក ដូចនេះ គឺអាចធានាបាននូវនិរន្តរភាពជីវចម្រុះ។ រដ្ឋបាលជលផល ដោយរួមសហការជាដៃគូផ្សេងទៀតនឹងធ្វើការដោះស្រាយនូវបញ្ហាព្រៃលិចទឹកនិងព្រៃកោងកាង ដែលត្រូវបានកាប់បំផ្លាញនិងរេចរឹលដែលរួមចំណែកដល់ការគ្រប់គ្រង និងអភិរក្សប្រកបដោយនិរន្តរភាព តាមរយៈការអនុវត្តយុទ្ធសាស្ត្រជាតិរេដបូកជាតិ[៦]។ រដ្ឋបាលជលផលក៏នឹងគាំទ្រផងដែរដល់ការគ្រប់គ្រងសត្វក្រពើព្រៃ និងទីជម្រករបស់វា ហើយសហការនៅក្នុងថ្នាក់តំបន់អំពីការគ្រប់គ្រងនិងការប្រើប្រាស់។

---

*[៦]ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការការបាត់បង់និងរេចរឹលព្រៃឈើ គឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតឡើងនូវតម្លៃហិរញ្ញវត្ថុ សម្រាប់ស្តុកទុកឧស្ម័នកាបូនិចនៅក្នុងព្រៃ ដោយផ្តល់នូវប្រាក់លើកទឹកចិត្តក្នុងការកាត់បន្ថយឧស្ម័នដោយរក្សាព្រៃឈើនិងការវិនិយោគ ធ្វើការបញ្ចេញកាបោនតិចតួច ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ រេដបូកជាតិជាកម្មវិធីមួយមិនត្រឹមតែទប់ស្កាត់មិនឱ្យកាប់ព្រៃឈើ និងរក្សាព្រៃមិនឱ្យរេចរឹលប៉ុណ្ណោះទេ ប៉ុន្តែវារួមបញ្ចូលនូវតួនាទីនៃការអភិរក្សនិងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងលើកទឹកចិត្តឱ្យមានការស្តុកឧស្ម័នកាបូនិចនៅក្នុងព្រៃឈើ។*













រដ្ឋបាលជលផលក៏នឹងចូលរួមចំណែកដល់គោលនយោបាយអភិវឌ្ឍន៍ដ៏ទូលំទូលាយផងដែរ តាមរយៈការស្រាវជ្រាវអំពី បញ្ហាឆ្លងដែនពាក់ព័ន្ធនឹងការគ្រប់គ្រងជលផល ដូចជាត្រីសំខាន់ៗ ប្រភពនិងគុណភាពនៃធាតុចូលសម្រាប់វារីវប្បកម្ម ជំងឺត្រី និងការប្រែប្រួលទីជម្រក។ រដ្ឋបាលជលផលនឹងបំពេញការងារយ៉ាងជិតស្និទ្ធជាមួយនឹងគណៈកម្មការទន្លេមេគង្គអំពីបញ្ហាឆ្លងដែននេះ។ រដ្ឋបាលជលផលនឹងស្រាវជ្រាវអំពីការជះឥទ្ធិពលដោយសារវារីអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតដូចជាផ្លូវថ្នល់ ប្រឡាយ និងមុខទឹកមកលើព្រៃលិចទឹកនិងធនធានជលផល។ រដ្ឋបាលជលផលនឹងគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធណា ដែលមិនមានផលប៉ះពាល់ដល់ធនធានជលផល។ រដ្ឋបាលជលផលនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងគណៈកម្មការទន្លេមេគង្គនិងអង្គការថ្នាក់តំបន់ផ្សេងទៀត ដើម្បីធានាថា ការជះឥទ្ធិពលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់តំបន់ មកលើធនធានជលផលត្រូវបានយល់ដឹងយ៉ាងច្បាស់និងបានចងក្រងជាឯកសារត្រឹមត្រូវ ហើយនិរន្តរភាពនៃធនធានជលផលត្រូវបានធានា តាមរយៈជម្រើសនិងអភិក្រមដ៏សមស្រប។

រដ្ឋបាលជលផលនឹងធ្វើការស្រាវជ្រាវផងដែរ អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើជលផលទឹកសាបនិងសមុទ្រដែលពាក់ព័ន្ធនឹងបញ្ហាជីវសាស្ត្រនិងសេដ្ឋកិច្ចសង្គម ហើយនឹងផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលអំពីជម្រើសនានា ដើម្បីកាត់បន្ថយនិងទប់ទល់នឹងការជះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ជាពិសេស នឹងធ្វើការជាមួយសហគមន៍មូលដ្ឋាននៅតំបន់ឆ្នេរនិងតំបន់ទឹកសាប ដើម្បីពង្រឹងសមត្ថភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុតាមរយៈជម្រើសនានានៃមុខរបរចិញ្ចឹមជីវិត ដូចជាទេសចរណ៍ធម្មជាតិ ដែលជួយដល់សហគមន៍ក្នុងការពង្រឹងនូវសេដ្ឋកិច្ចនៅមូលដ្ឋានរបស់ខ្លួន ហើយធ្វើឱ្យសហគមន៍អាចកាត់បន្ថយបាននូវការពឹងផ្អែកទៅលើតែធនធានជលផលមួយមុខប៉ុណ្ណោះ។ ផែនការដើម្បីដោះស្រាយនូវផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់ដែលបណ្តាលមកពីកត្តាផ្សេងទៀត ដូចជាការសាងសង់ទំនប់វារីអគ្គិសនីនឹងត្រូវរៀបចំនិងអនុវត្ត។







បន្ថែមទៅនឹងការបង្កើតនូវចំណេះដឹងថ្មីៗរដ្ឋបាលជលផលនឹងធ្វើការផ្សព្វផ្សាយតាមរយៈការរៀបចំអត្ថបទបច្ចេក-ទេសឯកសារគោលនយោបាយនិងព័ត៌មានសមស្រប។ កិច្ចការនេះ គឺផ្តល់លទ្ធភាពដល់សហគមន៍និងអ្នកពាក់ព័ន្ធអាចទទួលបាននូវព័ត៌មានថ្មីៗដែលគាំទ្រដល់ការគ្រប់គ្រងចំណេះដឹងដ៏មានប្រសិទ្ធភាព។

## វារីវប្បកម្មទឹកសាបនិងសមុទ្រ

កាលពីអតីតកាលនៅកម្ពុជាវារីវប្បកម្មពុំមានតួនាទីសំខាន់នៅក្នុងវិស័យជលផលឡើយ ពីព្រោះកម្ពុជាសម្បូរត្រីពីធម្មជាតិ។ទោះជាយ៉ាងនេះក្តីបច្ចុប្បន្ននេះដោយសារផលនេសាទទឹកសាបមានការថយចុះដូច្នេះដើម្បីបំពេញនូវតម្រូវការដែលកើនឡើង គឺចាំបាច់ត្រូវមានប្រភពថ្មីបន្ថែម។ ដើម្បីឱ្យផលិតផលវារីវប្បកម្មមានការកើនឡើងក្នុងអត្រាមួយស្របតាមតម្រូវការនៃកំណើនចំនួនប្រជាពលរដ្ឋនិងទីផ្សារក្នុងតំបន់ នោះវារីវប្បកម្មនឹងត្រូវតែពង្រីកនូវសកម្មភាពឱ្យបានលឿនថែមទៀត។ លើសពីនេះ កំណើនសេដ្ឋកិច្ចដែលជាការចូលរួមចំណែករបស់វិស័យជលផលចំពោះផលិតផលសរុបក្នុងស្រុក គឺអាចបានមកពីតម្លៃបន្ថែម តាមរយៈការធ្វើពិពិធកម្មនិងការផ្តោតលើទ្រង់ទ្រាយជាលក្ខណៈពាណិជ្ជកម្មនៃវិស័យវារីវប្បកម្ម។ ទោះជាយ៉ាងនេះក្តី កិច្ចការនេះគឺត្រូវគិតគូរអំពីនិរន្តរភាព។ រដ្ឋបាលជលផលនឹងអនុម័តកម្មវិធីមួយពាក់ព័ន្ធនឹងការធ្វើប្រពលវប្បកម្មប្រកបដោយនិរន្តរភាពនៃវារីវប្បកម្មនៅគ្រប់ទ្រង់ទ្រាយ។

ការលើកកម្ពស់វារីវប្បកម្ម គឺបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្ម។ គោលដៅនៃផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្ម គឺវិស័យវារីវប្បកម្មមួយដែលមានលក្ខណៈពាណិជ្ជកម្មនិងប្រកបដោយនិរន្តរភាពដោយរួមចំណែកដល់សុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភ ការអភិវឌ្ឍសេដ្ឋកិច្ច ផលិតផលសរុបក្នុងស្រុក និងការនាំចេញ។

ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្មបានកំណត់នូវគោលដៅជាយុទ្ធសាស្ត្រចំនួន៧ ដើម្បីជាមគ្គុទេសក៍ដល់ការអភិវឌ្ឍនេះ។ គោលដៅទាំងនេះរួមមានដូចខាងក្រោម៖

១. បង្កើនការផ្គត់ផ្គង់នូវកូនត្រីពូជដែលមានគុណភាពខ្ពស់សម្រាប់ប្រភេទត្រីដែលជាតម្រូវការរបស់មូលដ្ឋានថ្នាក់តំបន់និងទីផ្សារពិភពលោក។

២. បង្កើនការផ្គត់ផ្គង់ទឹកប្រកបដោយគុណភាពខ្ពស់ គ្រប់គ្រាន់និងជាប់លាប់ និងកាត់បន្ថយនូវហានិភ័យ ដែលកើតឡើងដោយទឹកជំនន់។

៣.ធានាបានប្រភពផ្គត់ផ្គង់ តម្លៃសមស្រប និងគុណភាពចំណីដែលមានគុណភាពខ្ពស់សមស្របតាមប្រភេទត្រីនានាដែលចិញ្ចឹម។







៤. ធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាព ផលចំណេញនិងនិរន្តរភាពនៃផលិតផលវារីវប្បកម្ម តាមរយៈការបង្កើននូវចំណេះដឹង ជំនាញ និងសមត្ថភាពអង្គភាព។

៥. រក្សាបាននូវគុណភាពបរិស្ថាននិងកាត់បន្ថយនូវការបាត់បង់ដោយសារជំងឺ។

៦. បង្កើននូវគុណភាពនិងតម្លៃរបស់ផលិតផល។

៧.សម្របសម្រួលការស្វែងរកនូវឥណទាន ដែលមានលក្ខណៈសមស្របតាមតម្រូវការ សក្តានុពល និងគិតគូរអំពីហានិភ័យដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវារីវប្បកម្ម។

ចំណុចសំខាន់នៃផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្ម គឺផ្តែកលើការអភិវឌ្ឍតាមបែបពិពិធកម្មវារីវប្បកម្ម ដែលរួមទាំងការចិញ្ចឹមត្រីជាលក្ខណៈប្រពៃណីទ្រង់ទ្រាយតូច ដែលមានអ្នកចិញ្ចឹមប្រមាណ៤០.០០០គ្រួសារ និងវារីវប្បកម្មដែលមានគោលដៅពាណិជ្ជកម្មទាំងទ្រង់ទ្រាយតូច មធ្យម និងធំ។ កសិដ្ឋានជាលក្ខណៈពាណិជ្ជកម្មនឹងរួមចំណែកយ៉ាងសំខាន់ដល់ការលូតលាស់របស់វិស័យជលផលនៅក្នុងឆ្នាំខាងមុខ តាមរយៈការពង្រីកនូវសកម្មភាពរបស់ខ្លួននិងពង្រឹងតម្លៃបន្ថែម។ ផែនការសកម្មភាពនឹងត្រូវរៀបចំឡើងនៅឆ្នាំបន្ទាប់ ដើម្បីអនុវត្តនូវផែនការយុទ្ធសាស្ត្រនេះ។ ការវាយតម្លៃនឹងត្រូវធ្វើឡើងចំពោះផ្នែកសំខាន់ៗ ហើយគូសបញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ននៃវារីវប្បកម្មនៅក្នុងប្រទេសដើម្បីជួយដល់ការរៀបចំផែនការអនាគត។

ការកើនឡើងនូវផលិតផលវារីវប្បកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុកភាគច្រើន គឺបានមកពីវារីវប្បកម្មទ្រង់ទ្រាយតូចនិងមធ្យម ដែលក្នុងនោះមានរួមទាំងវារីវប្បកម្មវារីសត្វដទៃទៀតផងដែរ។ បច្ចេកទេសក្នុងការគាំទ្រដល់ការអនុវត្តល្អនូវប្រព័ន្ធផលិតកម្មវារីវប្បកម្មទ្រង់ទ្រាយតូច គឺត្រូវបានរៀបចំឡើងនៅកម្ពុជា ហើយនឹងត្រូវពង្រីកបន្ថែមនូវចំនួនគ្រួសារនិងការងារ តាមរយៈភាពជាដៃគូរវាងរដ្ឋបាលជលផលនិងភ្នាក់ងារអភិវឌ្ឍន៍នានា។ ការធ្វើឱ្យប្រសើរឡើងនូវគុណភាពនិងសេវាកម្មផ្គត់ផ្គង់ចំណីនិងកូនត្រីនឹងបង្កើនបាននូវផលិតភាព។ នៅទីកន្លែងណាដែលមានលទ្ធភាពអាចធ្វើបាន ការគ្រប់គ្រងដីនិងទឹកសម្រាប់គោលបំណងវារីវប្បកម្មនឹងត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត ដើម្បីធានាបាននូវដីនិងទឹកដែលអាចប្រើប្រាស់សម្រាប់វារីវប្បកម្មបានពេញក្នុងឆ្នាំនីមួយៗ។ រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងភ្នាក់ងារនានានិងវិស័យឯកជន ដើម្បីជួយស្វែងរកដីនិងប្រភពទឹកសមស្របសម្រាប់វារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។ កិច្ចការនេះ នឹងស្វែងរកជម្រើសនានាសម្រាប់ការពារគ្រោះទឹកជំនន់ដែលត្រូវចំណាយទាបនិងធ្វើការជាមួយនឹងភ្នាក់ងារអន្តរជាតិ ដើម្បីធានាការព្យាករណ៍និងការគ្រប់គ្រងលំហូរទឹកទន្លេដែលហូរចូលមកកម្ពុជា។ កម្មវិធីរៀបចំស្រះជម្រកត្រីសហគមន៍ ត្រូវបានអនុវត្តនៅក្រោមក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ៥ឆ្នាំកន្លងទៅ ហើយនឹងបន្តអនុវត្ត ដើម្បីធានាបាននូវផលិតភាពនៃជលផលតាមវាលស្រែនិងបង្កើនបាននូវផល







នេសាទពីធម្មជាតិ (សសរស្តម្ភទី១)។

ការស្រាវជ្រាវនឹងត្រូវធ្វើឡើង ដើម្បីបង្កើនការយល់ឱ្យកាន់តែប្រសើរឡើងអំពីតួនាទីរបស់ស្ត្រីក្នុងការចិញ្ចឹមត្រី ហើយយុទ្ធសាស្ត្រសម្រាប់ជំរុញការងារនេះនឹងត្រូវរៀបចំឡើង។ លើសពីនេះ ការគាំទ្រនឹងផ្តល់នូវការរៀបចំអង្គភាពសម្រាប់កិច្ចសហប្រតិបត្តិការដ៏ទូលំទូលាយទូទាំងវិស័យ ដើម្បីធ្វើជាតំណាងឱ្យតម្រូវការនិងបំណងប្រាថ្នារបស់ភាគីពាក់ព័ន្ធនានានៅក្នុងវារីវប្បកម្មនិងដើម្បីធានាបានថា មតិយោបល់របស់ពួកគេនឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការរៀបចំគោលនយោបាយ។

ទោះបីជាយ៉ាងដូចនេះក្តី ការលូតលាស់ផ្នែកវារីវប្បកម្មភាគច្រើន គឺបានមកពីកសិដ្ឋានចិញ្ចឹមត្រីដែលមានតម្លៃខ្ពស់ជាលក្ខណៈពាណិជ្ជកម្មទ្រង់ទ្រាយតូចនិងមធ្យម ដែលការផលិតត្រីមានតម្លៃខ្ពស់សម្រាប់ទីផ្សារថ្នាក់តំបន់និងសកលលោក។ ដើម្បីសម្រេចបាននូវគោលដៅនេះ គឺទាមទារការវិនិយោគទុនពីវិស័យឯកជនទៅលើហេដ្ឋារចនាសម្ព័ន្ធនិងសម្រេចបាននូវប្រព័ន្ធផលិតកម្មមួយមានការទទួលស្គាល់។ ផ្អែកលើភាពចម្រុះនៃទីជម្រកនិងបរិស្ថាននៅកម្ពុជា ប្រពលវប្បកម្មវារីវប្បកម្មអាចធ្វើបានតាមបែបផ្សេងៗ និងមានការពាក់ព័ន្ធជាមួយនឹងបច្ចេកវិទ្យាស្មុគស្មាញ។ កិច្ចការនេះ គឺទាមទារការគាំទ្រពីរដ្ឋាភិបាលក្នុងការលើកទឹកចិត្តដល់ការវិនិយោគទុនដែលមានលក្ខណៈពាណិជ្ជកម្មនិងត្រូវកំណត់នឹងដោះស្រាយឱ្យបាននូវការលំបាកនានាដែលមាន ហើយកិច្ចការនេះត្រូវធ្វើឡើងតាមរយៈការចូលរួម ក្នុងនោះត្រូវបានលើកទឹកចិត្តដល់វិស័យឯកជនឱ្យចូលរួមនៅក្នុងការរៀបចំផែនការលម្អិតសម្រាប់ពង្រីកវិស័យវារីវប្បកម្ម។ កិច្ចការនេះនឹងរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ច ហើយអាចធានាបាននូវនិរន្តរភាពផលស្តុកត្រីធម្មជាតិ។ បទពិសោធន៍នឹងត្រូវរៀនសូត្រពីបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់ រួមមាន ថៃឡង់ វៀតណាម ចិន និងបង់ក្លាដេស ដោយផ្តោតលើកិច្ចសហប្រតិបត្តិការតំបន់ភាគខាងត្បូង។

ប្រព័ន្ធផលិតកម្មវារីវប្បកម្មទ្រង់ទ្រាយធំ ក៏ផ្តល់នូវកាលានុវត្តភាពសម្រាប់បង្កើនការរួមចំណែកដល់ផលិតផលសរុបក្នុងស្រុកផងដែរ។ នៅពេលដែលសហគមន៍សេដ្ឋកិច្ចអាស៊ានត្រូវបានបង្កើតឡើង ការវិនិយោគទុននៅកម្ពុជាពីបណ្តាប្រទេសជិតខាងនឹងមានការកើនឡើង ហើយកសិដ្ឋានចិញ្ចឹមត្រីខ្នាតមធ្យមនឹងត្រូវពង្រីក។ កិច្ចការនេះអាចនឹងជំរុញទៅមុខបានតាមរយៈការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសនៃធុរៈកិច្ចនិងព័ត៌មានអំពី កាលានុវត្តភាពនៃការវិនិយោគ។ បន្ថែមទៅលើការគាំទ្រដោយផ្ទាល់ ការគាំទ្រផ្នែកច្បាប់ពាក់ព័ន្ធនឹងការត្រួតពិនិត្យគុណភាពធាតុចូលនិងផលិតផលវារីវប្បកម្មតាមស្តង់ដារជាពិសេសចំពោះធាតុចូល និងផលិតផលដែលនាំចូលមកពីបណ្តាប្រទេសជិត







ខាង។ រដ្ឋបាលជលផលនឹងបង្កើតឡើងនូវប្រព័ន្ធត្រួតពិនិត្យជំងឺនៅក្នុងវិស័យវារីវប្បកម្ម។ ការត្រួតពិនិត្យនេះនឹងត្រូវធ្វើឡើងចំពោះជំងឺដែលកើតមានក្នុងចំណោមប្រភេទត្រីរបស់កសិដ្ឋាន រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងវិស័យឯកជនដើម្បីធានាថានៅពេលកើតមានជំងឺ គឺបានដឹងភ្លាមៗហើយមានវិធានការទប់ស្កាត់ភ្លាមដែរ។ ការស្រាវជ្រាវនឹងត្រូវធ្វើឡើងដើម្បីកាត់បន្ថយការជះឥទ្ធិពលជាអវិជ្ជមាននៃជំងឺមកលើប្រព័ន្ធផលិតកម្មវារីវប្បកម្មជាតិ ដែលរួមមានការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មច្បាប់និងអធិការកិច្ច។ បញ្ហានេះចាំបាច់ត្រូវធានាថា ការអភិវឌ្ឍវារីវប្បកម្ម នៅកម្ពុជានឹងមិនផ្តល់នូវគុណវិបត្តិដែលកើតឡើងដោយសារទម្លាប់មិនល្អពីបណ្តាប្រទេសនានាឡើយ។ រដ្ឋបាលជល-ផលនិងភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀតមានតួនាទីយ៉ាងសំខាន់ ក្នុងការជួយដល់វារីវប្បកម្មទ្រង់ទ្រាយតូចនិងមធ្យមរបស់វិស័យឯកជនក្នុងស្រុក ឱ្យចូលរួមនៅក្នុងប្រព័ន្ធផលិតកម្មវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម តាមរយៈការផ្តល់នូវការណែនាំនិងការគាំទ្រ។

ការផលិតនិងការបែងចែកនូវកូនត្រីពូជនិងចំណីដែលមានគុណភាពខ្ពស់និងតម្លៃសមស្រប គឺត្រូវធានាជាបឋមតាមរយៈការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនូវជំងឺនិងគុណភាពនៃការនាំចូល។

នៅក្នុងរយៈពេលវែង កម្មវិធីជាតិនៃការអភិវឌ្ឍការគ្រប់គ្រងនិងការបែងចែកមេពូជត្រី ត្រូវរៀបចំឡើងដោយរដ្ឋបាលជលផលនិងភ្នាក់ងារអភិវឌ្ឍន៍នានាដើម្បីឱ្យវិស័យឯកជនយកទៅអនុវត្តនៅក្នុងរយៈពេលមធ្យម។ ធនធានជលផលនៅក្នុងធម្មជាតិនឹងត្រូវធ្វើឱ្យប្រសើរឡើងតាមរយៈការលែងកូនត្រីនិងមេពូជ ដែលសមស្របចូលនៅក្នុងដែនទឹកធម្មជាតិ។ ការអនុវត្តកម្មវិធីវារីវប្បកម្មតាមបែបពិពិធកម្ម គឺមានសារៈសំខាន់ក្នុងការដោះស្រាយបាននូវភាពមិនប្រែប្រួលនៅថ្ងៃអនាគត។ រដ្ឋបាលជលផលនឹងធ្វើការស្រាវជ្រាវនៅទីណាដែលចាំបាច់ ចំពោះបច្ចេកទេសវារីវប្បកម្មទឹកសាបនិងសមុទ្រ និងការបង្កើននូវផលិតផលវារីវប្បកម្មសម្រាប់ការផ្គត់ផ្គង់មេពូជ និងកូនត្រីចំពោះប្រភេទត្រីសំខាន់ៗ។

ទម្លាប់នៃការប្រើប្រាស់កូនត្រីដែលមានតម្លៃទាបធ្វើជាចំណីនៅក្នុងវារីវប្បកម្ម បណ្តាលឱ្យត្រីដែលប្រជាពលរដ្ឋប្រើប្រាស់ជាម្ហូបអាហារមានការថយចុះ ដូចនេះវិធីថ្មីសម្រាប់ដោះស្រាយបញ្ហាចំណីត្រីនឹងត្រូវធ្វើការស្រាវជ្រាវនិងពង្រីក។ ជាពិសេស ការអភិវឌ្ឍវារីវប្បកម្មត្រូវធានាបាននូវអត្រាតម្លៃបន្ថែមខ្ពស់ចំពោះគុណភាពនៃត្រីធម្មជាតិដែលប្រើជាចំណីត្រីនៅក្នុងវារីវប្បកម្ម។ ការចំណាយថ្លៃដើមទាបសម្រាប់ការផលិតចំណីត្រីនៅមូលដ្ឋាន គឺមានសារៈ-សំខាន់ចំពោះការធ្វើវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម ហើយការស្រាវជ្រាវនឹងត្រូវធ្វើឡើង ដើម្បីផលិតចំណីឱ្យបាន













សមស្របសម្រាប់ការចិញ្ចឹមប្រភេទត្រីក្នុងស្រុក។

មន្ត្រីនាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម នៃរដ្ឋបាលជលផលនឹងធ្វើការងារជិតស្និទ្ធជាមួយនឹងអ្នកជំនាញផ្នែកកែច្នៃផលនេសាទ ដើម្បីកំណត់នូវកាលានុវត្តភាពទីផ្សារលើកកម្ពស់តម្លៃសង្វាក់ផលិតកម្មជលផល។ កិច្ចការនេះមានសារៈសំខាន់ ជាពិសេស នៅពេលដែលឥទ្ធិពលនៃសហគមន៍សេដ្ឋកិច្ចអាស៊ានអំពីការវិនិយោគទុននិងទីផ្សារចាប់ផ្ដើមមានឥទ្ធិពលមកលើកម្ពុជា។

រដ្ឋបាលជលផលនឹងធ្វើការស្រាវជ្រាវអំពីផលប៉ះពាល់ចំពោះសង្គមសេដ្ឋកិច្ចនិងបរិស្ថានទៅតាមទ្រង់ទ្រាយ និងទម្រង់ផ្សេងៗនៃការអភិវឌ្ឍវារីវប្បកម្ម ដែលពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នៅក្នុងវិស័យនិងពាក់ព័ន្ធនឹងសន្តិសុខស្បៀងជាតិ ទីជម្រកសំខាន់ៗនៅទឹកសាបនិងសមុទ្រ ហើយដែលប៉ះពាល់ដល់គោលនយោ-បាយរបស់វិស័យ។

ការពង្រីកវារីវប្បកម្ម ទៅដល់កម្រិតនៃគោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម គឺទាមទារនូវតួនាទីដ៏ទូលំទូលាយថែមទៀតរបស់មន្ត្រីផ្សព្វផ្សាយ ក្នុងការបណ្ដុះបណ្ដាលដល់វិស័យឯកជននៅក្នុងផ្នែកបច្ចេកទេសនៃវារី-វប្បកម្ម។ រដ្ឋបាលជលផលមិនត្រឹមតែកសាងសមត្ថភាពរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែនឹងធ្វើការផ្សព្វផ្សាយចំណេះដឹងទៅវិស័យឯកជន ដើម្បីធានាថាការប្រកួតប្រជែងនឹងទទួលបាននូវផលប្រយោជន៍នៅក្នុងតំបន់។

## ខ្សែសង្វាក់ផលិតកម្មជលផល

ការកែច្នៃត្រីនៅកម្ពុជាភាគច្រើន គឺសម្រាប់តែការប្រើប្រាស់ក្នុងស្រុក ឬនាំចេញទៅទីផ្សារថ្នាក់តំបន់ដែលមានតម្លៃទាបប៉ុណ្ណោះ។ ការលក់ចេញបានតម្លៃទាបនេះ គឺដោយសារផលិតផលមានតម្លៃបន្ថែមតិចតួច ហើយការទុកដាក់និងកែច្នៃពុំមានអនាម័យល្អ។ លទ្ធភាពរបស់កម្ពុជាក្នុងការបង្កើននូវផលិតផលដែលបានមកពីផលចាប់ធម្មជាតិ ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចនិងដើម្បីដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភ ចំពោះការកើនឡើងនូវចំនួនប្រជាពលរដ្ឋ គឺមានការលំបាកដោយសារបញ្ហាផលិតផលពីធម្មជាតិមានកម្រិតកំណត់។ ចំណែកឯសក្ដានុពលនៃកំណើននៅក្នុងវិស័យជលផល គឺផ្អែកលើតម្លៃបន្ថែមទៅលើផលិតផលត្រី ជាពិសេសផលិតផលបានមកពីវារីវប្បកម្ម។







ការបង្កើនតម្លៃសេដ្ឋកិច្ចនិងតម្លៃប្រើប្រាស់សម្រាប់សង្គមពីផលិតផលត្រី តាមរយៈការអភិវឌ្ឍខ្សែសង្វាក់ផលិតកម្មជលផល គឺជាការចាំបាច់ក្នុងការសម្រេចបាននូវគោលដៅនៃកំណើន ហើយកសាងបាននូវគំរូដ៏ល្អសម្រាប់កិច្ចការជំនួញ។ នៅក្នុងវិស័យវារីវប្បកម្មគុណភាពនៃមេពូជ កូនត្រីពូជ និងចំណីនឹងត្រូវធ្វើឱ្យប្រសើរឡើងតាមរយៈការលើកកម្ពស់នូវការត្រួតពិនិត្យនូវការនាំចូលនិងពង្រឹងការគ្រប់គ្រងឱ្យបានល្អ ដែលនាំឱ្យបង្កើនបាននូវផលិតភាព និងមានផលចំណេញ។ ការធ្វើសមាហរណកម្មវារីវប្បកម្មជាមួយនឹងកសិកម្ម គឺទទួលបានផ្តល់នូវផលប្រយោជន៍ទៅវិញទៅមក ហើយកិច្ចការនេះ គឺត្រូវបានអនុវត្តបង្ហាញនៅថ្នាក់តំបន់។ រដ្ឋបាលជលផលនឹងរៀនសូត្រនូវបទពិសោធន៍ពីថ្នាក់តំបន់នេះ ហើយយកមកអនុវត្តនៅកន្លែងណាដែលសមស្របនៅកម្ពុជា។ ការអនុវត្តវារីវប្បកម្មល្អនិងធានាបាននូវនិរន្តរភាពនៃធនធានជលផល គឺជាកត្តាដ៏មានសារៈសំខាន់ចំពោះការបង្ហាញពីលក្ខណៈពិសេសនៃផលផលិតផលជលផលកម្ពុជា នៅក្នុងទីផ្សារប្រកួតប្រជែងថ្នាក់តំបន់។

រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងភ្នាក់ងារនានា និងវិស័យឯកជន ដើម្បីធានាបាននូវការអនុវត្តស្របតាមលក្ខខណ្ឌនៃផែនទីបង្ហាញផ្លូវរបស់អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) សម្រាប់ពាណិជ្ជកម្ម ២០១៤-២០១៨។ រដ្ឋបាលជលផលនឹងធានា ជាពិសេសចំពោះ៖

- ការអនុវត្តតាមស្តង់ដារ គុណភាពអនាម័យល្អ ក្នុងចំណោមអ្នកកែច្នៃផលិតផលជលផល ដែលនឹងផ្តល់នូវផលប្រយោជន៍ដល់ការនាំចេញទៅក្នុងទីផ្សារប្រកួតប្រជែង។
- ការទទួលស្គាល់គុណភាពនិងអនាម័យពីសហគមន៍អឺរ៉ុប អាចគាំទ្រដល់ការនាំចេញនូវផល ផលិតផលជលផលកម្ពុជាទៅទីផ្សារអឺរ៉ុបតាមគោលដៅដែលបានកំណត់សម្រាប់ឆ្នាំ២០១៨។
- សមាគមកែច្នៃផលផលិតផល ជលផលជាតិត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការវិស័យឯកជន ការវិនិយោគ និងការកែលម្អទិសដៅនៃការនាំចេញ។
- ការសម្របសម្រួលពាណិជ្ជកម្មនិងគោលការណ៍ណែនាំសម្រាប់ការនាំចេញនឹងត្រូវរៀបចំឡើងនៅក្នុងឆ្នាំ ២០១៥ ដោយរួមមានការណែនាំអំពី ការអនុវត្តតាមភូតគាមអនាម័យនិងចំណុចគ្រោះថ្នាក់សំខាន់ៗដែលត្រូវត្រួតពិនិត្យក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តនៅក្នុងវិស័យជលផលកម្ពុជា។
- កម្មវិធីចេញលិខិតបញ្ជាក់ដល់អ្នកកែច្នៃផលិតផលជលផលសមុទ្រត្រូវបានអនុវត្ត។
- គោលការណ៍ណែនាំអំពីបរិស្ថានត្រូវបានរៀបចំឡើងសម្រាប់អ្នកកែច្នៃផលនេសាទនិងអ្នកនាំចេញ។
- ការចរចានឹងប្រព្រឹត្តធ្វើឡើងដើម្បីសម្រេចបាននូវការលើកលែងពន្ធចំពោះគ្រប់ផលិតផលនាំចេញ។







- ឧស្សាហកម្មត្រូវបានគាំទ្រដើម្បីធ្វើពិពិធកម្មទីផ្សារនាំចេញផល ផលិតផលជលផល។

លើសពីនេះ រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងដៃគូអភិវឌ្ឍន៍នានានិងវិស័យឯកជន ដើម្បីធានាបាននូវការអនុវត្តតាមពិធីសារស្តីពីសមាហរណកម្មអាស៊ានសម្រាប់វិស័យជលផល ជាពិសេសផែនទីបង្ហាញផ្លូវសម្រាប់ការធ្វើសមាហរណកម្មនៃវិស័យជលផល។

កម្ពុជានឹងមានការលំបាកក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារនាំត្រីចេញ ជាមួយនឹងប្រទេសជិតខាងដែលមានលទ្ធភាពប្រសើរជាង។ រដ្ឋបាលជលផលនឹងស្រាវជ្រាវអំពីទីផ្សារដែលមានលក្ខណៈពិសេសដែលផលិតផលកម្ពុជាអាចប្រកួតប្រជែងបាន ហើយកិច្ចការនេះនឹងផ្តល់នូវព័ត៌មានសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍កន្លែងកែច្នៃនិងវារីវប្បកម្ម។ ចំណុចស្នូលនៃកិច្ចការនេះ គឺការធ្វើពិពិធកម្មផល ផលិតផលជលផលនិងការបង្កើតនូវតម្លៃបន្ថែមចំពោះទីផ្សារក្នុងស្រុកនិងនាំចេញ។ ការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជន នឹងអាចកំណត់បាននូវផ្នែកដែលអាចធ្វើការលើកទឹកចិត្ត ឬគាំទ្រ ដើម្បីលើកកម្ពស់ការពង្រីកវិស័យឯកជនឱ្យបានសមស្រប។ ជាពិសេស រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងភ្នាក់ងារនានា ដើម្បីរៀបចំនូវនីតិវិធីនិងច្បាប់នៃការវិនិយោគ។ កម្ពុជានឹងរៀនសូត្រនូវបទពិសោធន៍ពីបណ្តាប្រទេសជិតខាងក្នុងក្របខ័ណ្ឌអាស៊ាននិងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់។ ពាក់ព័ន្ធនឹងកិច្ចការនេះលិខិតបទដ្ឋានគតិយុត្តិនឹងត្រូវរៀបចំឡើងដើម្បីធានាបាននូវសុវត្ថិភាពគ្រប់គ្រាន់និងស្តង់ដារគុណភាពសមស្របតាមតម្រូវការទីផ្សារ។

រដ្ឋបាលជលផលនឹងធ្វើការវាយតម្លៃអំពី ខ្សែសង្វាក់ផលិតកម្មជលផលបច្ចុប្បន្ន និងរៀបចំផែនការយុទ្ធសាស្ត្រមួយសម្រាប់ការអភិវឌ្ឍខ្សែសង្វាក់ផលិតកម្ម ដោយផ្អែកលើផលិតកម្មទៅថ្ងៃអនាគតនិងកាលានុវត្តភាព និងបញ្ហាប្រឈមនៃទីផ្សារ។ ព័ត៌មានអំពីកាលានុវត្តភាពនៃទីផ្សារសម្រាប់ផលនេសាទនិងប្រព័ន្ធផលិតកម្មវារីវប្បកម្មនឹងត្រូវបង្កើតឡើងជាប្រចាំដើម្បីគាំទ្រដល់វិស័យឯកជនក្នុងការបង្កើតឡើងនូវកាលានុវត្តភាពនៃទីផ្សារឱ្យបានពេញលេញ។

សក្តានុពលនៃការធ្វើឱ្យការចំណាយថ្លៃដើមសម្រាប់ការនាំចូលត្រីទាប ដើម្បីបំពេញនូវសន្តិសុខស្បៀងក្នុងស្រុកនិងបង្កើនតម្លៃប្រភេទត្រីក្នុងស្រុកសម្រាប់ការនាំចេញនឹងត្រូវធ្វើការស្រាវជ្រាវ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រសន្តិសុខស្បៀងយ៉ាងទូលំទូលាយ។

ការលើកកម្ពស់គុណភាពការកែច្នៃ នៅក្នុងវិស័យជលផលនឹងកាន់តែមានសារៈសំខាន់ នៅពេលដែលកម្ពុជាចូលទៅក្នុងទីផ្សារបើកចំហជាមួយនឹងសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ការធានាបាននូវគុណភាពផលិតផលត្រីសម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងការនាំចេញបានសមស្របនិងមានសុវត្ថិភាពគ្រប់គ្រាន់ គឺជាកិច្ចការចាំបាច់។ ពាក់ព័ន្ធនឹង













ការងារនេះ គឺទាមទារការយល់ដឹងនិងការអនុវត្តតាមច្បាប់ស្តង់ដារនៃបណ្តាប្រទេសនាំចេញសំខាន់ៗ។ ប្រព័ន្ធសម្រាប់ការចុះបញ្ជីអធិការកិច្ច និងការធ្វើនិយតកម្មទីតាំងកែច្នៃត្រី នឹងត្រូវបង្កើតឡើងនិងអនុវត្ត។ តួនាទីនៃការនាំចូលត្រីដើម្បីដោះស្រាយនូវសន្តិសុខស្បៀងក៏នឹងត្រូវធ្វើការស្រាវជ្រាវហើយលទ្ធផលនៃការស្រាវជ្រាវនឹងត្រូវផ្តល់ជូនដល់អ្នករៀបចំគោលនយោបាយ។ ដើម្បីគាំទ្រដល់ច្បាប់ទាំងនេះ រដ្ឋបាលជលផលនឹងធ្វើការអភិវឌ្ឍសមត្ថភាពស្ថាប័ន សម្រាប់ផ្តល់នូវសេវាកម្មប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់និងរក្សាបានសុវត្ថិភាពនិងគុណភាព តាមស្តង់ដារនៃការផលិតត្រីនៅក្នុងប្រទេស។ រដ្ឋបាលជលផលគឺជាភ្នាក់ងារមានសមត្ថកិច្ចក្នុងការធានាបាននូវគុណភាពផល ផលិតផលជលផល ហើយនឹងធ្វើការជាមួយនឹងស្ថាប័នរបស់រាជរដ្ឋាភិបាលផ្សេងទៀត ក្នុងការផ្តល់និងរៀបចំឧបករណ៍ពិសោធន៍ សម្រាប់ធ្វើការវិភាគការត្រួតពិនិត្យគុណភាពត្រី ដើម្បីបំពេញនូវលក្ខខណ្ឌទីផ្សារនាំចេញទៅសហគមន៍អឺរ៉ុប។ រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងវិស័យឯកជននៅគ្រប់លំដាប់ថ្នាក់ ដើម្បីផ្សព្វផ្សាយចំណេះដឹងអំពី សុវត្ថិភាពអនាម័យ បច្ចេកទេសកែច្នៃ ការដឹកជញ្ជូន ការវេចខ្ចប់ និងការថែរក្សារាល់ផលផលិតផល ជលផល។ កិច្ចការនេះនឹងទាមទារឱ្យមានវគ្គបណ្តុះបណ្តាលស្តីពី អនាម័យនិងការអនុវត្តល្អនូវគ្រប់ដំណាក់កាលនៃខ្សែសង្វាក់ផលិតកម្ម។

រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងភ្នាក់ងារដទៃ ដើម្បីធានាថាប្រព័ន្ធត្រួតពិនិត្យការនាំចូលនិងការនាំចេញត្រូវបានបង្កើតឡើងនិងមានដំណើរការប្រកបដោយប្រសិទ្ធភាព។

រដ្ឋបាលជលផលនឹងរៀបចំសេវាកម្មអធិការកិច្ចជលផល ដើម្បីលើកកម្ពស់សុវត្ថិភាពនិងគុណភាពត្រីនាំចូលនិងនាំចេញ ដើម្បីធានាថាស្តង់ដាររបស់ខ្លួននឹងមានការកែលម្អឱ្យបានប្រសើរឡើងដូចស្តង់ដារថ្នាក់តំបន់និងថ្នាក់អន្តរជាតិ។

រដ្ឋបាលជលផលនឹងធ្វើការស្រាវជ្រាវអំពី ខ្សែសង្វាក់ផលិតកម្មជលផលតាមប្រភេទត្រីផ្សេងៗគ្នា និងស្រាវជ្រាវអំពីផលប៉ះពាល់ដែលបណ្តាលពីការប្រែប្រួលអាកាសធាតុមកលើវិស័យនេះផងដែរ។







លើសពីនេះ ការគាំទ្រនឹងត្រូវធ្វើឡើងដើម្បីរៀបចំអង្គភាពសម្រាប់កិច្ចសហប្រតិបត្តិការ ដើម្បីឱ្យមានតំណាងអំពីតម្រូវការនិងវត្ថុបំណងរបស់ភាគីពាក់ព័ន្ធ រួមជាមួយនឹងខ្សែសង្វាក់ផលិតកម្មនិងធានាបាននូវការចូលរួមក្នុងការរៀបចំគោលនយោបាយនិងការសម្រេចចិត្តនានា។

## ការធ្វើនិយតកម្មនិងសេវាកម្ម

ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន រដ្ឋបាលជលផលតម្រូវឱ្យមានក្របខ័ណ្ឌនិយតកម្ម ហិរញ្ញវត្ថុ និងផែនការដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាពនិងធានាថា ការអនុវត្តមានប្រសិទ្ធភាពនិងមានការរីកចម្រើន។ ការតាមដាននិងការវាយតម្លៃចំពោះការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល គឺជាការចាំបាច់សម្រាប់វាយតម្លៃពីភាពជោគជ័យហើយកិច្ចការនេះត្រូវបានចាត់ទុកជាការងារអាទិភាពរបស់រដ្ឋបាលជលផលនិងដៃគូអភិវឌ្ឍន៍។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ទទួលស្គាល់ពីសារៈសំខាន់នៃការត្រួតពិនិត្យបទល្មើសនេសាទ សកម្មភាពពាណិជ្ជកម្ម ការកែច្នៃ និងការបំផ្លាញទីជម្រក។ ការធ្វើនិយតកម្មនៃវិស័យជលផលត្រូវបានចាត់ទុកជាអាទិភាព ហើយជាមួយគ្នានេះ សហគមន៍នេសាទបានរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង ដែលកិច្ចការនេះគឺត្រូវការពេលវេលាសមស្របមួយ។ រដ្ឋបាលជលផលនឹងធ្វើការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធទាំងអស់។ កិច្ចការនេះ នឹងពង្រឹងបាននូវច្បាប់បច្ចុប្បន្ន ហើយធានាថាច្បាប់ត្រូវបានអនុវត្តនិងគោរព ជាពិសេសពាក់ព័ន្ធទៅនឹងការបំផ្លាញទីជម្រក ការនេសាទខុសច្បាប់ សកម្មភាពពាណិជ្ជកម្ម និងការកែច្នៃត្រី។ ដើម្បីសម្រេចបាននូវគោលដៅនេះ គឺទាមទារនូវកិច្ចសហការជាមួយនឹងស្ថាប័នរដ្ឋផ្សេងទៀតនិងជាមួយភាគីពាក់ព័ន្ធនៅក្នុងវិស័យឯកជននិងបណ្តាប្រទេសជិតខាង។ កិច្ចការដែលត្រូវយកចិត្តទុកដាក់មុនគេ គឺការបង្វែរទិសដៅទប់ស្កាត់សកម្មភាពនេសាទល្មើសច្បាប់តាមរយៈការកសាងសមត្ថភាពនៅក្នុងរដ្ឋបាលជលផល និងការពង្រឹងការអនុវត្តច្បាប់នៃវិស័យជលផលទាំងមូល ។ ការគាំទ្រក៏ត្រូវធ្វើឡើងផងដែរចំពោះវិស័យឯកជន ដើម្បីពង្រឹងការយល់ដឹងអំពីច្បាប់និងផលលំបាកដែលកើតឡើងពីការមិនគោរពច្បាប់។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទទួលស្គាល់ថា សមត្ថភាពរបស់រដ្ឋបាលជលផលនៅមានកម្រិតក្នុងការអនុវត្តតួនាទីដ៏លំបាករបស់ខ្លួនពាក់ពន្ធ័នឹងការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យជលផល។ ដូចនេះ រដ្ឋបាលជលផលចាំបាច់ត្រូវមានជំនាញថ្មី ដើម្បីដោះស្រាយបាននូវបញ្ហាប្រឈមដែលវិស័យជលផលជួបប្រទះ។ លើសពីនេះ ដំណើរការកែ







ទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានន័យថា តួនាទីរបស់បុគ្គលិកនៅក្នុងវិស័យជលផលនឹងមានការប្រែប្រួលនៅក្នុងពេលឆាប់ៗខាងមុខ។ នៅថ្ងៃអនាគត តួនាទីទាំងនេះនឹងមានការវិវដ្តទៅតាមការប្រែប្រួលគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងសម្ពាធមកលើវិស័យ ដែលទាមទារនូវវិធីសាស្ត្រគ្រប់គ្រងជំនាញនិងចំណេះដឹងថ្មី ដើម្បីរក្សាបាននូវការឈានទៅមុខរបស់វិស័យតាមទិសដៅត្រឹមត្រូវ។ ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សនឹងត្រូវរៀបចំឡើងនៅពេលអនាគត។ ក្របខ័ណ្ឌនេះនឹងត្រូវអនុវត្តនៅក្នុងបណ្ដាឆ្នាំខាងមុខ ដើម្បីផ្ដល់នូវភាពទន់ភ្លន់ ជំនាញ និងការប្ដេជ្ញាចិត្ត។ ចំណុចសំខាន់ក្នុងការជ្រើសរើសបុគ្គលិកនៅក្នុងរដ្ឋាភិបាលនិងវិស័យឯកជននៅក្នុងវិស័យជលផលនៅពេលអនាគតត្រូវធ្វើយ៉ាងណា ដើម្បីបង្ហាញថា វិស័យជលផលជាជម្រើសការងារយ៉ាងល្អ។ កិច្ចការនេះនឹងលើកទឹកចិត្តឱ្យពលរដ្ឋចូលរួមនៅក្នុងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសនៅក្នុងវិស័យជលផល។ ការរៀបចំក្របខ័ណ្ឌនេះនឹងត្រូវធ្វើឡើងដោយរួមបញ្ចូលនូវកម្មវិធីសិក្សានិងស្ថាប័នបណ្ដុះបណ្ដាល ដើម្បីធានាថា វគ្គបណ្ដុះបណ្ដាលទាំងនោះនឹងត្រូវធ្វើឡើងស្របតាមតម្រូវការរបស់វិស័យ។

គោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៅក្នុងវិស័យជលផលឆ្នាំ២០០៧ នឹងត្រូវធ្វើបច្ចុប្បន្នភាព ដើម្បីគិតគូរដល់ការប្រែប្រួលគោលនយោបាយនៅក្នុងវិស័យជលផល។ កិច្ចការនេះ នឹងផ្ដល់នូវមូលដ្ឋានសម្រាប់ ១). ការកើនឡើងនូវការយល់ដឹងអំពីយេនឌ័រ ២). ការធ្វើសមាហរណកម្មយេនឌ័រទៅក្នុងការរៀបចំផែនការ ការតាមដាននិងការវាយតម្លៃនៅក្នុងវិស័យជលផលទាំងមូល ៣). ធានាបាននូវការបំពេញតួនាទីរបស់ស្ត្រីយ៉ាងពេញលេញ និង យ៉ាងសកម្មនៅក្នុងការងាររបស់រដ្ឋបាលជលផល ៤). ធ្វើការជាមួយនឹងអនុវិស័យផ្សេងៗដើម្បីធានាថា ស្ត្រីនៅជនបទដើរតួនាទីយ៉ាងសកម្មនៅក្នុងវិស័យជលផលនិងទទួលបាននូវផលប្រយោជន៍ពីកិច្ចការនោះ និង ៥). ការចែករំលែកចំណេះដឹងជាមួយនឹងភ្នាក់ងារពាក់ព័ន្ធនៅក្នុងវិស័យជលផលអំពីបញ្ហាយេនឌ័រ គឺត្រូវសម្រេចឱ្យបាន។ លើសពីនេះ តួនាទីរបស់កុមារនិងបញ្ហាពលកម្មកុមារក្នុងវិស័យជលផលក៏នឹងធ្វើការវាយតម្លៃនិងរៀបចំជាយុទ្ធសាស្ត្រឱ្យបានសមស្របនិង អនុវត្តដើម្បីធានាថា ការជះឥទ្ធិពលអវិជ្ជមានមកលើកុមារត្រូវបានកាត់បន្ថយ។

ដើម្បីធានាបាននូវការបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព ការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល គឺទាមទារថវិកាគ្រប់គ្រាន់និងទាន់ពេលវេលា ក្នុងនោះត្រូវធានាបាននូវតម្លាភាពនិងគណនេយ្យភាពក្នុងការប្រើប្រាស់នូវថវិកានោះ។ ការព្យាករណ៍បានរំពឹងថា ក្នុងរយៈពេល១០ឆ្នាំបន្ទាប់ទៅទៀត ការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល គឺត្រូវការថវិកាចំនួន១៥០លានដុល្លារអាមេរិក។ អភិក្រមផ្អែកតាម







កម្មវិធីសម្រាប់វិស័យជលផលតម្រូវឱ្យរដ្ឋបាលជលផលត្រូវកំណត់នូវថវិកា ដែលត្រូវការនេះឱ្យស្របជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ រដ្ឋបាលជលផលនឹងបន្តតាមដានជាប់ជាប្រចាំនិងពិនិត្យមើលឡើងវិញនូវថវិកាសម្រាប់គាំទ្រដល់ការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល។រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងស្ថាប័នរដ្ឋនិងភ្នាក់ងារម្ចាស់ជំនួយ ដើម្បីស្វែងរកថវិកាឱ្យបានគ្រប់គ្រាន់សម្រាប់អនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ដើម្បីសម្រេចបាននូវគោលដៅរបស់អនុវកម្មវិធីទាំងអស់។ សមត្ថភាពរៀបចំថវិកាសម្រាប់សកម្មភាពអភិវឌ្ឍន៍នៅថ្នាក់ជាតិនិងនៅថ្នាក់ខណ្ឌរដ្ឋបាលជលផលនឹងត្រូវពង្រឹងឡើងនៅគ្រប់នាយកដ្ឋានជំនាញទាំងអស់។ រដ្ឋបាលជលផលនឹងធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព តាមរយៈការរាយការណ៍ជាប់ជាប្រចាំនូវការចំណាយថវិកាធៀបនឹងសកម្មភាពលទ្ធផល និងលទ្ធផលសម្រេចដែលបានលើកឡើង។

នៅក្នុងរយៈពេលវែង វិស័យជលផលមានគោលដៅឆ្ពោះទៅម្ចាស់ការហិរញ្ញវត្ថុ ហើយរដ្ឋបាលជលផលរួមជាមួយនឹងក្រសួងដទៃនិងវិស័យឯកជននឹងរៀបចំយុទ្ធសាស្ត្រមួយ ដើម្បីសម្រេចបាននូវគោលដៅនេះ។ យុទ្ធសាស្ត្រនេះរួមមានការលើកទឹកចិត្តនិងការគាំទ្រចំពោះការវិនិយោគរបស់វិស័យឯកជននៅក្នុងវិស័យជលផល ប្រកបដោយភាពច្នៃប្រឌិតក្នុងការសម្រេចបាននូវការផលិត ស្របតាមចំណុចដៅដែលបានគ្រោងទុក។

ការអភិវឌ្ឍវិស័យជលផលក្នុងការសម្រេចបាននូវចំណុចដៅរបស់ខ្លួន និងរួមចំណែកដល់ការអភិវឌ្ឍជាតិដ៏ទូលំទូលាយ គឺជាកិច្ចការដ៏លំបាកដែលទាមទារនូវការរៀបចំផែនការ ការសម្របសម្រួល ការគាំទ្រ និងការគ្រប់គ្រងឱ្យបានល្អ។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលបានរៀបចំនូវក្របខ័ណ្ឌអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅនេះ។ រដ្ឋបាលជលផលនឹងប្រែក្លាយក្របខ័ណ្ឌនេះ ឱ្យក្លាយទៅជាផលប្រយោជន៍និងឱ្យមានការរីកចម្រើននៅក្នុងវិស័យ។ កិច្ចការនេះ គឺទាមទារនូវកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងវិស័យផ្សេងទៀត ហើយត្រូវធានាថា បញ្ហារបស់វិស័យជលផលត្រូវបានគិតគូរពេញលេញនៅក្នុងការរៀបចំផែនការរបស់វិស័យដទៃ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពី កំណែទម្រង់វិស័យជលផលនិងស្ថាប័នសម្របសម្រួលផ្សេងទៀតនឹងដើរតួនាទីសំខាន់ចំពោះករណីនេះ។

រដ្ឋបាលជលផលនឹងអនុវត្តនូវតួនាទីបំពេញបន្ថែម ចំពោះក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលតាមរយៈការរៀបចំផែនការប្រចាំឆ្នាំ។ សមត្ថភាពក្នុងការរៀបចំផែនការនិងសកម្មភាពតាមដាននៅថ្នាក់ជាតិនិងថ្នាក់













ខណ្ឌរដ្ឋបាលជលផល នឹងត្រូវពង្រឹងឡើងនៅគ្រប់នាយកដ្ឋានជំនាញ។ រដ្ឋបាលជលផលនឹងធានានូវតម្លាភាពនិងគណនេយ្យភាព តាមរយៈរបាយការណ៍អំពីសកម្មភាពលទ្ធផលនិងសមិទ្ធផល។

រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងម្ចាស់ជំនួយ ភ្នាក់ងាររបស់រដ្ឋផ្សេងទៀត អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋាន ដើម្បីធានាបានថា ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនៅតែមានសុពលភាពនិងអាចសម្រេចបាន។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពី កំណែទម្រង់វិស័យជលផលនឹងដើរតួនាទីយ៉ាងសំខាន់ចំពោះបញ្ហានេះ។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនឹងត្រូវធ្វើបច្ចុប្បន្នភាព និងកែសម្រួលក្នុងរយៈពេលមួយកំណត់ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលតាមការចាំបាច់ និងដើម្បីទទួលយកនូវផែនការដែលអាចសម្របតាមកាលៈទេសៈ។ ពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយនឹងវិស័យនានា ការយកចិត្តទុកដាក់ជាចម្បង គឺផ្តោតទៅលើអន្តរកម្មនៃគោលនយោបាយជាអន្តរវិស័យនិងតម្រូវការនៃការពង្រឹងនូវកិច្ចសហការ និងការសម្របសម្រួលជាអន្តរវិស័យដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលវិស័យជលផលជួបប្រទះ។ ក្រុមការងារបច្ចេក-ទេសចម្រុះស្តីពី កំណែទម្រង់វិស័យជលផលនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញនិងគាំទ្រដល់អភិក្រមជាអន្តរវិស័យនេះ។ នៅទីណាដែលគោលនយោបាយមានការប្រទាំងប្រទើសគ្នា រដ្ឋបាលជលផលនឹងវាយតម្លៃបញ្ហាទាំងនោះ ហើយកំណត់នូវទិសដៅដ៏សមស្របបំផុតសម្រាប់អនុវត្តតាមវិស័យ។ ពាក់ព័ន្ធនឹងបញ្ហាថ្នាក់តំបន់ ការផ្តោតការយកចិត្តទុកដាក់គឺការធ្វើសមាហរណកម្មជាមួយនឹងសមាគមសេដ្ឋកិច្ចអាស៊ានដែលត្រូវចាត់ទុកជាការងារអាទិភាព។

សារៈសំខាន់នៃកិច្ចព្រមព្រៀងអន្តរជាតិចំពោះវិស័យជលផល គឺមានភាពកើនឡើង និងស្មុគស្មាញ។ ការវាយតម្លៃអំពី ការអនុវត្តកិច្ចព្រមព្រៀងទាំងនោះ នាពេលបច្ចុប្បន្ន នឹងត្រូវធ្វើឡើងដោយក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់វិស័យជលផល ហើយគោលការណ៍ណែនាំអំពីការពង្រឹងការអនុវត្តនូវកិច្ចព្រមព្រៀងទាំងនោះ នឹងត្រូវរៀបចំឡើង។













តួនាទីនៃកិច្ចសហប្រតិបត្តិការឆ្លងដែនរវាងកម្ពុជានិងបណ្តាប្រទេសជិតខាងជាប់ព្រំដែន នឹងក្លាយជាកិច្ចការដ៏សំខាន់។ រដ្ឋបាលជលផលដោយរួមសហការជាដៃគូជាមួយនឹងគណៈកម្មការទន្លេមេគង្គ តាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍន៍និងគ្រប់គ្រងធនធានជលផលនៅក្នុងអាងទន្លេមេគង្គ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាបាននូវការគ្រប់គ្រងដ៏ទូលំទូលាយទាំងនៅក្នុងតំបន់មេគង្គនិងតំបន់សមុទ្រ។ សារៈសំខាន់នៃកិច្ចការនេះនឹងកាន់តែមានការកើនឡើងនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍវារីអគ្គិសនី ភាពស្មុគស្មាញនៃការគ្រប់គ្រងជលផលឆ្លងដែន និងតម្រូវការពង្រីកសកម្មភាពសេដ្ឋកិច្ចតាមរយៈការចែករំលែកបច្ចេកវិទ្យា។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការរបស់រដ្ឋបាលជលផល សមត្ថភាពរបស់មន្ត្រីដែលបំពេញការងារតាមដាននិងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តផែនការរបស់វិស័យជលផលនឹងត្រូវពង្រឹង។ រដ្ឋបាលជលផលនឹងធ្វើការតាមដាននូវសូចនាករកម្រិតលទ្ធផលសម្រេច ហើយផ្តល់នូវការណែនាំអំពីការកែលម្អផែនការក្នុងគោលបំណង ដើម្បីសម្រេចបាននូវគោលដៅដ៏ទូលំទូលាយ។ សកម្មភាពតាមដាននិងវាយតម្លៃទាំងនេះ គឺជាមធ្យោបាយយ៉ាងសំខាន់ដែលផ្តល់ឱកាសដល់វិស័យឯកជន សហគមន៍និងក្រសួងផ្សេងៗអាចសម្តែងនូវទស្សនៈរបស់ខ្លួនចំពោះប្រសិទ្ធភាពនៃការបំពេញការងាររដ្ឋបាលជលផលនិងគោលនយោបាយ។

រដ្ឋបាលជលផលនឹងតាមដាននូវវឌ្ឍនភាពផ្អែកតាមគោលដៅ ដែលបានកំណត់ឡើងដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករតាមដាន និងត្រួតពិនិត្យរួមគ្នា។ រដ្ឋបាលជលផលនឹងរាយការណ៍ជាប់ជាប្រចាំអំពីការអនុវត្តនូវសកម្មភាព លទ្ធផល និងសមិទ្ធផលរបស់វិស័យជលផល។ វគ្គបណ្តុះបណ្តាលនឹងត្រូវធ្វើឡើងនៅទូទាំងវិស័យ ដើម្បីអនុវត្តការងារតាមដានឱ្យមានប្រសិទ្ធភាព។ រដ្ឋបាលជលផលនឹងរៀបចំគោលនយោបាយណែនាំនិងច្បាប់តាមសេចក្តីត្រូវការ ដើម្បីដោះស្រាយនូវតម្រូវការនៃការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល។







# ៥

# ការអនុវត្តអភិក្រមជាយុទ្ធសាស្ត្រ

រាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍នឹងគាំទ្រដល់វិស័យជលផលតាមរយៈអភិក្រមផ្អែកតាមកម្មវិធី។ អភិក្រមនេះនឹងទទួលស្គាល់នូវសារៈសំខាន់នៃការប្រែប្រួល ហើយនឹងធ្វើការសម្របនិងបត់បែនទៅតាមការប្រែប្រួលនោះ។ ករណីនេះ នឹងត្រូវណែនាំដោយគោលការណ៍ចាត់អាទិភាព ដែលបំពេញបន្ថែមនិងពង្រឹងដល់ក្រុមប្រតិបត្តិជលផលកម្ពុជា។ ករណីនេះនឹងមានការផ្សារភ្ជាប់នៅក្នុងដំណើរការនៃការរៀបចំផែនការវិស័យជលផល ជាពិសេស សកម្មភាពដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។ វឌ្ឍនភាពនៃការអនុវត្តនឹងត្រូវតាមដានជាប់ជាប្រចាំ ដើម្បីធានាថាសកម្មភាពទាំងនោះអាចដោះស្រាយបាននូវការប្រែប្រួលប្រកបដោយប្រសិទ្ធភាពនិងធានានូវផលសម្រេច។ ធនធានសម្រាប់ការអនុវត្តនឹងត្រូវធ្វើការវាយតម្លៃប្រចាំឆ្នាំនិងធ្វើការកែតម្រូវតាមការចាំបាច់។

## អភិក្រមផ្អែកតាមកម្មវិធី

រដ្ឋបាលជលផលបានចូលរួមក្នុងការរៀបចំអភិក្រមផ្អែកតាមកម្មវិធី ចំពោះវិស័យជលផលក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ អភិក្រមនេះមានការវិវដ្ត ពីព្រោះការគាំទ្រវិស័យជលផលកាលពីអតីតកាលមិនមានការសម្របសម្រួលបានល្អ គឺអនុវត្តតាមគោលបំណងរបស់ម្ចាស់ជំនួយ ការរៀបចំនិងអនុវត្តផែនការមិនមានប្រសិទ្ធភាពជាហេតុធ្វើឱ្យការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលមានភាពរប៉ាត់រប៉ាយ។ លើសពីនេះ ការគាំទ្រពីខាងក្រៅជារឿយៗ គឺអមដោយការបង្កើតនូវស្ថាប័នដែលត្រួតភារកិច្ច ជាហេតុធ្វើឱ្យផលសម្រេចនៃការអនុវត្តគម្រោងមិនមាននិរន្តរភាព ហើយបណ្តាលឱ្យការងាររដ្ឋបាលមានភាពទន់ខ្សោយ។

ផ្អែកលើផែនការសកម្មភាពឆ្នាំ២០០៤-២០០៨ ពាក់ព័ន្ធនឹងការធ្វើសុខដុមនីយកម្មនិងការតម្រឹម រដ្ឋាភិបាលបានអំពាវនាវឱ្យមានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈអភិក្រមផ្អែកតាមកម្មវិធីនិងបានដាក់បន្ទុកការទទួលខុសត្រូវដល់ក្រុមការងារបច្ចេកទេស។ ចាប់ពីពេលនោះមក រដ្ឋបាលជលផលនិងក្រុមការងារបច្ចេកទេសចម្រុះស្តីពី កំណែទម្រង់ជលផល បានជួយដល់វិស័យជលផលក្នុងការអនវុត្តតាមអភិក្រមផ្អែកតាមកម្មវិធីបានយ៉ាងល្អប្រសើរ។

ការអនុវត្តតាមអភិក្រមនេះ គឺទទួលបាននូវផលប្រយោជន៍ដែលឆ្លើយតបទៅនឹងការរៀបចំនិងការអនុវត្តនូវគោលនយោបាយបានទូលំទូលាយ ហើយអាចកាត់បន្ថយបាននូវការខ្វះចន្លោះពាក់ព័ន្ធនឹងគម្រោងទាំងឡាយ។ ការអនុវត្ត







តាមអភិក្រមផ្អែកលើកម្មវិធីនេះ គឺទទួលបាននូវប្រសិទ្ធភាពចំពោះការអភិវឌ្ឍបុគ្គលិកនិងការងារ ការធ្វើលទ្ធកម្ម ការរាយការណ៍ និងការគ្រប់គ្រងហិរញ្ញវត្ថុ។

ការអនុវត្តតាមអភិក្រមផ្អែកតាមកម្មវិធីនៅក្នុងវិស័យជលផលទទួលបានជោគជ័យ និងធ្វើឱ្យមានការប្រែប្រួលជាច្រើននិងសម្រេចបាននូវគោលដៅដែលបានគ្រោងទុក។ អភិក្រមនេះនឹងត្រូវអនុវត្តជាបន្តទៅទៀត នៅក្នុងរយៈពេលនៃសុពលភាពក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល។

## ការសម្របទៅនឹងការប្រែប្រួល

ការអនុវត្តអភិក្រមជាយុទ្ធសាស្ត្រចំពោះវិស័យជលផលនឹងជួបប្រទះនូវការប្រែប្រួលមិនទៀងទាត់។ ការប្រែប្រួលដែលមិនអាចគ្រោងទុកនេះ គឺមិនត្រឹមតែបណ្តាលមកពីការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែវាក៏បណ្តាលមកពីការប្រែប្រួលសេដ្ឋកិច្ចថ្នាក់តំបន់ និងពិភពលោកទៀតផង។ ការប្រែប្រួលនេះ គឺធ្វើឱ្យការរៀបចំផែនការវិស័យជលផលពិបាកក្នុងការប៉ាន់ស្មាន។ ចំពោះករណីនេះ គឺទាមទារនូវការរៀបចំផែនការវិស័យនិងការអនុវត្តមួយដែលអាចសម្របនិងទន់ភ្លន់តាមស្ថានភាពជាក់ស្តែង ដែលអាចឆ្លើយតបទៅនឹងការប្រែប្រួល ហើយរក្សាបាននូវគោលដៅយុទ្ធសាស្ត្រយូរអង្វែង។

## ការចាត់អាទិភាពតាមគោលការណ៍អភិវឌ្ឍន៍

ទោះបីជាវិស័យជលផលក្នុងពេលអនាគតនឹងជួបប្រទះនូវភាពមិនទៀងទាត់ក៏ដោយ ប៉ុន្តែយើងអាចរកវិធីស្រាយដោះស្រាយបាន ដោយបង្កើតនិងកំណត់នូវគោលការណ៍ច្បាស់លាស់សម្រាប់អនុវត្ត។ ទោះបីជាមានការប្រែប្រួលទៅថ្ងៃអនាគត ប៉ុន្តែគោលការណ៍នៅតែរក្សាដដែលក្នុងរយៈពេលនៃដំណើរការអនុវត្ត។

គោលការណ៍ចំនួន១០ត្រូវបានកំណត់ រួមមានដូចខាងក្រោម៖

១. ការកសាងភាពធន់ទ្រាំតាមរយៈការរៀបចំផែនការដែលអាចបត់បែននិងសម្របតាមកាលៈទេសៈ

២. ការទទួលខុសត្រូវនិងតម្លាភាពផ្អែកលើភ័ស្តុតាងជាក់លាក់

៣. ប្រតិបត្តិការនៅគ្រប់កម្រិត

៤. ការដោះស្រាយនូវគោលដៅមិនស៊ីសង្វាក់គ្នានិងធានាបាននូវភាពប្រទាក់ក្រឡាគ្នាល្អ

៥. ការធានាបាននូវនិរន្តរភាពនៃមុខងាររបស់ប្រព័ន្ធអេកូឡូស៊ី

៦.ការលើកកម្ពស់សិទ្ធិស្របច្បាប់និងការទទួលខុសត្រូវរបស់សហគមន៍និងបុគ្គលនីមួយៗ







៧. ដោះស្រាយនូវតម្រូវការនិងឆ្លើយតបទៅតាមបំណងប្រាថ្នារបស់សហគមន៍

៨. ស្វែងយល់អំពីភាពពឹងអាស្រ័យនៅក្នុងវិស័យនិងធ្វើឱ្យមានតុល្យភាពជាមួយនឹងជម្រើសមុខរបរ

៩. គិតគូរអំពីការចំណាយនិងផលចំណេញ ដោយរក្សាបាននូវនិរន្តរភាពនិងសមធម៌

១០. ការកសាងសមត្ថភាព

## ១. ការកសាងធាពធន់ទ្រាំ តាមរយៈការរៀបចំផែនការដែលអាចបត់បែននិងសម្របតាមកាលៈទេសៈ

នៅគ្រប់ប្រព័ន្ធនៃការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យជលផល ការប្រែប្រួលគឺជាផ្នែកមួយនៃដំណើរការដែលកើតឡើងមិនអាចជៀសផុតឡើយ។ ការប្រែប្រួលនេះនឹងស្តែងចេញយ៉ាងពិតប្រាកដនៅពេលដែលមានការប្រែប្រួលអាកាសធាតុ ភូមិសាស្ត្រ សេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់និងនយោបាយពិភពលោក ដែលមានឥទ្ធិពលមកដល់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

នៅពេលដែលភាពមិនទៀតទាត់មានកម្រិតកាន់តែខ្ពស់ លទ្ធភាពនៃការព្យាករណ៍ ការត្រៀមបម្រុង ការដោះស្រាយ និងការសម្របនៅនឹងការប្រែប្រួលកាន់តែមានភាពចាំបាច់។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលផ្តល់នូវទស្សនៈយូរអង្វែងសម្រាប់វិស័យ។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ គឺផ្សារភ្ជាប់និងគាំទ្រដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលមានភាពទន់ភ្លន់អាចសម្របទៅនឹងការប្រែប្រួលបាន។ ពាក់ព័ន្ធនឹងបញ្ហាប្រែប្រួលនេះ គឺចាំបាច់ត្រូវដាក់បញ្ចូលនៅក្នុងការរៀបចំផែនការរបស់វិស័យជលផល។ លើសពីនេះ ការរៀបចំផែនការដែលអាចសម្របបានតាមកាលៈទេសៈ គឺតម្រូវឱ្យមានការចូលរួមពីវិស័យឯកជននិងសហគមន៍ ដើម្បីស្វែងយល់ធ្វើការតាមដាននិងឆ្លើយតបនៅនឹងការប្រែប្រួល ហើយអាចធន់ទ្រាំបាន។

រដ្ឋបាលជលផលនឹងរៀបចំប្រព័ន្ធនិងអភិក្រម ដើម្បីរៀបចំផែនការដែលអាចសម្របបានតាមកាលៈទេសៈ។ កិច្ចការនេះរួមមានដំណើរការរៀបចំផែនការដែលអាចបត់បែនបាននៅក្នុងរដ្ឋបាលជលផល ដោយផ្អែកលើបទពិសោធន៍និងចំណេះដឹងដែលមានកន្លងមក។

## ២. ការទទួលខុសត្រូវនិងតម្លាភាពផ្អែកលើភ័ស្តុតាងជាក់លាក់

ភាពចាំបាច់សម្រាប់ការអភិវឌ្ឍវិស័យជលផលទៅថ្ងៃអនាគត គឺការសម្រេចចិត្តចំពោះការអភិវឌ្ឍទាំងឡាយណាដែលអាចឆ្លើយតបទៅនឹងការប្រែប្រួលរបស់វិស័យ ដោយផ្អែកលើភ័ស្តុតាងដែលមានមូលដ្ឋានជាក់លាក់។ ចំណេះដឹងជាមូលដ្ឋាននេះ នឹងត្រូវផ្អែកលើមធ្យោបាយចំនួន៣គឺ៖







- ភ័ស្តុតាងដែលទទួលបានពីការស្រាវជ្រាវ។
- ភ័ស្តុតាងដែលទទួលបានពីការងារតាមដាននិងវាយតម្លៃ។
- ភ័ស្តុតាងដែលទទួលបានពីការចូលរួមពិភាក្សាជាមួយនឹងសហគមន៍និងវិស័យឯកជន។

ភ័ស្តុតាងទាំងនេះ ដែលពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងសេដ្ឋកិច្ច គឺចាំបាច់ត្រូវដាក់បញ្ចូលនៅក្នុងគោលនយោបាយ ច្បាប់ ផែនការ និងយកមកអនុវត្តឱ្យមានប្រសិទ្ធភាព។

ភ័ស្តុតាងទាំងនេះ នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ផ្តល់នូវមតិយោបល់ដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មក្នុងការកែលម្អនិងជាពិសេសក្នុងការរៀបចំផែនការប្រចាំឆ្នាំនិងកែសម្រួលការអនុវត្ត។

ចំណេះដឹងនេះ នឹងធ្វើការចែករំលែកនៅក្នុងរដ្ឋបាលជលផលនិងនៅក្នុងវិស័យទាំងមូលឱ្យបានទូលំទូលាយជាប់ជាប្រចាំ ដើម្បីធានាថាអ្នកចូលរួមទាំងអស់ គឺទទួលបានព័ត៌មានពេញលេញ។ លើសពីនេះ ចំណេះដឹងទាំងនេះ នឹងត្រូវឆ្លុះបញ្ចាំងនៅក្នុងការពិនិត្យមើលឡើងវិញប្រចាំឆ្នាំ អំពីភាពពាក់ព័ន្ធនៃអនុកម្មវិធីនីមួយៗនៅក្នុងកម្មវិធីជលផលទាំងមូល ដែលជាផ្នែកនៃដំណើរការពិនិត្យមើលឡើងវិញនូវការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។

## ៣. ការប្រតិបត្តិការនៅគ្រប់កម្រិត

ជលផលកម្ពុជាមិនអាចដំណើរការទៅដាច់ដោយឡែកពីវិស័យដទៃនៅក្នុងខឿនសេដ្ឋកិច្ចជាតិទាំងមូល និងដាច់ដោយឡែកពីបណ្តាប្រទេសជិតខាង ឬដាច់ដោយឡែកពីឥទ្ធិពលនៃពិភពលោកបានឡើយ។ ទោះបីជា ការអភិវឌ្ឍវិស័យជលផល គឺយកចិត្តទុកដាក់ដល់សហគមន៍មូលដ្ឋាន តាមរយៈសហគមន៍នេសាទក៏ដោយ ប៉ុន្តែកិច្ចការនេះក៏ទទួលរងនូវឥទ្ធិពលពីកម្រិតថ្នាក់ផ្សេងៗផងដែរ។ ដំណើរការរៀបចំផែនការនៅថ្នាក់មូលដ្ឋាននិងនៅរដ្ឋបាលជលផលចាំបាច់ត្រូវផ្សារភ្ជាប់ជាមួយនឹងដំណើរការផែនការនៅថ្នាក់សហគមន៍ ដើម្បីធានាបានថា គោលនយោបាយវិស័យជលផលនិងគោលនយោបាយអភិវឌ្ឍន៍មូលដ្ឋាន គឺមានភាពប្រទាក់ក្រឡាគ្នា។

ប្រតិបត្តិការថ្នាក់តំបន់មានការជះឥទ្ធិពលមកលើវិស័យជលផលកម្ពុជា។ បឹងទន្លេសាបនិងទន្លេសាបមិនស្ថិតនៅដាច់ដោយឡែកពីប្រព័ន្ធវារិជាតដ៏ទូលំទូលាយឡើយ ហើយវាទទួលនូវការគំរាមកំហែងពីការប្រែប្រួលហេដ្ឋារចនាសម្ព័ន្ធដែលកម្ពុជាពុំមានសមត្ថភាពធ្វើការត្រួតពិនិត្យបាន។ គណៈកម្មការទន្លេមេគង្គដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលរវាងបណ្តាប្រទេសជាសមាជិកនៅក្នុងតំបន់ទន្លេមេគង្គទាំងអស់។ ដូចគ្នានេះដែរ ការប្រែប្រួលនៅ







ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន អាចនឹងធ្វើឱ្យមានការប្រែប្រួលទីផ្សារ ទុនវិនិយោគ ផ្លាស់ទីនៃពលកម្ម និងតម្រូវការនៃផលិតផលជលផលនៅថ្នាក់តំបន់។ ការប្រែប្រួលនេះនឹងត្រូវតាមដាននិងអនុវត្តតាមស្តង់ដារនិងបទដ្ឋានគតិយុត្តសមស្រប។

រដ្ឋបាលជលផលនឹងដើរតួនាទីយ៉ាងរឹងមាំក្នុងការស្វែងយល់ តាមរយៈការស្រាវជ្រាវអំពីការគំរាមកំហែងដែលអាចកើតមានឡើងពីការប្រែប្រួលក្នុងកម្រិតថ្នាក់ផ្សេងៗ ទាំងនេះហើយនឹងធ្វើឱ្យមានឥទ្ធិពលទៅលើដំណើរការសម្រេចចិត្តនៅថ្នាក់តំបន់ ដែលគាំទ្រដល់ជលផលកម្ពុជា។

### ៨. ការដោះស្រាយនូវគោលដៅមិនស៊ីសង្វាក់គ្នានិងធានាបាននូវភាពប្រទាក់ក្រឡាគ្នាល្អ

វិស័យជលផលមានគោលបំណងនិងគោលដៅច្បាស់លាស់។ ការកំណត់នូវគោលបំណងនិងគោលដៅច្បាស់លាស់នេះធ្វើឱ្យវិស័យជលផលទទួលបាននូវផលប្រយោជន៍យ៉ាងច្រើន។ ទោះបីជាយ៉ាងនេះក្តី ក្នុងកាលៈទេសៈខ្លះសមិទ្ធផលសម្រេចបានរបស់គោលបំណងមួយ ធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការសម្រេចបាននូវគោលបំណងផ្សេងទៀត។ ជាទូទៅ គោលបំណងនិងគោលដៅរបស់វិស័យមួយ គឺពាក់ព័ន្ធនឹងសកម្មភាពដ៏ទូលំទូលាយក្នុងបរិបទសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលមានឥទ្ធិពលទៅលើសមិទ្ធផលសម្រេចបានរបស់ខ្លួន។ កត្តាសំខាន់ដែលនាំមកនូវភាពជោគជ័យនៃការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល គឺការដោះស្រាយបាននូវការជះឥទ្ធិពលទៅវិញទៅមករវាងគោលបំណងនានានៅក្នុងវិស័យ បញ្ហាសំខាន់ថាតើទស្សនវិស័យនៃវិស័យជលផលនឹងសម្រេចបានតាមរបៀបណាដែលល្អបំផុត។

ការស្វែងយល់អំពីទំនាក់ទំនងរវាងវិស័យជលផលនិងវិស័យផ្សេងទៀត ដូចជាផលិតកម្មស្រូវ ការអភិវឌ្ឍឧស្សាហកម្ម ការគ្រប់គ្រងដីធ្លី ផលិតកម្មថាមពល និងការកសាងផ្លូវថ្នល់ គឺជាការចាំបាច់ ដើម្បីប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព។ នៅក្នុងថ្ងៃអនាគត ការធ្វើឱ្យមានតុល្យភាពរវាងផលត្រីដែលប្រើសម្រាប់សន្តិសុខស្បៀងនិងសម្រាប់ការនាំចេញ គឺជាបញ្ហាប្រឈមដ៏ចម្បងមួយ ជាពិសេស នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ ការងារស្រាវជ្រាវនឹងត្រូវធ្វើឡើង ដើម្បីពង្រឹងនូវការយល់ដឹងអំពីឥទ្ធិពលដែលនឹងកើតមានឡើងដោយកត្តាជាអន្តរវិស័យមកលើវិស័យជលផល។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មមានសារៈសំខាន់ ក្នុងការធានាបាននូវភាពប្រទាក់ក្រឡាគ្នានៅក្នុង







វិស័យកសិកម្មទាំងមូល ប៉ុន្តែរដ្ឋបាលជលផលនឹងចូលរួមចំណែកជាមួយនឹងគោលនយោបាយផ្សេងទៀតពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន ការប្រែប្រួលអាកាសធាតុ យេនឌ័រ ពលកម្មកុមារ និងការគ្រប់គ្រងហានិភ័យ។

រដ្ឋបាលជលផលនឹងធ្វើការងារយ៉ាងជិតស្និទ្ធក្នុងភាពជាដៃគូជាមួយនឹងក្រសួងស្ថាប័នដទៃ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីធានាថា តម្រូវការរបស់វិស័យត្រូវបានយល់ដឹងពីអ្នកពាក់ព័ន្ធទាំងនោះ ហើយត្រូវបានដោះស្រាយ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពី កំណែទម្រង់ជលផលនឹងបំពេញតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលនេះ។

## ៥. ការធានាបាននូវនិរន្តរភាពនៃមុខងាររបស់ប្រព័ន្ធអេកូឡូស៊ី

ធនធានជលផលមិនអាចគង់វង្សបានឡើយប្រសិនបើតំបន់ឆ្នេរ បឹងបួរ ព្រៃលិចទឹក និងប្រព័ន្ធទន្លេត្រូវបានបំផ្លាញ។ ការថែរក្សាបាននូវគុណភាពនៃប្រព័ន្ធអេកូឡូស៊ីទាំងនោះ គឺជាការចាំបាច់សម្រាប់ភាពគង់វង្សនៃវិស័យជលផលរយៈពេលយូរអង្វែង។ កិច្ចការនេះតម្រូវឱ្យមានការយល់ដឹងយ៉ាងច្បាស់អំពីមុខងាររបស់ប្រព័ន្ធអេកូឡូស៊ីទាំងនោះ សម្ពាធនិងផលប៉ះពាល់ និងវិធានការទប់ស្កាត់ចាំបាច់នានា។ តួនាទីសំខាន់របស់រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍ ដើម្បីយល់ដឹងនិងគាំទ្រដល់មុខងាររបស់ប្រព័ន្ធអេកូឡូស៊ី។

## ៦. ការលើកកម្ពស់សិទ្ធិស្របច្បាប់និងការទទួលខុសត្រូវរបស់សហគមន៍និងបុគ្គលនីមួយៗ

ទិដ្ឋភាពមួយនៃគោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិស្តីពី នេសាទទ្រង់ទ្រាយតូច គឺការបង្កើននិងធានានិរន្តរភាពនូវសិទ្ធិសម្រាប់ការនេសាទទ្រង់ទ្រាយតូច។ គោលការណ៍នេះអាចជួយធ្វើឱ្យមានតុល្យភាពបានដោយបង្កើននូវការទទួលខុសត្រូវក្នុងការប្រើប្រាស់ធនធានទាំងនោះ ប្រកបដោយនិរន្តរភាព។ នៅក្នុងខ្លឹមសារសំខាន់នៃការកែទម្រង់វិស័យជលផលនៅកម្ពុជា គឺការបង្កើននូវសិទ្ធិនិងការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ។ កិច្ចការនេះនឹងបន្តក្នុងការអភិវឌ្ឍវិស័យជលផលទៅថ្ងៃអនាគត។ ភាពជាដៃគូរវាងរដ្ឋនិងសហគមន៍ គឺជាការចាំបាច់ ដើម្បីសម្រេចឱ្យបាននូវការអនុវត្តតាមអភិក្រមជាយុទ្ធសាស្ត្រ ហើយនឹងធ្វើឱ្យកាន់ប្រសើរឡើងនៅក្នុងរយៈពេល១០ឆ្នាំបន្តបន្ទាប់។







## ៧. ដោះស្រាយនូវតម្រូវការនិងឆ្លើយតបទៅតាមបំណងប្រាថ្នារបស់សហគមន៍

ចំណុចគន្លឹះក្នុងការលើកកម្ពស់សិទ្ធិស្របច្បាប់និងការទទួលខុសត្រូវរបស់សហគមន៍ គឺការយល់ដឹងអំពីតម្រូវការរបស់ពួកគាត់។ ប្រសិនបើមិនដូច្នោះទេ កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលនិងសហគមន៍មានដំណើរការខុសទិសដៅ។ ការយល់ដឹងអំពី បំណងប្រាថ្នា និងតម្រូវការរបស់អ្នកនេសាទ គឺមានសារៈសំខាន់សម្រាប់ធានាបាននូវភាពប្រទាក់ក្រឡានៅក្នុងគោលបំណងនៃការគ្រប់គ្រងធនធានផល ដោយការចូលរួមពីសហគមន៍។

ការតាមដាន ការវាយតម្លៃ និងការស្រាវជ្រាវ គឺដើរតួនាទីយ៉ាងសំខាន់ឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន ដើម្បីយល់ដឹងអំពីតម្រូវការនិងបំណងប្រាថ្នារបស់ពួកគាត់ ហើយកិច្ចការនេះ គឺជាព័ត៌មានយ៉ាងសំខាន់សម្រាប់ដំណើរការនៃការរៀបចំផែនការនិងគោលនយោបាយ។ តួនាទីរបស់យេនឌ័រនៅក្នុងវិស័យជលផលក៏ជាចំណុចដែលត្រូវយកចិត្តទុកដាក់ខ្ពស់ផងដែរ។

## ៨. ការយល់ដឹងអំពីភាពពឹងអាស្រ័យនៅក្នុងវិស័យនិងធ្វើឱ្យមានតុល្យភាពជាមួយនឹងជម្រើសមុខរបរចិញ្ចឹមជីវិត

របៀបនិងកម្រិតនៃការពឹងផ្អែកលើធនធានជលផលរបស់អ្នកនេសាទគឺខុសៗគ្នា។ អ្នកខ្លះប្រកបមុខរបរនេសាទពេញម៉ោង ហើយមិនមានមុខរបរអ្វីផ្សេងទៀតទេ ចំណែកអ្នកខ្លះទៀតប្រកបរបរនេសាទមិនពេញម៉ោង គឺធ្វើនេសាទតាមរដូវកាល អ្នកខ្លះប្រកបរបរចាប់ត្រី អ្នកខ្លះកែច្នៃនិងលក់ដូរត្រី មានប្រជាពលរដ្ឋខ្លះពឹងអាស្រ័យលើវិស័យជលផលសម្រាប់ធានាបាននូវសុវត្ថិភាពមុខរបរចិញ្ចឹមជីវិត នៅពេលដែលពុំអាចរកមុខរបរផ្សេងទៀតបាន។ នៅពេលដែលចំនួនប្រជាពលរដ្ឋកើនឡើងហើយការប្រើឧបករណ៍នេសាទកាន់តែទំនើប និងមានប្រសិទ្ធភាពកាន់តែខ្ពស់នឹងធ្វើឱ្យមានសម្ពាធកាន់តែខ្លាំងឡើងទៅលើធនធានជលផល ដែលបណ្ដាលឱ្យផលស្តុកត្រីធម្មជាតិមានការធ្លាក់ចុះខ្លាំងទៅៗ ទីបំផុតនឹងមានប្រជាពលរដ្ឋចាកចេញពីវិស័យជលផលកាន់តែច្រើនទៅៗ ដើម្បីស្វែងរកការងារធ្វើផ្សេងៗ ពីព្រោះការធ្វើនេសាទរបស់ពួកគាត់មិនអាចធានាបាននូវការផ្គត់ផ្គង់ជីវភាពរស់នៅបាន។

រដ្ឋបាលជលផលនឹងធ្វើការជាមួយនឹងសហគមន៍ ស្ថាប័នផ្សេងៗ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីបង្កើតនូវជម្រើសមុខរបរសមស្របសម្រាប់អ្នកដែលចេញពីការធ្វើនេសាទ។ កិច្ចការនេះ នឹងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងបំណងប្រាថ្នារបស់សហគមន៍ កាលានុវត្តភាពនៃទីផ្សារនិងរបៀបវារៈនៃការអភិវឌ្ឍដ៏ទូលំទូលាយនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។













## ៩. ការគិតគូរអំពីការចំណាយនិងផលចំណេញ ដោយរក្សាបាននូវនិរន្តរភាពនិងសមធម៌

ដោយមានការគាំទ្រពីម្ចាស់ជំនួយ រាជរដ្ឋាភិបាលបានចំណាយថវិកាជាច្រើនដើម្បីជំរុញដំណើរការកំណែទម្រង់គោលនយោបាយវិស័យជលផលឱ្យបានជោគជ័យ។ ការចំណាយនេះ គឺជាបន្ទុករបស់រាជរដ្ឋាភិបាល។ លើសពីនេះ ដោយសារកម្រិតនៃភាពក្រីក្រនៅជនបទ សហគមន៍មូលដ្ឋានមិនត្រូវបានដាក់កំហិតឱ្យបង់ប្រាក់សម្រាប់ទទួលបាននូវសិទ្ធិនៃការធ្វើនេសាទឡើយ។ ទោះបីជាយ៉ាងនេះក្តី សហគមន៍បានចំណាយពេលវេលានិងកម្លាំងក្នុងការចូលរួម ក្នុងដំណើរការសហគមន៍នេសាទ។ លើសពីនេះ តួនាទីនៃការគ្រប់គ្រងធនធានជលផលដែលបានប្រគល់ទៅឱ្យសហគមន៍នឹងរួមចំណែកដល់ការកាត់បន្ថយបន្ទុកនៃការចំណាយរបស់រដ្ឋាភិបាល។

ក្នុងពេលដែលកម្ពុជាកំពុងឈានឆ្ពោះទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមនោះ ជំនួយថវិកាអភិវឌ្ឍន៍ពីប្រភពខាងក្រៅនឹងមានការថយចុះ។ ទោះបីជាករណីនេះត្រូវបានចាត់ទុកថាជាជំហានវិជ្ជមាន ដោយបង្ហាញពីវឌ្ឍន-ភាពដែលប្រទេសជាតិបានធ្វើក៏ដោយ ប៉ុន្តែវិស័យជលផលចាំបាច់ត្រូវទទួលបាននូវប្រសិទ្ធភាពនិងស្វែងរកថវិកាច្រើនទៀតពីក្នុងវិស័យ។

ការបង្កើនការចំណាយលើការគ្រប់គ្រងធនធាន គឺជាផ្នែកមួយយ៉ាងសំខាន់របស់ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលក្នុងឆ្នាំខាងមុខ។ តើករណីនេះត្រូវអនុវត្តតាមរបៀបណា បញ្ហានេះគឺពឹងអាស្រ័យទៅលើការពិភាក្សានិងការឆ្លុះបញ្ចាំងជាក់ស្តែងពីមួយពេលទៅមួយពេល ដែលត្រូវជំរុញឱ្យមានការចូលរួមពីសហគមន៍នេសាទនិងវិស័យឯកជនពាក់ព័ន្ធ។ ចំណុចសំខាន់ៗនៃការពិភាក្សានេះ រួមមាន៖ ១). ទំហំនៃការចំណាយត្រូវសមាមាត្រទៅនឹងផលប្រយោជន៍ដែលក្រុមនីមួយៗបានទទួលពីធនធានជលផល ២). សង្គតិភាពនៃផែនការចំណាយគ្រប់គ្រងជាមួយនឹងវិស័យដទៃ ៣).ការគិតគូរអំពីស្ថានភាពសេដ្ឋកិច្ចសង្គមជាពិសេសបញ្ហាភាពក្រីក្រ ៤).ទំហំការងារដែលក្នុងនោះភារកិច្ចគ្រប់គ្រង គឺជាផលនៃកត្តាខាងក្នុង ឬជាផលិតផលនៃរដ្ឋាភិបាលដទៃ ឬគោលនយោបាយអន្តរជាតិលើសពីសមត្ថភាពត្រួតពិនិត្យរបស់អ្នកប្រើប្រាស់ធនធាននិង ៥). ការចំណាយនិងប្រសិទ្ធភាពនៃមធ្យោបាយគ្រប់គ្រង។







### ១០.ការកសាងសមត្ថភាព

អភិក្រមជាយុទ្ធសាស្ត្រសម្រាប់វិស័យតម្រូវឱ្យមានការបង្វែរពីសមត្ថភាពរបស់បុគ្គល និងស្ថាប័ននៅក្នុងវិស័យជលផលឱ្យទៅជាការអនុវត្តជាក់ស្តែង។ ចំណុចសំខាន់ គឺការកសាងប្រព័ន្ធនិងអភិក្រមមួយដែលអាចបត់បែនបានដើម្បីសម្របទៅនឹងការប្រែប្រួលនៅក្នុងវិស័យ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទទួលស្គាល់ថា នៅក្នុងរដ្ឋបាលជលផលមានតំណែងជាច្រើននៅទំនេរនៅឡើយ ហើយក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលបានផ្តោតលើការកសាងសមត្ថភាពរបស់មន្ត្រី។ ទោះបីជាយ៉ាងនេះក្តី កិច្ចការចាំបាច់ គឺមន្ត្រីរដ្ឋបាលជលផលត្រូវអភិវឌ្ឍន៍សមត្ថភាព អត្តចរិត និងចំណេះដឹងរបស់ខ្លួនដើម្បីអាចបត់បែនសម្របនិងមានសមត្ថភាពពេញលេញ។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលបានផ្តោតលើការកសាងសមត្ថភាពនេះ នៅក្នុងឆ្នាំខាងមុខ។

ការកសាងសមត្ថភាពនេះ នឹងត្រូវពង្រីកទៅដល់សហគមន៍និងអាជ្ញាធរមូលដ្ឋាន ចំពោះអ្នកដែលមានភារកិច្ចពាក់ព័ន្ធនៅក្នុងវិស័យជលផល។ ចំណុចសំខាន់ចំពោះកិច្ចការនេះ គឺការរៀបចំអង្គភាពសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យឯកជនដែលធានាបាននូវការសម្របសម្រួល កិច្ចសហការ ការទំនាក់ទំនង និងជាតំណាងនៅក្នុងដំណើរការសម្រេចចិត្ត។

ការកសាងសមត្ថភាពនេះ គឺជាដំណើរការបន្ត ដែលឆ្លុះបញ្ចាំងពីការប្រែប្រួលរបស់វិស័យ។

## ការរៀបចំផែនការសម្រាប់វិស័យ

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល គឺជាផែនការយុទ្ធសាស្ត្រដ៏សំខាន់បំផុតរបស់វិស័យជល-ផល។ ការធ្វើបច្ចុប្បន្នភាពនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលដែលមានចែងនៅក្នុងឯកសារនេះ គឺត្រូវធ្វើឡើងស្របជាមួយនឹងការប្រែប្រួលដែលកើតឡើងយ៉ាងទូលំទូលាយនៅក្នុងកម្រិតវិស័យ។

ផែនការ៣ឆ្នាំរំកិលរបស់វិស័យជលផលដែលជាផ្នែកមួយនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ គឺត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនៅក្នុងដំណើរការកសាងផែនការនៃអនុកម្មវិធី ដែលស្ថិតនៅក្រោមវិសាលភាពរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ផែនការនេះនឹងត្រូវកែសម្រួលនៅក្នុងរយៈពេលកំណត់មួយ ដើម្បីដោះស្រាយបាននូវការប្រែប្រួលនៅក្នុងវិស័យ។







មានការរំពឹងថា ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ នឹងធ្វើការវាយតម្លៃនៅក្នុងឆ្នាំ២០១៩ ហើយនឹងធ្វើបច្ចុប្បន្នភាពផ្អែកតាមសភាពការណ៍ជាក់ស្តែង។

រដ្ឋបាលជលផល នឹងរៀបចំផែនការប្រចាំឆ្នាំសម្រាប់កម្មវិធីនិងអនុកម្មវិធី ដែលស្របជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។

## ការត្រួតពិនិត្យ ការវាយតម្លៃ និងការរាយការណ៍

ការរក្សាបាននូវដំណើរការរៀបចំផែនការឱ្យស្របនឹងការប្រែប្រួល គឺជាតួនាទីបឋមរបស់ប្រព័ន្ធតាមដាន និងវាយតម្លៃ។ កិច្ចការនេះនឹងត្រូវធ្វើឡើងស្របតាមប្រព័ន្ធតាមដាននិងវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការតាមដាននិងការវាយតម្លៃនៅក្នុងវិស័យជលផលនឹងត្រូវធ្វើឡើងនៅលើ៣កម្រិត៖

១. កម្រិតកម្មវិធី៖ នៅក្នុងកម្រិតនេះការតាមដាននិងវាយតម្លៃត្រូវធ្វើឡើងអំពី ផលប៉ះពាល់ដែលសម្រេចបានចំពោះវិស័យទាំងមូល ហើយអាចវាស់វែងបានដោយសូចនាករនៃសសរស្តម្ភទាំង៤នៃការអភិវឌ្ឍវិស័យ។

២. កម្រិតអនុកម្មវិធី៖នៅក្នុងកម្រិតនេះ ការតាមដាននិងវាយតម្លៃ គឺធ្វើឡើងចំពោះលទ្ធផលសម្រេច ដែលសម្រេចបានដោយរដ្ឋបាលជលផល។ ការតាមដាននិងវាយតម្លៃនេះ គឺផ្អែកលើសូចនាករលទ្ធផលសម្រេចរបស់អនុកម្មវិធីនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។

៣.កម្រិតសកម្មភាព៖គឺជាកម្រិតមួយ ដែលរដ្ឋបាលជលផលទទួលខុសត្រូវក្នុងការអនុវត្ត នៅក្នុងកម្រិតនេះ គឺពាក់ព័ន្ធនឹងការវាស់វែងនូវលទ្ធផលដែលអនុវត្តបានដោយអនុកម្មវិធីនីមួយៗ។

ការត្រួតពិនិត្យនឹងត្រូវធ្វើឡើងប្រចាំឆ្នាំនិងប្រចាំត្រីមាស ហើយការចុះពិនិត្យជាក់ស្តែងដល់ទីកន្លែងអនុវត្តក៏ត្រូវធ្វើឡើងដើម្បីផ្ទៀងផ្ទាត់ផងដែរ។ និន្នាការប្រែប្រួលនៃធនធាននឹងត្រូវធ្វើការតាមដាននៅក្នុងរយៈពេលវែង។ ការវាយតម្លៃអំពីផលប៉ះពាល់នឹងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។ ការរាយការណ៍អំពីអនុកម្មវិធីត្រូវធ្វើឡើងប្រចាំត្រីមាសនិងប្រចាំឆ្នាំសម្របតាមនីតិវិធីតាមដាននិងវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ធនធានសម្រាប់ការអនុវត្ត

គម្រោងថវិកាសម្រាប់ការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ សម្រាប់វិស័យជលផលនឹងត្រូវរៀបចំឡើងដោយរដ្ឋបាលជលផលស្របជាមួយនឹងផែនការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់នូវការណែនាំអំពី ការរៀបចំថវិកាសម្រាប់កម្មវិធីជលផល ដូចមានចែងនៅក្នុង







ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។ នៅក្នុងរយៈពេលខ្លីដល់រយៈពេលមធ្យម កម្ពុជានឹងពឹងផ្អែកលើថវិកាជំនួយពីដៃគូអភិវឌ្ឍន៍។ ប៉ុន្តែ ចាប់ពីមួយពេលទៅមួយពេល នៅពេលដែលការរួមចំណែករបស់វិស័យជលផលដល់សេដ្ឋកិច្ចជាតិមានការកើនឡើងគួរតែអនុញ្ញាតឱ្យបង្កើនការយកថ្លៃឈ្នួលពីដែននេសាទ ដើម្បីបង្កើនលទ្ធភាពរកចំណូលរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់នូវថវិកាដល់វិស័យ។ ទោះបីជាយ៉ាងនេះក្តី គោលការណ៍សំខាន់ចំពោះការកំណត់នូវចំណូលជាក់លាក់ទៅថ្ងៃអនាគតនឹងធានាបានថា វាមិនមែនជាបន្ទុកដ៏ធ្ងន់ទៅលើប្រជាពលរដ្ឋនៅក្នុងវិស័យឡើយ ដូចនេះសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋអាចធានាបាន ភាពក្រីក្រនៅក្នុងវិស័យត្រូវបានកាត់បន្ថយ ហើយវិស័យជលផលសម្រេចបាននូវកំណើនប្រកបដោយនិរន្តរភាព។

ការគ្រប់គ្រងថវិកានិងការត្រួតពិនិត្យជារួមនូវរាល់អនុកម្មវិធី គឺជាភារកិច្ចរបស់នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ នៃរដ្ឋបាលជលផលហើយត្រូវធ្វើឡើងដោយផ្អែកតាមនីតិវិធីនិងប្រព័ន្ធថវិកា និងផែនការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការប៉ាន់ស្មានពីតម្រូវការហិរញ្ញវត្ថុសម្រាប់ការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល គឺមានបង្ហាញក្នុងតារាងដូចខាងក្រោម៖

ការប៉ាន់ស្មានថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល (ឯកត្តា៖ពាន់ដុល្លារ)

| ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|
| ៨.៥១៧,៦៥ | ១៨.៣៦០,៦២ | ១៥.៩២៩,២២ | ១៥.៤២៧,៩៧ | ១៥.០០០ |

| ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|
| ១៥.០០០ | ១៥.០០០ | ១៥.០០០ | ១៥.០០០ | ១៥.០០០ |

តួលេខថវិកាសម្រាប់រយៈពេលឆ្នាំ២០១៥-២០១៨ ត្រូវបានប៉ាន់ស្មានសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ហើយចាប់ពីឆ្នាំ២០១៩ ទៅគឺជាការគ្រោងទុក ប៉ុន្តែមិនទាន់បានបញ្ជាក់ពីការប៉ាន់ស្មានជាក់លាក់នៅឡើយ។







# ឧបសម្ព័ន្ធ



ឧបសម្ព័ន្ធ១៖គោលនយោបាយទូលំទូលាយដែលមានឥទ្ធិពលដល់ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រឆ្នាំ២០១៥-២០២៤
៥៤



ឧបសម្ព័ន្ធ២៖ការណែនាំអំពីសូចនាករនិងចំណុចដៅនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល
៦៤





# ១

# គោលនយោបាយទូលំទូលាយដែលមានឥទ្ធិពលដល់ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រឆ្នាំ២០១៥-២០២៤

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល មិនអាចស្ថិតនៅដាច់ដោយឡែកពីគោលនយោបាយរបស់វិស័យដទៃនៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិឡើយ។ ដូចនេះ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនឹងមានឥទ្ធិពលទៅវិញទៅមកជាមួយនឹងគោលនយោបាយវិស័យដទៃមិនអាចជៀសផុតឡើយ។ ចំណុចសំខាន់ៗដែលមានឥទ្ធិពលនិងអន្តរកម្មទៅវិញទៅមករវាងគោលនយោបាយនានាជាមួយនឹងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលមានបញ្ជាក់ដូចខាងក្រោម៖

## គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព គឺផ្តោតលើសមាសភាគសំខាន់ៗដែលឆ្លុះបញ្ចាំងពីមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងវិស័យជលផលនៅកម្ពុជា។ គោលដៅនេះ គឺអាចដោះស្រាយបាននូវភាពក្រីក្រដែលមានឥទ្ធិពលដល់ប្រពលរដ្ឋដែលពឹងផ្អែកលើធនធានជលផល ហើយអាចដោះស្រាយនូវភាពស្រេកឃ្លានបញ្ហាសន្តិសុខស្បៀង និងការបង្កើននូវអាហារូបត្ថម្ភនិងសុខភាពចំពោះអ្នកដែលប្រើប្រាស់ត្រីដោយផ្ទាល់ ជាពិសេស នៅកម្ពុជាត្រីមានតួនាទីសំខាន់ក្នុងម្ហូបអាហារ។ ដូចនេះ ការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព គឺជាកិច្ចការយ៉ាងសំខាន់។ គោលដៅទាំងនេះអាចជួយដោះស្រាយបាននូវបញ្ហាសិក្សាអប់រំដែលមានសារៈសំខាន់យ៉ាងខ្លាំងចំពោះវិស័យជលផល ជាពិសេសចំពោះការសម្រេចចិត្តលើការគ្រប់គ្រងប្រកបដោយនិរន្តរភាពដែលចាំបាច់ត្រូវផ្អែកលើចំណេះដឹងនិងព័ត៌មានសមស្រប។ គោលដៅទាំងនេះ ក៏ទទួលស្គាល់ផងដែរនូវសារៈសំខាន់នៃសមធម៌យេនឌ័រនិងការពង្រឹងនូវសិទ្ធិអំណាចរបស់ស្ត្រី ដែលចាំបាច់សម្រាប់ភាពមានយុត្តិធម៌និងនិរន្តរភាពនៃការអភិវឌ្ឍវិស័យជលផលនៅកម្ពុជា។

គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនេះ គឺអាចដោះស្រាយបាននូវតម្រូវការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាពនិងផ្តល់នូវលទ្ធភាពអាចប្រើប្រាស់ថាមពលទំនើបនិងមាននិរន្តរភាព។ បញ្ហានេះនឹងជះឥទ្ធិពលដោយផ្ទាល់ទៅលើវិស័យជលផលនៅកម្ពុជានៅថ្ងៃអនាគត ដោយសារតែបញ្ហាការប្រើប្រាស់ធនធានទឹកឆ្លងដែនរួមនិងការកើនឡើងនូវគោលដៅនៃការប្រើប្រាស់ធនធាននេះ ដើម្បីបង្កើតនូវថាមពលវារីអគ្គិសនី។ តម្រូវការ នេះ

គឺចាំបាច់ត្រូវធ្វើឱ្យមានតុល្យភាពនៅក្នុងគោលដៅនៃការសម្រេចបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាព និង ផ្តល់នូវការងារធ្វើពេញលេញ។ ករណីនេះ គឺមានសារៈសំខាន់ចំពោះវិស័យជលផល ជាពិសេសនៅទីណាដែលការងារក្នុងវិស័យនេះមានការថយចុះនៅពេលដែលធនធានធ្លាក់ចុះ និងនៅទីណាដែលបញ្ហាពលកម្មកុមារកើតឡើងធ្ងន់ធ្ងរ។ ភាពចាំបាច់ ដើម្បីធ្វើសមាហរណកម្មការគ្រប់គ្រងធនធានធម្មជាតិនិងការអភិវឌ្ឍនៅកម្ពុជា គឺផ្តល់នូវកាលានុវត្តភាពសម្រាប់ជម្រើសនានានៃមុខរបរចិញ្ចឹមជីវិត។ កិច្ចការនេះនឹងមានសារៈសំខាន់ចំពោះការធ្វើសមាហរណកម្មវិស័យជលផលជាមួយនឹងការអភិវឌ្ឍផ្សេងទៀត ដើម្បីធានាបាននូវយុត្តិធម៌និងតុល្យភាព។

ទោះបីជាយ៉ាងនេះក្តី មានការទទួលស្គាល់ថាគំនិតច្នៃប្រឌិតនិងឧស្សាហភាវូបនីយកម្ម អាចរួមបញ្ចូលបានគ្រប់ជ្រុងជ្រោយនិងមាននិរន្តរភាព ប្រសិនបើអនុវត្តបានត្រឹមត្រូវ ហើយករណីនេះនឹងបង្កើតនូវបញ្ហាប្រឈមដល់ការគ្រប់គ្រងវិស័យជលផលនិងការអភិវឌ្ឍវារីវប្បកម្មនៅកម្ពុជានៅឆ្នាំខាងមុខ។ ការរៀបចំផែនការបានល្អ និងការធានាបាននូវនិរន្តរភាពនៃធនធានជលផលនិងវារីវប្បកម្ម គឺអាចរួមចំណែកដល់ការសម្រេចបាននូវសមធម៌ដ៏ធំធេងនៅក្នុងប្រទេសនិងរវាងជាតិនានា ហើយកាត់បន្ថយបាននូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្រីក្រនៅជនបទក្នុងការស្វែងរកការងារធ្វើនៅទីក្រុង។

ទោះបីជាយ៉ាងនេះក្តី ផលប្រយោជន៍ដែលអាចទទួលបាន គឺស្ថិតនៅក្រោមការគំរាមកំហែងដោយការប្រែប្រួលអាកាសធាតុ ដែលអាចធ្វើឱ្យមានការប្រែប្រួលរបបទឹកជំនន់ ប៉ះពាល់ដល់ប្រភេទត្រី ផលចាប់ និងជំងឺ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពទទួលស្គាល់នូវសារៈសំខាន់ នៃការយល់ដឹងការកាត់បន្ថយនិងការឆ្លើយតបទៅនឹងការជះឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ។ កិច្ចការនេះមិនត្រឹមតែជាវិធានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិងលើកកម្ពស់ឧស្សាហកម្មណាដែលបំភាយសារជាតិកាបោនទាប ការអភិរក្សទីជម្រកនិងជីវចម្រុះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអភិរក្សនិងប្រើប្រាស់ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីនិងព្រៃឈើប្រកបដោយនិរន្តរភាព។ ដើម្បីធ្វើកិច្ចការនេះបានសម្រេច គឺទាមទារសង្គមមួយដែលមានសន្តិភាពនិងមានការចូលរួម ហើយមានស្ថាប័នសម្រាប់គ្រប់គ្រងធនធានប្រើប្រាស់នៅគ្រប់កម្រិតនិងភាពជាដៃគូនៃការអភិវឌ្ឍគ្រប់ជ្រុងជ្រោយត្រូវបានលើកកម្ពស់។

### គោលការណ៍ស្ម័គ្រចិត្តសម្រាប់ធានានិរន្តរភាពនៃនេសាទទ្រង់ទ្រាយតូច នៅក្នុងបរិបទនៃសន្តិសុខស្បៀងនិងការលុបបំបាត់ភាពក្រីក្រ និងក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវនៃវិស័យជលផលរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

គោលការណ៍ស្ម័គ្រចិត្តសម្រាប់ធានានិរន្តរភាពនៃការនេសាទទ្រង់ទ្រាយតូច នៅក្នុងបរិបទនៃសន្តិសុខស្បៀង និងការលុបបំបាត់ភាពក្រីក្រ ត្រូវបានរៀបចំឡើងជាការបំពេញបន្ថែមទៅនឹងក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវចំពោះវិស័យជលផលរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ១៩៩៥។ គោលការណ៍ណែនាំនេះទទួលស្គាល់ ថាសកម្មភាពពាក់ព័ន្ធនឹងខ្សែសង្វាក់ផលិតកម្មជលផលរួមមាន សកម្មភាពមុនពេលប្រមូលផល សកម្មភាព

ប្រមូលផល និងក្រោយពេលប្រមូលផលរបស់នេសាទទ្រង់ទ្រាយតូច គឺអនុវត្តទាំងបុរសនិងស្ត្រី។ គោលការណ៍ណែនាំនេះក៏ទទួលស្គាល់ផងដែរ នូវតួនាទីដ៏សំខាន់របស់នេសាទទ្រង់ទ្រាយតូចចំពោះសន្តិសុខស្បៀងអាហារូបត្ថម្ភការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយសមធម៌ ការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ នេសាទទ្រង់ទ្រាយតូចផ្តល់នូវអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋនៅជនបទ ទីផ្សារជាតិ និងអន្តរជាតិ ហើយបង្កើតនូវប្រាក់ចំណូលជួយគាំទ្រដល់សេដ្ឋកិច្ចមូលដ្ឋាននិងសេដ្ឋកិច្ចជាតិ។

គោលបំណងនៃគោលការណ៍ទាំងនេះ រួមមានដូចខាងក្រោម៖

ក) លើកកម្ពស់ការចូលរួមចំណែករបស់នេសាទទ្រង់ទ្រាយតូច ចំពោះសន្តិសុខស្បៀងនិងអាហារូបត្ថម្ភពិភពលោក ហើយគាំទ្រដាក់ការយល់ដឹងអំពីសិទ្ធិទទួលបាននូវការហូបចុកគ្រប់គ្រាន់។

ខ) រួមចំណែកចំពោះការអភិវឌ្ឍសហគមន៍នេសាទប្រកដោយសមធម៌និងការកាត់បន្ថយភាពក្រីក្រ និងបង្កើននូវស្ថានភាពសេដ្ឋកិច្ចសង្គមរបស់អ្នកនេសាទ និងកម្មករនេសាទនៅក្នុងបរិបទនៃការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព។

គ) សម្រេចបាននូវការប្រើប្រាស់ប្រកបដោយនិរន្តរភាព ការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងអភិរក្សធនធានជលផល ដែលស្របជាមួយនឹងក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវ ចំពោះវិស័យជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ។

ឃ) ជំរុញការរួមចំណែករបស់នេសាទទ្រង់ទ្រាយតូចចំពោះសេដ្ឋកិច្ច សង្គម និងបរិស្ថាន ប្រកបដោយនិរន្តរភាពទៅថ្ងៃអនាគតសម្រាប់មនុស្សជាតិនៅលើផែនដី។

ង) ផ្តល់មតិយោបល់ណែនាំសម្រាប់ការពិចារណាពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការអនុវត្តនូវការថែរក្សាប្រព័ន្ធអេកូឡូស៊ីនិងគោលនយោបាយចូលរួមក្របខ័ណ្ឌច្បាប់និងយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការទទួលខុសត្រូវនិងនិរន្តរភាពនេសាទទ្រង់ទ្រាយតូច។

ច) លើកកម្ពស់ការយល់ដឹងសាធារណៈនិងជំរុញចំណេះអំពីវប្បធម៌ តួនាទី ការរួមចំណែក និងសក្តានុពលនៃនេសាទទ្រង់ទ្រាយតូច ដោយគិតគូរអំពីចំណេះដឹងជាប្រពៃណី បញ្ហាប្រឈម និងកាលានុវត្តភាព។

បញ្ញត្តិនានាពាក់ព័ន្ធនឹងគោលការណ៍ណែនាំទាំងនេះ គឺមាននៅក្នុងក្រមប្រតិបត្តិជលផលកម្ពុជា(កាំកូដ) ដែលជាគោលការណ៍បានរៀបចំឡើង ជាពិសេសសម្រាប់ជាការបកស្រាយក្រមប្រតិបត្តិនៃការទទួលខុសត្រូវជលផលថ្នាក់តំបន់នៅក្នុងបរិបទនៃវិស័យជលផលកម្ពុជា។

ក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវចំពោះវិស័យជលផល ក៏ទទួលស្គាល់នូវសារៈសំខាន់នៃការលុបបំបាត់នូវការធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ហើយជាលទ្ធផល បញ្ហានេះត្រូវបានគិតគូរដាក់

បញ្ចូលនៅក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ការលុបបំបាត់នូវការធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតទាំងនេះ។

## យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ សម្រាប់កំណើនការងារ សមធម៌ និងប្រសិទ្ធភាព

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គឺពង្រឹងបន្ថែមទៀតនូវបេសកកម្មរបស់រាជរដ្ឋាភិបាលដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងកាត់បន្ថយនូវភាពក្រីក្រ។ យុទ្ធសាស្ត្រចតុកោណបានកំណត់នូវវិស័យជាអាទិភាពចំនួន៤ ក្នុងនោះការអភិវឌ្ឍកសិកម្ម ដែលរួមមានវិស័យជលផលនិងវារីវប្បកម្ម គឺជាវិស័យអាទិភាពដែលបានកំណត់។ ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យជលផលយុទ្ធសាស្ត្រចតុកោណបានផ្តោតលើតម្រូវការធ្វើឱ្យមានតុល្យ-ភាពនៃការអភិវឌ្ឍជាមួយនឹងការអភិរក្ស។ យុទ្ធសាស្ត្រនេះក៏បានបញ្ជាក់ពីភាពចាំបាច់ដែលត្រូវជំរុញពីប្រព័ន្ធផលិតកម្មតាមបែបវិបុលវប្បកម្ម ឆ្ពោះទៅរកប្រព័ន្ធប្រពលវប្បកម្ម។ ចំណែកឯការអភិវឌ្ឍវិស័យជលផល គឺផ្តោតលើការពង្រីកវារីវប្បកម្មនិងការនេសាទប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចបាននូវគោលដៅនេះ គឺតម្រូវឱ្យមានការកែទម្រង់វិស័យជលផលថែមទៀតនិងដោះស្រាយនូវបញ្ហាសំខាន់ៗដូចជាការប្រែប្រួលអាកាសធាតុជាដើម។ យុទ្ធ-សាស្ត្រចតុកោណក៏ទទួលស្គាល់នូវសារៈសំខាន់នៃអភិបាលកិច្ចល្អ និងតួនាទីនៃការកែទម្រង់វិស័យជលផលផងដែរ។ ការកែទម្រង់វិស័យជលផលស៊ីជម្រៅត្រូវបានធ្វើឡើងនៅក្នុងឆ្នាំកន្លងទៅថ្មីៗដើម្បីផ្តល់នូវសិទ្ធិ និងធនធានច្រើនថែមទៀតដល់សហគមន៍មូលដ្ឋានសម្រាប់ការគ្រប់គ្រងនិងអភិរក្សធនធានជលផល។ ទោះបីជាយ៉ាងនេះក្តី ដោយទទួលស្គាល់ពីសារៈសំខាន់របស់ត្រីចំពោះសន្តិសុខស្បៀងជាតិ ការបង្កើននូវប្រាក់ចំណូលនិងការលើកកម្ពស់ការនាំចេញ រដ្ឋាភិបាលបានកំណត់នូវគោលដៅជំរុញការបង្កើនផលិតផលពីការនេសាទដោយគិតគូរដល់និរន្តរភាព និងពីវារីវប្បកម្ម ដើម្បីបង្កើនការចូលរួមចំណែកដល់កំណើនជាតិតាមរយៈវិធីសាស្ត្រនៃការបង្កើននូវតម្លៃសង្វាក់ផលិតកម្ម។ ដើម្បីលើកកម្ពស់ការបង្កើននូវផលិតផលរដ្ឋាភិបាលនឹងផ្តោតលើសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

១. បន្តអនុវត្តនូវក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ ក្នុងគោលបំណងដើម្បីបង្កើនផលិតផលជលផលសម្រាប់បំពេញនូវតម្រូវការប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ។

២. លើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍផ្នែកនានានៅក្នុងវិស័យវារីវប្បកម្មដូចជា ការភ្ញាស់កូនត្រី សុខភាពត្រីនិងផលិតកម្មចំណីត្រី និងប្រព័ន្ធកសិដ្ឋានចិញ្ចឹមត្រី ។

៣. លើកកម្ពស់ការអនុវត្តច្បាប់ស្តីពីសុខភាពនិងបរិមាណផលិតផលត្រី ដើម្បីផ្តល់នូវមូលដ្ឋានសម្រាប់ការរៀបចំ និងគ្រប់គ្រងវិស័យវារីវប្បកម្ម ក្នុងគោលដៅពង្រឹងការអនុវត្តតាមស្តង់ដារអនាម័យនៃផលិតផលត្រី និងពង្រឹងការអនុវត្តតាមវិធានការអនាម័យនិងភូតគាមអនាម័យ ដើម្បីការពារនិងទប់ស្កាត់នូវជំងឺត្រីដែលកើតឡើងនិងការពារសុខភាពសាធារណៈ។

៤. លើកទឹកចិត្តដល់ការវិនិយោគទុនចំពោះផលិតកម្មចំណីត្រីជាទ្រង់ទ្រាយមធ្យមនិងទ្រង់ទ្រាយធំ ដើម្បីគាំទ្រដល់ការចិញ្ចឹមត្រី រួមជាមួយនឹងការបង្កើននូវប្រព័ន្ធផ្តល់សេវាកម្មផ្សព្វផ្សាយ ការភ្ញាស់ ឥណទាន និងការរកទីផ្សារសម្រាប់កសិករចិញ្ចឹមត្រី លើកទឹកចិត្តដល់ការវិនិយោគទុនរបស់ឯកជនក្នុងការកែច្នៃផលផលិតផលជលផលនិងការសម្របសម្រួលពាណិជ្ជកម្មផល ផលិតផលជលផល។

ដើម្បីធានាបាននូវតុល្យភាពរវាងការអភិវឌ្ឍនិងការអភិរក្ស គឺតម្រូវឱ្យមានការលើកកម្ពស់ការត្រួតពិនិត្យសកម្មភាពនេសាទល្មើសច្បាប់ ដោយរួមមានការត្រួតពិនិត្យយ៉ាងតឹងរឹងនូវឧបករណ៍និងពេលវេលានៃការធ្វើនេសាទ ការលុបបំបាត់នូវការនេសាទហួសកម្រិត ពង្រឹងសមត្ថភាពសហគមន៍នេសាទក្នុងការគ្រប់គ្រងប្រើប្រាស់ និងអភិរក្សធនធានជលផល ការការពារជីវចម្រុះ និងទីជម្រករបស់វារិជាត ការត្រួតពិនិត្យគុណភាពទឹកសាបនិងសមុទ្រតាមរយៈវិធានការកាត់បន្ថយជាតិពុល ការពារនិងដាំឡើងវិញនូវព្រៃលិចទឹក កំណត់ព្រំប្រទល់ព្រៃលិចទឹក និងតំបន់អភិរក្ស អភិវឌ្ឍន៍ស្ថាប័ននិងធនធានមនុស្ស និងរៀបចំការសិក្សាស្រាវជ្រាវនិងការផ្សព្វផ្សាយ។

យុទ្ធសាស្ត្រចតុកោណក៏ទទួលស្គាល់ផងដែរ នូវការកើនឡើង និងការប្រែប្រួលបញ្ហាប្រឈមចំពោះតួនាទីរបស់វិស័យជលផល។ ដើម្បីដោះស្រាយនូវបញ្ហានេះ ការបង្កើននូវសមត្ថភាពរបស់មន្ត្រីនៅក្នុងរដ្ឋបាលជលផល គឺជាការចាំបាច់ ដើម្បីពង្រឹងបាននូវប្រសិទ្ធភាពនៃស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន និងថ្នាក់សហគមន៍។ ទន្ទឹមនឹងការទទួលស្គាល់ថាតំណែងរបស់មន្ត្រីបច្ចុប្បន្ននៅទំនេរដែលចាំបាច់ត្រូវបំពេញ ប៉ុន្តែក៏មានការចាំបាច់ត្រូវពង្រឹងប្រសិទ្ធភាពការងាររបស់មន្ត្រី ក្នុងនោះគោលនយោបាយយេនឌ័រនៅក្នុងវិស័យជលផលចាំបាច់ត្រូវអនុវត្តឱ្យបានពេញលេញ ហើយភាពជាដៃគូរវាងនាយកដ្ឋាននានា រវាងកម្រិតថ្នាក់រដ្ឋបាលផ្សេងៗ និងជាមួយនឹងសហគមន៍ចាំបាច់ គឺត្រូវពង្រឹង។ ទំនាក់ទំនងនិងបច្ចេកវិទ្យាព័ត៌មានក៏ចាំបាច់ត្រូវដើរតួនាទីឱ្យបានខ្លាំងក្លាថែមទៀត ក្នុងការទប់ទល់ជាមួយនឹងការប្រែប្រួលបរិស្ថាននិងសេដ្ឋកិច្ចដែលកើតឡើងមិនអាចប៉ាន់ស្មានបាន។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានកែសម្រួលឡើងវិញ ដើម្បីឆ្លុះបញ្ចាំងនូវការប្រែប្រួលគោលនយោបាយនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣និងរៀបចំផែនការអនុវត្តសម្រាប់វិស័យសេដ្ឋកិច្ច។

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨

ទស្សនវិស័យសម្រាប់វិស័យជលផល

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានកំណត់នូវអាទិភាពនៃការជះឥទ្ធិពលសម្រាប់ការអភិវឌ្ឍជាតិ គឺកំណើនការកាត់បន្ថយភាពក្រីក្រ ស្ថិរភាព និងការអភិវឌ្ឍធនធានមនុស្ស។ ទស្សនវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យជលផល គឺ៖

*គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍប្រទេសជាតិ។*

គោលសំខាន់សម្រាប់ការអភិវឌ្ឍ

វិស័យជលផល គឺមានទំនាក់ទំនងជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិតាមរយៈគោលសំខាន់នៃគោលនយោបាយអភិវឌ្ឍន៍ចំនួន៤៖

១. អភិបាលកិច្ច៖ រដ្ឋាភិបាលនៅតែបន្តផ្តល់អាទិភាពខ្ពស់ក្នុងការលើកទឹកចិត្តនិងគាំទ្រដល់សហគមន៍នេសាទដើម្បីចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិដើម្បីធានាបានទាំងនិរន្តរភាពនៃធនធានទាំងនោះនិងធានាបាននូវជីវភាពរស់នៅដ៏ប្រសើររបស់សហគមន៍មូលដ្ឋានដែលពឹងផ្អែកលើធនធានជលផល។ ការគ្រប់គ្រងនេះគឺតម្រូវឱ្យមានការសម្របនៅនឹងភាពមិនទៀងទាត់ ដែលកើតឡើងដោយសារការប្រែប្រួលអាកាសធាតុនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់តំបន់។ រដ្ឋាភិបាលនឹងសហការយ៉ាងជិតស្និទ្ធជាមួយនឹងបណ្តាប្រទេសជិតខាងដើម្បីធានាបាននូវការប្រើប្រាស់ទីជម្រកនិងធនធានប្រកបដោយនិរន្តរភាព។

២. ការអភិរក្ស៖ រដ្ឋាភិបាលនឹងបន្តពង្រឹងការអភិរក្សធនធានជាតិ ជាពិសេសលើកទឹកចិត្តដល់ការផ្សារភ្ជាប់រវាងការអភិរក្សជាមួយនឹងទេសចរណ៍ធម្មជាតិ។ រដ្ឋាភិបាលនឹងបន្តអនុវត្តវិធានការទប់ស្កាត់បទល្មើស ការកាប់បំផ្លាញព្រៃលិចទឹក ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និងទប់ស្កាត់រាល់សកម្មភាពអណាធិបតេយ្យនានាដែលបំផ្លិចបំផ្លាញធនធាន។ កិច្ចការនេះ នឹងត្រូវធានានូវការអភិរក្សនិងការការពារតាមរយៈការបោះបង្គោលថ្មនៅក្នុងតំបន់អភិរក្ស ការកំណត់និងបោះបង្គោលព្រំប្រទល់ ដើម្បីការពារព្រៃលិចទឹក អន្លង់អភិរក្សនៅទន្លេមេគង្គលើ និងគ្រប់គ្រងទីជម្រកសំខាន់ៗឱ្យមាននិរន្តរភាព។

៣. ផលិតកម្ម៖ រដ្ឋាភិបាលនឹងលើកទឹកចិត្តដល់ការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពតាមរយៈសហគមន៍នេសាទនិងនេសាទតាមវាលស្រែ ក៏ដូចជាការពង្រីកទ្រង់ទ្រាយវារីវប្បកម្មទាំងទឹកសាបនិងសមុទ្រជាលក្ខណៈពាណិជ្ជកម្ម ដើម្បីថែរក្សាបានទាំងផលត្រីស្តុកធម្មជាតិនិងរក្សាបាននូវការផ្គត់ផ្គង់ផលត្រីសម្រាប់ការប្រើប្រាស់នៅមូលដ្ឋាន។

៤. តម្លៃបន្ថែម៖ ដើម្បីធានាបានថា តម្លៃត្រីឆ្លុះបញ្ចាំងពីតម្លៃសេដ្ឋកិច្ចពិតនិង ដើម្បីធានាបានថាជីវភាពរស់នៅ

របស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេសាទមានភាពសមរម្យ មិនទាបជាងកម្រិតមធ្យមរបស់ថ្នាក់ជាតិនោះ រដ្ឋាភិបាលនឹងបង្កើតនូវយន្តការទីផ្សារដ៏មានប្រសិទ្ធភាពនិងកាត់បន្ថយការបាត់បង់ផលត្រីក្នុងការកែច្នៃ ជាពិសេសការកែច្នៃត្រីជាលក្ខណៈទ្រង់ទ្រាយតូច។ ដើម្បីសម្រេចបាននូវគោលដៅនេះ គឺចាំបាច់ត្រូវផ្អែកលើវិធីសាស្ត្រខ្សែសង្វាក់ផលិតកម្មចំពោះវិស័យជលផល។

គោលដៅជាក់លាក់របស់វិស័យ

គោលដៅជាក់លាក់សម្រាប់វិស័យជលផលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចមានក្នុងតារាងខាងក្រោម៖

| លេខរៀង | សូចនាករ | ឯកត្តា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| សូចនាករ NSDP | | | | | | | |
| ៨.១៣ | វារីវប្បកម្ម (កើនឡើង១៥%) | តោន | ៩៧.៨០០ | ១១២.៥០០ | ១២៩.៤០០ | ១៤៨.៨០០ | ១៧១.១៧០ |
| ៨.១៤ | ផលិតផលត្រី (ពីគ្រប់ប្រភព) | ពាន់តោន | ៧៥២ | ៧៩០ | ៨២៩ | ៨៧០ | ៩១០ |
| ៨.១៥ | សហគមន៍នេសាទទទួលបានការពង្រឹងសមត្ថភាព | ចំនួន | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

ទោះបីជាយ៉ាងនេះក្តី ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវថ្មីៗដែលធ្វើឡើងទៅលើការនេសាទតាមវាលស្រែ និងការនេសាទនៅក្នុងដែននេសាទទឹកសាបនិងការជះឥទ្ធិពលពីប្រពលវប្បកម្មដំណាំស្រូវ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនោះ ការបង្កើនផលនេសាទពីគ្រប់ប្រភពមិនអាចទទួលបានដូចការប៉ាន់ស្មានដែលធ្វើឡើងកាលពីមុនឡើយ។ វិធីសាស្ត្រប៉ាន់ស្មានអំពីផលិតភាពត្រីកំពុងត្រូវបានរៀបចំឡើងនិងផ្សព្វផ្សាយក្នុងពេលឆាប់ៗនេះ។

ដើម្បីទទួលនូវផលិតភាពកើនឡើង រដ្ឋាភិបាលនឹងរៀបចំគោលនយោបាយ ច្បាប់និងបរិយាកាសនៃការគាំទ្រដល់វិស័យជលផល ដែលមានភាពសមស្របនិងបង្កភាពងាយស្រួល។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏បានគិតគូរចំពោះបរិបទនៃអន្តរជាតិដែលមានការពាក់ព័ន្ធ។ ក្នុងករណីនេះ គឺតម្រូវឱ្យមានយុទ្ធសាស្ត្រដ៏ទូលំទូលាយសម្រាប់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ដើម្បីដោះស្រាយបាននូវបញ្ហាដែលវិស័យជលផលនៅកម្ពុជាជួបប្រទះ៖ រួមមានការប្រែប្រួលអាកាសធាតុ ការធ្វើទំនប់កាត់ទន្លេនៅផ្នែកខាងលើ ការរេចរឹលបរិស្ថាន ដែលត្រូវយកមកអនុវត្តឱ្យបានពេញលេញ។ លើសពីនេះ ការស្រាវជ្រាវនឹងត្រូវធ្វើឡើងដើម្បីគាំទ្រដល់ការរៀបចំនិងអនុវត្តនូវគោលនយោបាយ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ។ កិច្ចការនេះ ចាំបាច់ត្រូវមានការលើកកម្ពស់នូវសមត្ថភាពបុគ្គលនិងអង្គភាពនៅក្នុងរដ្ឋបាលជលផល ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព និងធ្វើការជាមួយនឹងវិស័យនានាក្នុងការសម្រេចបាននូវគោលដៅសមាហរណកម្មនិងនិរន្តរភាពទៅថ្ងៃអនាគត។

## ទស្សនវិស័យសម្រាប់ឆ្នាំ២០៣០ និងការអភិវឌ្ឍបៃតង

ទោះបីជាគោលដៅនៃការអភិវឌ្ឍន៍រយៈពេលមធ្យម ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់ទី ៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏ដោយ ក៏ប៉ុន្តែគោលដៅអភិវឌ្ឍន៍រយៈពេលវែងក៏ត្រូវបានកំណត់នូវក្នុងឯកសារនៃទស្សនវិស័យសម្រាប់ឆ្នាំ២០៣០។ ទស្សនវិស័យនេះបានដាក់បញ្ចូលកម្ពុជាឱ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ជាមួយនឹងស្ថិរភាពសេដ្ឋកិច្ច ដែលការប្រកបមុខរបរមានភាពប្រសើរនិងមានផលចំណេញប្រកបដោយសមធម៌។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនឹងរួមចំណែកយ៉ាងសំខាន់ដល់ទស្សនវិស័យនេះ តាមរយៈការផ្តោតលើពាណិជ្ជនីយកម្មជលផល ដែលមានគោលដៅផ្តោតលើកំណើនផលិតផលសរុបក្នុងស្រុក។

ផែនការមេនៃការអភិវឌ្ឍបៃតង ត្រូវបានរៀបចំឡើងស្របជាមួយនឹងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ គោលបំណងសំខាន់ៗរបស់ផែនការមេនៃការអភិវឌ្ឍបៃតងរួមមាន៖ ១). ប្រើប្រាស់នូវសក្តានុពលនៃការអភិវឌ្ឍបៃតងកម្ពុជា ២). បង្កើតប្រព័ន្ធច្បាប់និងស្ថាប័ន ដើម្បីអនុវត្តនិងតាមដានដ៏មានប្រសិទ្ធភាពទៅលើគោលនយោបាយអភិវឌ្ឍន៍បៃតង ៣). កំណត់នូវអាទិភាពរបស់វិស័យសម្រាប់ការអភវិឌ្ឍបៃតងរបស់កម្ពុជា និង ៤). បង្កើតអភិក្រមរួមមួយដែលតំណាងឱ្យគោលការណ៍យុទ្ធ-សាស្ត្រនិងផែនការសកម្មភាព ដែលមានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងផែនទីបង្ហាញផ្លូវនៃការអភិវឌ្ឍបៃតងជាតិ។

ដើម្បីសម្រេចបាននូវគោលដៅនៃផែនការមេនៃការអភិវឌ្ឍបៃតង រដ្ឋាភិបាលបានកំណត់នូវគោលបំណងសំខាន់ៗដូចខាងក្រោម៖

១. ជំរុញកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ ដោយអនុវត្តតាមគោលនយោបាយដោះស្រាយនូវតម្រូវការគ្រប់ៗគ្នា រួមទាំងក្រុមអ្នកទន់ខ្សោយនិងមនុស្សជំនាន់ក្រោយផងដែរ។
២. ធានាបាននូវនិរន្តរភាពនៃបរិស្ថាន។
៣. ជំរុញចលនាសេដ្ឋកិច្ចបៃតងនិងបង្កើតការងារបៃតង។
៤. ការពារកេរ្តិ៍មរតកធម្មជាតិរបស់កម្ពុជាដែលពោរពេញទៅដោយជីវសាស្ត្រចម្រុះ។
៥. ធានាបានថា ទឹក ដី និងធនធានធម្មជាតិត្រូវបានប្រើប្រាស់មានប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងសមធម៌សម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។
៦. ពង្រឹងសុខភាពនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតងគ្រប់ជ្រុងជ្រោយ។
៧. បង្កើននូវភាពធន់ទ្រាំនៃបរិស្ថាននិងប្រជាជនចំពោះឥទ្ធិពលអវិជ្ជមានដែលកើតមានឡើង។

ក្របខ័ណ្ឌផែនការយុទ្ធសាស្រ្តសម្រាប់វិស័យជលផល មានការពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងគោលដៅទាំងនេះ តាមរយៈការលូតលាស់និងការកាត់បន្ថយភាពក្រីក្រ នៅក្នុងវិស័យជលផលនិងការធានាបាននូវនិរន្តរភាពនៃបរិស្ថាន និងការការពារកេរ្តិ៍មរតកធម្មជាតិ តាមរយៈការអភិវឌ្ឍខ្សែសង្វាក់ប្រព័ន្ធផលិតកម្ម ការលើកកម្ពស់សន្តិសុខស្បៀង និងភាពធន់ទ្រាំរបស់សហគមន៍និងធនធាននៅមូលដ្ឋាន។

## គោលនយោបាយស្តីពី ការប្រែប្រួលអាកាសធាតុ

គោលនយោបាយវិស័យជលផលក៏មានការពាក់ព័ន្ធជាមួយនឹងផែនការយុទ្ធសាស្រ្តស្តីពី ការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ ផងដែរ។ បេសកកម្មនៃផែនការយុទ្ធសាស្រ្តស្តីពី ការប្រែប្រួលអាកាសធាតុ គឺបង្កើតក្របខ័ណ្ឌជាតិសម្រាប់ការចូលរួមពីសាធារណៈ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នៅក្នុងដំណើរការនៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ គោលដៅនានានៃផែនការនេះរួមមានការកាត់បន្ថយភាពងាយរងគ្រោះ ការប្តូរទិសដៅទៅរកការអភិវឌ្ឍតាមបែបការអភិវឌ្ឍបៃតង និងលើកកម្ពស់ការយល់ដឹងជាសាធារណៈនិងចូលរួមក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ផែនការយុទ្ធសាស្រ្តស្តីពីការប្រែប្រួលអាកាសធាតុ គឺមានការទទួលស្គាល់យ៉ាងពេញលេញនូវភាពងាយរងគ្រោះរបស់វិស័យលផលនិងសហគមន៍មូលដ្ឋាន ដែលពឹងផ្អែកលើធនធានជលផលបណ្តាលមកពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្រ្តស្តីពីការប្រែប្រួលអាកាសធាតុអំពាវនាវឱ្យមានការធ្វើសមាហរណកម្មពេញលេញនូវការជះឥទ្ធិពលនិងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍វិស័យ។ ភាពមិនទៀងទាត់នៃឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ តម្រូវឱ្យវិស័យជលផលមិនត្រឹមតែកសាងនូវភាពធន់ទ្រាំប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើការសម្របតាមរយៈការកសាងផែនការដែលអាចបត់បែន និងអាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងទៅថ្ងៃអនាគត។ លើសពីនេះ គឺតម្រូវឱ្យមានការយល់ដឹងអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុមកលើវិស័យនិងរៀបចំវិធានការសម្រាប់តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍អំពីបញ្ហានេះ។

គោលការណ៍ណែនាំសំខាន់សម្រាប់វិស័យជលផលរួមមាន៖ ១) ធ្វើការសម្របនិងកាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ២) ទទួលស្គាល់នូវតម្រូវការសម្រាប់អភិក្រមជាអន្តរវិស័យ ៣) អនុវត្តអភិក្រមនៃការរួមបញ្ចូលរវាងសហគមន៍ជាមួយនឹងមូលដ្ឋានវិទ្យាសាស្រ្តនិងប្រព័ន្ធអេកូឡូស៊ី ៤) ធានាបានថាការឆ្លើយតប គឺគិតគូរអំពីបញ្ហាយេនឌ័រ និង៥) ជំរុញការចូលរួមពីថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ។

ផែនការអាទិភាពនៃការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម ព្រៃឈើ និងជលផលឆ្នាំ២០១៤-២០១៨ បានរៀបចំឡើងដោយក្រុមការបច្ចេកទេសកសិកម្មនិងការប្រែប្រួលអាកាសធាតុរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម

គោលដៅរួមរបស់វិស័យកសិកម្ម គឺជំរុញកំណើនកសិកម្មឱ្យបាន៥%ប្រចាំឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជូនីយកម្មកសិកម្ម។ ដើម្បីសម្រេចបាននូវគោលដៅនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨ គឺផ្អែកលើសសរស្តម្ភចំនួន៤ ដូចខាងក្រោម៖

- បង្កើនផលិតភាពពិពិធកម្មនិងពាណិជ្ជូនីយកម្មកសិកម្ម
- ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ
- លើកកម្ពស់ការគ្រប់គ្រងធនធានជលផលនិងព្រៃឈើប្រកបដោយនិរន្តរភាពនិង
- ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍធនធានមនុស្ស។

វិស័យជលផលរួមចំណែកដល់សសរស្តម្ភទាំងនេះ ហើយវិស័យជលផលមានអនុកម្មវិធីចំនួន១សម្រាប់អនុវត្តរួមមានដូចខាងក្រោម៖

១. ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ
២. ការគ្រប់គ្រងដែននេសាទ
៣. ជំរុញការអភិវឌ្ឍវារីវប្បកម្ម
៤. លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សនិងការអនុវត្តច្បាប់
៥. ការស្រាវជ្រាវនិងអភិវឌ្ឍជលផលទឹកសាប
៦. ការស្រាវជ្រាវនិងអភិវឌ្ឍជលផលសមុទ្រ
៧. ការស្រាវជ្រាវអំពីបច្ចេកទេសវារីវប្បកម្ម
៨. ការធ្វើឲ្យប្រសើរឡើងនៃខ្សែសង្វាក់ផលិតកម្មជលផល
៩. ការអភិរក្សនិងការការពារធនធានជលផល
១០. ការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលនិង
១១. អភិបាលកិច្ចនិងប្រតិបត្តិការនៃរដ្ឋបាលជលផល។

ចំណុចដៅសម្រាប់វិស័យជលផល ក្នុងរយៈពេល៤ឆ្នាំខាងមុខ ត្រូវបានកំណត់នៅក្នុងអនុកម្មវិធីទាំងនេះ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។

# ២ ឧបសម្ព័ន្ធ

## ការណែនាំអំពីសូចនាករនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ សម្រាប់វិស័យជលផលនិងចំណុចដៅ

សូចនាករដែលបានចែងនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤ គឺជាសូចនាករសម្រេចបានលទ្ធផលចុងក្រោយមានលក្ខណៈទូលំទូលាយ ជាឧទាហរណ៍ការប្រែប្រួលផ្សេងៗដែលពាក់-ព័ន្ធជាមួយហើយរដ្ឋបាលជលផលនិងក្រុមការងារបច្ចេកទេសជលផលមិនអាចត្រួតពិនិត្យ និងទទួលបានដោយផ្ទាល់។ សូចនាករទាំងនេះគឺជាផលនៃធាតុចូល សកម្មភាព និងធាតុចេញដែលសម្រេចបានពីការអនុវត្តរបស់រដ្ឋបាលជលផលនិងដៃគូអភិវឌ្ឍន៍ ប៉ុន្តែត្រូវផ្អែកលើការចូលរួមដ៏ទូលំទូលាយនៅក្នុងវិស័យជលផល ហើយជាទូទៅភាគច្រើននៅលើវិស័យដែលទទួលបានជោគជ័យនូវលទ្ធផលទាំងអស់នេះនៅក្នុងសេដ្ឋកិច្ច។ នៅក្នុងតារាងខាងក្រោម សូចនាករនិងចំណុចដៅទាំងនេះ ត្រូវបានគូសបញ្ជាក់លម្អិតដើម្បីជាជំនួយដល់ការតាមដាននៅក្នុងឆ្នាំខាងមុខ។

| សូចនាករ | កំណត់សំគាល់ |
|---|---|
| សសរស្តម្ភទី១<br>សូចនាករ ១.១ | ការនេសាទពីគ្រប់ប្រភព រួមទាំងការនេសាទតាមវាលស្រែនិងនេសាទសមុទ្រសរុបរួមបញ្ចូលគ្នា។ ទោះបីជា ផលនេសាទពីធម្មជាតិមានការប្រែប្រួលពី១ឆ្នាំទៅ១ឆ្នាំក៏ដោយ ប៉ុន្តែគោលដៅនៃផលចាប់ត្រូវបានកំណត់នៅត្រឹមចំនួន៦០០.០០០តោនប៉ុណ្ណោះ។ ការកំណត់នេះ គឺមានគោលដៅធានាបាននូវនិរន្តរភាពនៃផលស្តុក ដែលក្នុងនោះការនេសាទមិនអាចបង្កើនឱ្យលើសពីកម្រិតនេះបានឡើយ។ |
| សសរស្តម្ភទី១<br>សូចនាករ ១.២ | ទោះបីជាចំនួនសហគមន៍នេសាទជាច្រើនត្រូវបានបង្កើតឡើង ប៉ុន្តែបញ្ហាសំខាន់ជាងនេះ គឺប្រសិទ្ធភាពក្នុងការផ្តល់នូវសេវាកម្មនៃការគ្រប់គ្រងរបស់សហគមន៍និងផលប្រយោជន៍ផ្សេងៗដែលសហគមន៍ទទួលបាន។ ការវាយតម្លៃអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងសហគមន៍នេសាទទាំងនោះនឹងត្រូវកំណត់តាមរយៈលក្ខណៈវិនិច្ឆ័យធំទូលាយមួយចំនួនដូចមានចែងខាងក្រោម៖<br>១. ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានជលផល<br>២. ក្របខ័ណ្ឌច្បាប់របស់សហគមន៍នេសាទ<br>៣. តួនាទីនិងមុខងាររបស់គណៈកម្មការសហគមន៍នេសាទ |

| | |
|---|---|
| | ៤. ការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍<br>៥. ដំណើរការបណ្តាញសហគមន៍នេសាទ<br>៦. សហគមន៍នេសាទមានប្រភពធនធានហិរញ្ញវត្ថុសមស្រប<br>៧. សហគមន៍នេសាទមានមុខរបរចិញ្ចឹមជីវិតប្រកបដោយគុណភាពនិង<br>៨. ប្រសិទ្ធភាពនៃការអភិរក្សរបស់សហគមន៍នេសាទ។<br><br>រដ្ឋបាលជលផលបានប៉ាន់ស្មានថា បច្ចុប្បន្ននេះក្នុងចំណោមសហគមន៍នេសាទទាំងអស់មានសហគមន៍ប្រមាណតែ១ភាគ១០ប៉ុណ្ណោះដែលត្រូវបានចាត់ថ្នាក់ជាសហគមន៍នេសាទដែលមានដំណើរការល្អ។ លក្ខណៈវិនិច្ឆ័យអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងសហគមន៍នេសាទនឹងត្រូវរៀបចំឡើង ហើយនឹងពិភាក្សានៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលបានធ្វើឡើងនូវខែសីហា ឆ្នាំ២០១៥។ លក្ខណៈវិនិច្ឆ័យដែលមានការឯកភាពនឹងត្រូវរៀបចំជាមធ្យោបាយសម្រាប់តាមដាន ហើយប្រើសម្រាប់កំណត់នូវទិន្នន័យគោលដែលកំណត់នៅក្នុងឆ្នាំ២០១៥។ មធ្យោបាយតាមដាននេះ គឺនឹងប្រើសម្រាប់តាមដានសហគមន៍នេសាទជាប្រចាំ ដែលនឹងធ្វើឡើងរួមគ្នារវាងរដ្ឋបាលជលផលថ្នាក់កណ្តាលនិងខណ្ឌរដ្ឋបាលជលផល។ |
| សសរស្តម្ភទី១<br>សូចនាករ ១.៣ | ផ្ទៃដែននេសាទសរុបទុកសម្រាប់ធ្វើជាកន្លែងអភិរក្សឱ្យមានប្រសិទ្ធភាព គឺត្រូវបានជ្រើសរើសដើម្បីកំណត់នូវសូចនាករជាក់លាក់។ ការប្រើពាក្យប្រសិទ្ធភាពនេះ គឺចង់បញ្ជាក់ថាពេលបង្កើតកន្លែងអភិរក្សហើយគឺមានដំណើរការល្អនិងមានផលប្រយោជន៍។ មានការកត់សំគាល់ថា កន្លែងអភិរក្សផ្សេងគ្នា គឺតម្រូវឱ្យមានលក្ខណៈវិនិច្ឆ័យផ្សេងគ្នាសម្រាប់វាយតម្លៃពីប្រសិទ្ធភាពរបស់វា (លក្ខណៈវិនិច្ឆ័យទាំងនេះជាធម្មតា គឺជាផ្នែកនៃផែនការគ្រប់គ្រងកន្លែងអភិរក្សទាំងនោះ)។ ករណីនេះ គឺតម្រូវឱ្យមានលក្ខណៈវិនិច្ឆ័យទៅតាមកន្លែងអភិរក្សរៀងខ្លួន ដែលមានការឯកភាពពីរដ្ឋបាលជលផលនិងចងក្រងជាឯកសារ។ បញ្ហាផ្សេងទៀតដែលត្រូវគិតគូរ គឺទំនាក់ទំនងនិងការភ្ជាប់គ្នារវាងកន្លែងអភិរក្សផ្សេង។ នេះគឺជាបញ្ហាដ៏សំខាន់ដែលត្រូវគិតគូរនៅក្នុងដំណើរការរៀបចំបង្កើតកន្លែងអភិរក្សនីមួយៗដើម្បីធានានូវប្រសិទ្ធភាព។ ប្រសិនគ្មានការភ្ជាប់គ្នារវាងកន្លែងអភិរក្សផ្សេងៗគ្នាក៏ដូចជារវាងទីជម្រកផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់វដ្តនៃជីវិត |

| | |
|---|---|
| សសរស្តម្ភទី១<br>សូចនាករ ១.៣ | របស់វាវិសេចន្តនោះទេ កន្លែងអភិរក្សដែលបង្កើតឡើងទាំងនោះ គឺមិនមានប្រសិទ្ធភាពឡើយ។ ព័ត៌មានលម្អិតអំពីប្រភេទនិងទំហំនៃកន្លែងអភិរក្សដែលត្រូវបង្កើត គឺមានចែងនៅក្នុងកម្រិតលទ្ធផលសម្រេចនៃអនុកម្មវិធី។ នៅក្នុងបរិបទនេះ ស្រះជម្រកត្រីសហគមន៍ត្រូវបាន ចាត់ទុកថាមានសារៈសំខាន់ ជាពិសេសសម្រាប់និរន្តរភាពនៃការនេសាទ ដែលពាក់ព័ន្ធ ជាមួយនឹងនេសាទវាលស្រែ។ ទោះបីជាកន្លែងនីមួយៗរបស់ស្រះជម្រកត្រីសហគមន៍ មានទំហំតូច ប៉ុន្តែការគ្រប់គ្រងទទួលបានជោគជ័យ គឺជាការចូលរួមចំណែកយ៉ាងសំខាន់ ចំពោះចំណុចដៅនៃសូចនាករ១.១នេះ។ |
| សសរស្តម្ភទី២<br>សូចនាករ ២.១ | ទោះបីជា ផលិតផលវារីវប្បកម្ម គឺជាសូចនាករមួយដែលខ្វះភ័ស្តុតាងបញ្ជាក់អំពីគុណភាព ផលិតផល ឬតម្លៃរបស់វាក៏ដោយ ប៉ុន្តែវាបានផ្តល់នូវនូវការណែនាំយ៉ាងសំខាន់សម្រាប់តាមដាននិងវាយតម្លៃអំពីផលត្រី ដែលមាននៅក្នុងវិស័យ។ នៅពេលដែលវារីវប្បកម្មកាន់តែដើរតួនាទីយ៉ាងសំខាន់ ការកត់ត្រាអំពីផលិតផលត្រីគឺចាំបាច់ត្រូវធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីសូចនាកររបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ចំណុចដៅសម្រាប់សូចនាករនេះ គឺបានបង្ហាញពីកំណើនដែលមានលំនាំជាខ្សែបន្ទាត់ត្រង់។ ទោះបីជាយ៉ាងដូចនេះក្តី លទ្ធភាពនៃកំណើននេះ គឺអាចកើតមានតាមខ្សែកោងនៃសក្តានុពលដែលឆ្លុះបញ្ចាំងអំពីដំណាក់កាលនៃកំណើនដែលមានល្បឿនយឺត។ ម្យ៉ាងទៀត កត្តាដែលមានឥទ្ធិពលដល់កំណើននេះ គឺវិស័យឯកជនដែលធ្វើឱ្យកំណើនអាចមានល្បឿនលឿនជាងនេះ នៅពេលដែលមានអ្នកវិនិយោគទុនថ្មីចូលរួម។ ការវាយតម្លៃអំពីវឌ្ឍនភាព គឺចាំបាច់ត្រូវមានភាពទន់ភ្លន់។ |
| សសរស្តម្ភទី២<br>សូចនាករ ២.២ | សូចនាករនេះ ត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃអំពីវារីវប្បកម្មដែលបានចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច។ ក្នុងករណីនេះការវាយតម្លៃទៅលើចំនួនអ្នកប្រតិបត្តិការវារីវប្បកម្មទ្រង់ទ្រាយមធ្យម ឬទ្រង់ទ្រាយធំជាលក្ខណៈពាណិជ្ជកម្ម។ នៅជំពូកទី១០នៃច្បាប់ជលផលកម្ពុជា បានកំណត់នូវទ្រង់ទ្រាយវារីវប្បកម្មដែលតម្រូវឱ្យមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល រួមមានដូចខាងក្រោម៖ |

| | |
|---|---|
| | • វារីវប្បកម្មទឹកសាប (មាត្រា៥៣)៖ ស្រះដែលមានក្រឡាផ្ទៃសរុបលើសពី៥០០០ម² ស៊ងដែលមានក្រឡាផ្ទៃសរុបលើសពី៥០០០ម² បែដែលមានក្រឡាផ្ទៃសរុបលើសពី ១៥ម²។<br>• វារីវប្បកម្មសមុទ្រ (មាត្រា៥៤)៖ បែដែលមានក្រឡាផ្ទៃសរុបលើសពី២០ម² ស្រែបង្គា ឬស្រះត្រីដែលមានក្រឡាផ្ទៃសរុបលើសពី៥០០០ម² វារីរុក្ខជាតិគ្រប់ប្រភេទដែលមាន ផ្ទៃក្រឡាសរុបលើពី៥០០០ម² វារីសត្វផ្សេងទៀតដែលមានក្រឡាផ្ទៃសរុបលើសពី ៣០០០ម²។<br>គួរកត់សម្គាល់ថា ការជ្រើសរើសយកវារីវប្បកម្មទ្រង់ទ្រាយមធ្យម ឬធំសម្រាប់សូចនាករ នេះ មិនមែនមានន័យថា វារីវប្បកម្មទ្រង់ទ្រាយតូចពុំមានសារៈសំខាន់នោះទេ។ វារីវប្ប-កម្មទ្រង់ទ្រាយតូច គឺមានតួនាទីយ៉ាងសំខាន់ចំពោះសន្តិសុខស្បៀងនិងជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅជនបទ។ លើសពីនេះ ការរួមចំណែករបស់វារីវប្បកម្មទ្រង់ទ្រាយ តូច គឺបានបញ្ចូលនៅក្នុងសូចនាករទី២.១ រួចហើយ។ |
| សសរស្តម្ភទី២<br>សូចនាករ ២.៣ | ការចូលរួមចំណែករបស់វារីវប្បកម្មចំពោះផលិតផលសរុបក្នុងស្រុកគិតជាដុល្លារសហ-រដ្ឋអាមេរិក គឺជាខ្នាតយ៉ាងសំខាន់ក្នុងការបង្ហាញពី ការចូលរួមចំណែករបស់វារីវប្បកម្ម ចំពោះសេដ្ឋកិច្ចជាតិ។ ចំណុចដៅទាំងនេះ នឹងមានការកើនឡើងយ៉ាងច្រើន នៅពេល ដែលអ្នកវិនិយោគទុនចូលរួមច្រើននៅក្នុងវិស័យនេះ។ ការប្រៀបធៀបតម្លៃផលិតផល ជាក់ស្តែងជាមួយនឹងចំណុចគោលដៅនឹងផ្តល់នូវខ្លឹមសារនៃការប្រែប្រួលនេះ។ |
| សសរស្តម្ភទី៣<br>សូចនាករ ៣.១ | ផលិតផលសរុបក្នុងស្រុករបស់កម្ពុជាក្នុងឆ្នាំ២០១៤ គឺមានចំនួន១៦៣ពាន់លានដុល្លារ អាមេរិក។ ផ្អែកតាមការគណនាផល ផលិតផលជលផលលក់ចេញជាមធ្យមក្នុងតម្លៃ ២ដុល្លារ/១គីឡូក្រាម នោះវិស័យជលផលបានចូលរួមចំណែកប្រមាណ៩% នៃផលិត ផលសរុបក្នុងស្រុក។ ការចូលរួមចំណែកនេះ គឺមានការធ្លាក់ចុះតិចតួចដោយសារ កំណើនផលិតផលសរុបក្នុងស្រុកកើនឡើងខ្ពស់ទន្ទឹមនឹងការលូតលាស់យឺតៗរបស់វារី-វប្បកម្ម នៅក្នុងដំណាក់កាលដំបូងបណ្តាលឱ្យអត្រាកំណើនរបស់វិស័យជលផលមាន ត្រឹមតែ៨%។ |

| | |
|---|---|
| សសរស្តម្ភទី៣<br>ស្ទូចនាករ ៣.២ | សូចនាករនេះ គឺពាក់ព័ន្ធនឹងការកើនឡើងនូវការនាំចេញនូវផលនេសាទនិងវារីវប្បកម្មស្របច្បាប់។ សូចនាករនេះមិនត្រឹមតែលើកទឹកចិត្តដល់ការនាំចេញប៉ុណ្ណោះទេ ប៉ុន្តែវាក៏លើកទឹកចិត្តដល់ការនាំចេញដែលធ្វើឡើងតាមប្រព័ន្ធផ្លូវការ។ |
| សសរស្តម្ភទី៣<br>ស្ទូចនាករ ៣.៣ | សូចនាករនេះពាក់ព័ន្ធនឹងការលើកទឹកចិត្តក្នុងការសម្រេចបាននូវសូចនាករវិស័យពាណិជ្ជកម្ម និងអនុវត្តបានតាមលក្ខខណ្ឌរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន។ ទោះបីជាយ៉ាងដូចនេះក្តី អ្នកកែច្នៃទ្រង់ទ្រាយតូចក៏មានសារៈសំខាន់ដូចគ្នាផងដែរ ហើយនៅក្នុងរយៈពេលមធ្យមទៅរយៈពេលវែងនឹងត្រូវលើកទឹកចិត្តឱ្យមានការអនុវត្តអនាម័យល្អចំពោះអ្នកកែច្នៃទាំងនោះ ដែលជាអ្នកផ្គត់ផ្គង់ដល់ទីផ្សារក្នុងស្រុក។ |
| សសរស្តម្ភទី៤<br>ស្ទូចនាករ៤.១ | សូចនាករទី៤.១ ត្រូវបានរៀបចំឡើង ដើម្បីឆ្លុះបញ្ចាំងនូវទស្សនៈយល់ឃើញរបស់សាធារណៈអំពីវិស័យជលផល ដែលជាវិស័យផ្តល់នូវជម្រើសការងារយ៉ាងសំខាន់។ រដ្ឋបាលជលផល នឹងជ្រើសរើសយកវគ្គបណ្តុះបណ្តាលជាច្រើនពីវិទ្យាស្ថានជាតិនានា ហើយធ្វើការវាយតម្លៃលទ្ធផលឱ្យបានទៀងទាត់ ដើម្បីកំណត់ពីកម្រិតនៃការចុះឈ្មោះចូលរៀននូវវគ្គបណ្តុះបណ្តាលទាំងនោះ។ វគ្គបណ្តុះបណ្តាលទាំងនេះ មិនកំណត់ទៅលើតែមុខវិជ្ជាជីវសាស្ត្រជលផលប៉ុណ្ណោះទេ ប៉ុន្តែក៏មានជំនាញវារីវប្បកម្មនិងជំនាញផ្សេងៗទៀតដូចជាទីផ្សារ សេដ្ឋកិច្ចសង្គមដែលពាក់ព័ន្ធនឹងវិស័យជលផល។ ការចុះឈ្មោះចូលរៀននៅវិទ្យាស្ថាននានារួមមានដូចខាងក្រោម៖<br>១. សាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង (និស្សិតចំនួន២០នាក់ សម្រាប់ឆ្នាំសិក្សា២០១៤/២០១៥ យោងតាមលោក **ឈូក មុរិន** នាយកមហាវិទ្យាល័យវិទ្យាសាស្ត្រជលផល)។<br>២. សាកលវិទ្យាល័យកសិកម្មព្រែកលាប (និស្សិតចំនួន១០នាក់ សម្រាប់ឆ្នាំសិក្សា ២០១៤/២០១៥ យោងតាមលោក **យ៉េន សីថិន** មន្ត្រីរដ្ឋបាល)។<br>៣. សាកលវិទ្យាល័យកសិកម្មកំពង់ចាម (និស្សិតចំនួន១០នាក់ សម្រាប់ឆ្នាំសិក្សា ២០១៤/២០១៥ យោងតាមលោក **ហ៊ីង សុផាន់ណារិទ្ធ** នាយរងខណ្ឌរដ្ឋបាលជលផលកំពង់ចាម ហើយជាគ្រូបង្រៀននៅសកលវិទ្យាល័យកសិកម្មកំពង់ចាម។ |

| | |
|---|---|
| សសរស្តម្ភទី៤<br>សូចនាករ ៤.២ | សូចនាករ៤.២ នេះមានគោលបំណងវាយតម្លៃនូវការចូលរួមរបស់ក្រសួងដទៃទៀតក្នុងដំណើរការសម្រេចចិត្តរបស់រដ្ឋបាលជលផលពាក់ព័ន្ធនឹងវិស័យជលផល។ កិច្ចការដែលត្រូវវាយតម្លៃនេះ គឺចំនួនលិខិតផ្លូវការដែលរដ្ឋបាលជលផលបានទទួលរួមមានលិខិតជូនព័ត៌មានដល់រដ្ឋបាលជលផលនិងលិខិតស្នើឱ្យរដ្ឋបាលជលផលផ្តល់នូវព័ត៌មានសម្រាប់ធ្វើការសម្រេចចិត្តនានា។ |
| សសរស្តម្ភទី៤<br>សូចនាករ ៤.៣ | សូចនាករនេះត្រូវបានបង្កើតឡើង ដើម្បីបង្ហាញពីការយល់ឃើញរបស់សហគមន៍និងវិស័យឯកជនចំពោះការអនុវត្តរបស់រដ្ឋបាលជលផលនិងដៃគូអភិវឌ្ឍន៍ ផ្អែកតាមគោលនយោបាយនានារបស់រដ្ឋាភិបាល និងផ្តល់នូវឱកាសដល់ពួកគាត់ក្នុងការបញ្ចេញមតិយោបល់ចំពោះគោលនយោបាយទាំងនេះ។ ការធ្វើអង្កេតពីទស្សនៈយល់ឃើញនេះ នឹងត្រូវធ្វើឡើងប្រចាំឆ្នាំដោយមន្ត្រីតាមដាននិងវាយតម្លៃរបស់រដ្ឋបាលជលផល នៅតាមអនុវិស័យនីមួយៗដូចជា ការនេសាទខុសច្បាប់ ប្រសិទ្ធភាពនៃការគ្រប់គ្រងសហគមន៍នេសាទ ការគាំទ្រទីផ្សារ និងការផ្សព្វផ្សាយវារីវប្បកម្ម។ ការសិក្សាដើម្បីកំណត់នូវទិន្នន័យគោលនឹងត្រូវធ្វើឡើងនៅក្នុងឆ្នាំ២០១៥ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលពីមួយពេលទៅមួយពេល។ |











**រដ្ឋបាលជលផល**

អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រ៥៨២ គេហទំព័រ :www.fia.gov.kh

ការបោះពុម្ពសៀវភៅនេះ ជាជំនួយរបស់សហភាពអឺរ៉ុប
ហើយខ្លឹមសារនៅក្នុងសៀវភៅនេះជាការទទួលខុសត្រូវ
របស់រដ្ឋបាលជលផលនិងមិនឆ្លុះបញ្ចាំងពីទស្សនៈ
របស់សហភាពអឺរ៉ុបឡើយ។





